សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Laws and Economics

## សារណាបញ្ចប់ការសិក្សា

# ស្ត្រីជាពាណិជ្ជករ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. នាម ស្រីលាក់**
**ល. ជឹម សិទ្ធិវឌ្ឍនៈ**

សាស្ត្រាចារ្យណែនាំ
លោក **គង់ សាផន**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Laws and Economics

## សារណាបញ្ចប់ការសិក្សា

# ស្ត្រីជាពាណិជ្ជករ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: **ក. នាម ស្រីលាក់**
**ខ. ជឹម សិទ្ធិវឌ្ឍនៈ**

សាស្ត្រាចារ្យណែនាំ
លោក **គង់ សាផន**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **នាម ស្រីលាក់** និងខ្ញុំបាទឈ្មោះ **ជឹម សិទ្ធិវឌ្ឍនៈ** ជានិស្សិតឆ្នាំទី៤ ថ្នាក់នីតិសាស្ត្រ ជំនាន់ទី១៧ ក្នុងឆ្នាំសិក្សា ២០១៣-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះបុគ្គលមួយចំនួន** ដែលបានជួយជ្រោមជ្រែងយើងខ្ញុំតាំងពីដើមដល់ចប់ដើម្បីសម្រេចបាននូវ សារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំដូចតទៅៈ

លោកឪពុក **ខាត់ សាឌុន** អ្នកម្តាយ**អួន ឡុង** និងលោកឪពុក **ជិន សំអាត** អ្នកម្តាយ **មូល ស្រីពៅ** ដែលលោកបានផ្តល់កំណើតដល់យើងខ្ញុំ ហើយចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារបាតជើងក្រហម រហូតដល់យើងខ្ញុំពេញរូបពេញរាងធំដឹងក្តី។ ជាពិសេសលោកទាំងទ្វេខិតខំប្រឹងប្រែងតស៊ូធ្វើការ ដើម្បីផ្គត់ផ្គង់កូនៗឱ្យបានទទួលការសិក្សាខ្ពង់ខ្ពស់រហូតដល់ថ្នាក់ឧតម្តសិក្សា ហើយមានឱកាសសរសេរសារណាបញ្ចប់កាសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ កូនៗសូមថ្លែងអំណរគុណចំពោះគុណូបការៈនេះ និងសំដែងនូវកត្តញ្ញូតាធម៌ដល់លោកអ្នកមានគុណដែលផ្តល់នូវឱកាសដែលមិនអាចកាត់ថ្លៃបាន ក្នុងបុព្វហេតុដើម្បីឱ្យកូនៗក្លាយជាធនធានដែលសង្គមត្រូវការ។ ជាមួយគ្នានេះដែរ នាងខ្ញុំនាម ស្រីលាក់ ក៏សូមសំដែងនូវអំណរគុណដ៏ថ្លៃថ្លាចំពោះ**ក្រុមគ្រួសារ** THE STERLING ដែលបានជួយគាំទ្រនាងខ្ញុំទាំងទឹកចិត្ត និងហិរញ្ញវត្ថុកំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំមានឱកាសទទួលបានការបណ្តុះបណ្តាល បង្កើត និងពង្រីកទាំងចំណេះដឹង ទាំងជំនាញផ្នែកនីតិសាស្ត្រ ក្រោមការខិតខំប្រឹងប្រែងដឹកនាំរបស់លោក រហូតទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

**លោកសាស្ត្រាចារ្យ គង់ សាផន** ដែលបានបង្រៀន ហើយបណ្តាលឱ្យយើងខ្ញុំមានចំណាប់អារម្មណ៍ចំពោះនីតិពាណិជ្ជកម្ម និងជាពិសេសបំផុតនោះគឺលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចង្អុលបង្ហាញផ្លូវ ទូន្មាន ណែនាំ និងធ្វើការកែតម្រូវរាល់កំហុសឆ្គងរបស់យើងខ្ញុំ ដើម្បីធានានូវសមិទ្ធផលសារណាមួយដែលបង្កប់នូវ ការចូលរួមចំណែកដោះស្រាយបញ្ហាគតិយុត្ត ដែលសង្គមកំពុងជួបប្រទះនាពេលបច្ចុប្បន្ន។ យើងខ្ញុំចងចាំនូវពាក្យទូន្មានរបស់លោកអំពីការត្រៀមខ្លួនរួចរាល់មុននឹងការធ្វើអ្វីមួយ ជាពិសេសចំពោះដំណើរការសារណានេះតែម្តងដែលដំបូន្មាននោះគឺ **ត្រូវរៀបចំបន្លែ ត្រី សាច់ គ្រឿងផ្សំឱ្យហើយ សឹមចាប់ផ្តើមស្ល។** ជារួម យើង

ខ្ញុំសូមធ្វើការគោរពដឹងគុណចំពោះសេចក្តីសណ្តោសប្រណី របស់លោកក្នុងការទទួលយកសំណើដើម្បីដឹកនាំការសរសេរសារណារបស់យើងខ្ញុំទាំងពីរ ជាទុនជំនួយដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

លោក លោកស្រី សាស្ត្រាចារ្យ គណៈគ្រប់គ្រងសាកលវិទ្យាល័យទាំងអស់ដូចជា សាកលវិទ្យាធិការង ប្រធាន អនុប្រធានដេប៉ាតឺម៉ង់ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង មន្ត្រី និងបុគ្គលិកគ្រប់លំដាប់ និងផ្នែកទាំងអស់ដែលបានបង្ហាត់បង្រៀនយើងខ្ញុំ ជំរុញដំណើរការសាកលវិទ្យាល័យ ជាកតាលិករចូលរួមចំណែកឱ្យការសិក្សារបស់យើងខ្ញុំបានឈានមកដល់ ដំណាក់កាលសរសេរសារណា។

យើងខ្ញុំក៏សូមធ្វើការថ្លែងអំណរគុណផងដែរ ជូនទៅដល់និស្សិតរៀមច្បង មិត្តរួមថ្នាក់ រួមសាលា រួមជំនាន់ មិត្តភក្តិក្រៅសាលា បងៗ ប្អូនៗ លោកយាយ លោកតា ពូមីង អ៊ំ បុគ្គលិករដ្ឋ និងឯកជន លោកគ្រូអ្នកគ្រូទាំងឡាយ ដែលបានចែករំលែកទាំងឯកសារ បទពិសោធន៍ចាស់ថ្មី ចំណេះដឹង ព្រមទាំងផ្តល់នូវការលើកទឹកចិត្តដែលជំរុញឱ្យយើងខ្ញុំទាំងពីរមានភាពកក់ក្តៅ និងទំនុកចិត្តក្នុងការស្រាវជ្រាវ។

ជាចុងក្រោយ ខ្ញុំបាទ នាងខ្ញុំសូមគោរពជូនពរ លើកហត្ថាទាំងទ្វេប្រណម្យសំពះបួងសួងដល់ព្រះ និងទេវតាឱ្យថែរក្សាលោកឪពុក អ្នកម្តាយ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងលោកអ្នកដែលបានជួយជ្រោមជ្រែងយើងខ្ញុំទាំងពីរក្នុងកិច្ចការសរសេរសារណានេះ តាំងពីដើមដល់ចប់ និងសូមលោកទាំងអស់ទទួលបាននូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ក្នុងនាមជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំសូមអរគុណទុកជាមុនទៅដល់លោកគ្រូអ្នកគ្រូ មិត្តៗនិស្សិត និងប្រិយមិត្តទាំងអស់ដែលបានគាំទ្រនូវស្នាដៃសារណាមួយក្បាលស្តីពី "ស្ត្រីជាពាណិជ្ជករ" ដែលកំពុងតែកាន់នូវនឹងដៃនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សារណានេះគ្រាន់តែជាសមិទ្ធផលដ៏តូចមួយរបស់យើងខ្ញុំដែលបានរៀបរៀងចងក្រងឡើង សម្រាប់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់យើងខ្ញុំ។ ប៉ុន្តែអ្វីដែលជាគោលបំណងសំខាន់នៃការជ្រើសរើសប្រធានបទនេះ ដើម្បីយកមកសរសេរបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះគឺដោយសារយើងខ្ញុំសង្កេតឃើញថាពុំទាន់មាននិស្សិត ចាប់អារម្មណ៍ច្រើនទៅលើបញ្ហានេះនៅឡើយទេ ហើយយើងខ្ញុំចង់ធ្វើការស្រាវជ្រាវបន្ថែមអំពីច្បាប់ពាណិជ្ជកម្ម ជាពិសេសអំពីស្ត្រីនៅក្នុងវិស័យពាណិជ្ជកម្ម ក៏ដូចជាដើម្បីពង្រឹង និងពង្រីកបន្ថែមទៀតនូវចំណេះដឹងរបស់យើងខ្ញុំចំពោះវិស័យច្បាប់ពាណិជ្ជកម្មនេះផងដែរ។ម្យ៉ាងទៀត ដោយសារតែយើងខ្ញុំចង់យល់ដឹងឱ្យច្បាស់ពាក់ព័ន្ធនឹងបញ្ហាគតិយុត្ត ចំពោះស្ត្រីដែលជាពាណិជ្ជករ ថាតើពួកគាត់ធ្វើប្រតិបត្តិការដូចជាពាណិជ្ជករទូទៅ ឬយ៉ាងណា?។ អ្វីដែលសំខាន់មួយទៀតនោះគឺ យើងខ្ញុំជឿជាក់ថាតាមរយៈការស្រាវជ្រាវនេះ យើងខ្ញុំអាចប្រើប្រាស់ជាទុនជំនួយដល់ការអភិវឌ្ឍអាជីពនាពេលអនាគតរបស់យើងខ្ញុំ។ យ៉ាងណា មិញ ការស្រាវជ្រាវអំពីប្រធានបទនេះក៏បានជួបប្រទះនូវ ការលំបាកមួយចំនួនផងដែរ ទាក់ទងនឹង កង្វះខាតឯកសារ ប៉ុន្តែបញ្ហាកង្វះខាតនេះពុំមែនជាឧបសគ្គដែលបង្អាក់នូវការសម្រេចចេញ សារណាមួយក្បាលនេះឡើយ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថា សារណាមួយក្បាលនេះនឹងមានសារៈប្រយោជន៍អាចក្លាយជាជំនួយស្មារតីដល់លោកគ្រូអ្នកគ្រូ សិស្សានុសិស្សក្នុងការសិក្សា ស្រាវជ្រាវ ស្វែងយល់បន្ថែមអំពីបញ្ហាគតិយុត្តចំពោះស្ត្រីក្នុងវិស័យពាណិជ្ជកម្ម។ ជាមួយគ្នានេះដែរ យើងខ្ញុំពិតជាប្រាកដថាការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ ដូច្នេះ យើងខ្ញុំរង់ចាំទទួលនូវមតិរិះគន់ដើម្បីស្ថាបនារបស់អស់លោកអ្នកបងប្អូនអ្នកស្នេហាវិស័យច្បាប់ទាំងអស់គ្នា ជាពិសេសអ្នកស្នេហាវិស័យច្បាប់ពាណិជ្ជកម្ម ដើម្បីយកមកកែកុននូវកំហុសដែលកើតមានឡើងនានាទៅលើប្រធានបទ "ស្ត្រីជាពាណិជ្ជករ" មួយនេះ ប្រយោជន៍ឱ្យវាកាន់តែស៊ីជម្រៅ និងមានភាពប្រសើរឡើងៗ។

សូមទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........ ១

## ជំពូកទី១

## ស្ត្រីមិនទាន់រៀបការជាពាណិជ្ជករ

១.១ លក្ខខណ្ឌគតិយុត្តដើម្បីក្លាយជាពាណិជ្ជកររបស់ស្ត្រីមិនទាន់រៀបការ ........ ៥
១.១.១ សមត្ថភាពបំពេញពាណិជ្ជកិច្ច ........ ៥
១.១.១.១ ពាណិជ្ជកិច្ចតាមលក្ខណ: ឬតាមកម្មវត្ថុ ........ ៦
១.១.១.២ ពាណិជ្ជកិច្ចតាមលក្ខណ:បន្ទាប់បន្សំ ........ ១១
១.១.១.៣ ពាណិជ្ជកិច្ចតាមទម្រង់ ........ ១២
១.១.១.៤ កិច្ចចំរុះ ........ ១៣
១.១.១.៥ អនីតិជន និងនីតិជនជាពាណិជ្ជករ ........ ១៤
១.១.២ យកពាណិជ្ជកិច្ចជាមុខរបរប្រចាំខ្លួន ........ ១៥
១.១.៣ ចាត់ចែងសកម្មភាពក្នុងនាមខ្លួន និងប្រយោជន៍ខ្លួន ........ ១៦
១.២ សិទ្ធិរបស់ពាណិជ្ជករជាស្ត្រីមិនទាន់រៀបការ ........ ១៦
១.២.១ សិទ្ធិរបស់ពាណិជ្ជករ ........ ១៧
១.២.១.១ ការគ្រប់គ្រងអាជីវកម្ម ........ ១៨
១.២.១.២ សិទ្ធិចំពោះតតិយជន និងអ្នកប្រើប្រាស់ ........ ១៨
១.២.១.៣ សិទ្ធិចំពោះមុខរបរ ........ ១៨
១.២.២ របបទ្រព្យសម្បត្តិដែលស្ត្រីមិនទាន់រៀបការជាពាណិជ្ជករប្រើប្រាស់ ........ ១៩
១.៣ កាតព្វកិច្ចរបស់ពាណិជ្ជករជាស្ត្រីមិនទាន់រៀបការ ........ ១៩
១.៣.១ ការចុះបញ្ជីពាណិជ្ជកម្ម ........ ១៩
១.៣.១.១ ការចុះបញ្ជីកែប្រែ ........ ២១
១.៣.១.២ ការលុបឈ្មោះចេញពីបញ្ជី ........ ២១
១.៣.១.៣ ទណ្ឌកម្ម ........ ២១
១.៣.២ ការផ្សព្វផ្សាយជាសាធារណ:តាមផ្លូវច្បាប់ ........ ២៣
១.៣.៣ ការគ្រប់គ្រងបញ្ជីគណនេយ្យ ........ ២៣

១.៣.៤ ភាតព្វកិច្ចបង់ពន្ធ ............ ២៣

១.៣.៥ ភាតព្វកិច្ចផ្សេងៗទៀត ............ ២៣

## ជំពូកទី២

## ស្ត្រីរៀបការជាពាណិជ្ជករ

២.១ លក្ខខណ្ឌគតិយុត្តដើម្បីក្លាយជាពាណិជ្ជកររបស់ស្ត្រីរៀបការ ............ ២៥

២.១.១ ការសុំការអនុញ្ញាត ឬមានការព្រមព្រៀងពីស្វាមីរបស់ខ្លួន ............ ២៥

២.១.២ ការប្រកាសរបបទ្រព្យសម្បត្តិ ............ ២៦

២.១.២.១ ទ្រព្យផ្ទាល់ ............ ២៧

២.១.២.២ ទ្រព្យរួម ............ ២៨

២.១.៣ ការទទួលខុសត្រូវចំពោះប្រាក់បំណុលរបស់គតិយជន ............ ២៩

២.១.៤ ការចុះបញ្ជីពាណិជ្ជកម្ម ............ ២៩

២.១.៥ ការគ្រប់គ្រងអាជីវកម្ម: ករណីស្វាមីជាពាណិជ្ជករ ឬ/និងភរិយាជាពាណិជ្ជករ ............ ៣០

២.១.៥.១ ការអនុវត្តសកម្មភាពពាណិជ្ជកម្មដាច់ដោយឡែក ............ ៣០

២.១.៥.២ ការអនុវត្តសកម្មភាពពាណិជ្ជកម្មរួមដោយសហព័ទ្ធទាំងពីរ ............ ៣៧

២.២ ករណីលែងលះ ............ ៤៣

២.២.១ សាលក្រមរបស់តុលាការ ............ ៤៤

២.២.២ ការបែងចែកទ្រព្យសម្បត្តិ ............ ៤៥

២.២.២.១ ការបែងចែកទ្រព្យសម្បត្តិចំពោះប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិ តាមកិច្ចសន្យា ............ ៤៥

២.២.២.២ ការបែងចែកទ្រព្យសម្បត្តិចំពោះប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាម ច្បាប់កំណត់ ............ ៤៦

២.២.៣ របបអាហារកិច្ច ............ ៤៧

២.២.៣.១ អាហារកិច្ចចំពោះសហព័ទ្ធ ............ ៤៧

២.២.៣.២ អាហារកិច្ចចំពោះកូន ............ ៤៨

២.២.៤ ការចុះបញ្ជីកែប្រែ ............ ៤៩

២.៣ ករណីមរណភាពរបស់សហព័ទ្ធជាពាណិជ្ជករម្ខាងណាមួយ ............ ៥០

**២.៣.១ សន្តតិកម្មមានបណ្តាំ** ..................................................... ៥១
**២.៣.១.១ សមត្ថភាពរបស់មតកជន** ..................................................... ៥១
**២.៣.១.២ ទម្រង់មតកសាសន៍** ..................................................... ៥១
**២.៣.១.៣ ការចែងនៅក្នុងមតកសាសន៍** ..................................................... ៥២
**២.៣.១.៤ អច្ច័យទាន** ..................................................... ៥៣
**២.៣.២ សន្តតិកម្មតាមច្បាប់** ..................................................... ៥៤
**២.៣.២.១ ប្រភេទសន្តតិជន** ..................................................... ៥៤
**២.៣.២.២ ការសម្រួលចំណែកមរតក** ..................................................... ៥៥
**២.៣.២.៣ ភាគបម្រុង** ..................................................... ៥៦
**២.៣.៣ ការប្រកាសផ្សាយជាសាធារណៈពីមរណភាព និងការដោះស្រាយបំណុលចំពោះតតិយជន** ..................................................... ៥៧
**សេចក្តីសន្និដ្ឋាន** ..................................................... ៥៩
**អនុសាសន៍** ..................................................... ៦៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

អង្គការសហប្រជាជាតិ បានសម្រេចចេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០១៦-២០៣០ ចំនួនដប់ប្រាំពីរ។ មានគោលដៅមួយក្នុងចំណោមគោលដៅទាំងដប់ប្រាំពីរ គឺការសម្រេចឲ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចនៃស្ត្រី និងកុមារីគ្រប់រូប។ នេះគឺជាគោលដៅទី៥ ដែលវាសបញ្ជាក់ឱ្យឃើញថា ស្ត្រីកំពុងតែត្រូវបានលើកតម្កើងឡើងឲ្យដូចជាបុរសដែរ ខណៈពេលដែលស្ត្រីត្រូវបានទុកមួយឡែកកាលពីអតីតកាល។ ស្ត្រីត្រូវបានយកចិត្តទុកដាក់ឡើងវិញដោយសង្គម ឬរដ្ឋតាមរយៈការផ្តល់ឱកាសចូលរួមធ្វើការនៅក្នុងវិស័យផ្សេងៗជាច្រើន នៅគ្រប់កម្រិតទាំងអស់ ពោលគឺតាំងពីថ្នាក់ក្រោមដល់ថ្នាក់លើ ជាពិសេសថ្នាក់នៃការធ្វើការសម្រេចចិត្ត។ ដោយឡែក ប្រទេសកម្ពុជាយើងក៏ជាប្រទេសសមាជិកមួយរបស់អង្គការសហប្រជាជាតិផងដែរ។ ដូច្នេះ ប្រទេសកម្ពុជាយើង ក៏បាននឹងកំពុងអនុវត្តភារៈកិច្ចមួយនេះ ដោយកម្ពុជាបានអនុញ្ញាតឱ្យស្ត្រីចូលរួមនៅក្នុងវិស័យនានា ដើម្បីឲ្យស្ត្រីមានឱកាសចូលរួមអភិវឌ្ឍន៍ជាតិដោយផ្ទាល់ ហើយអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ ទៅលើវិស័យដែលស្ត្រីត្រូវបានកំហិតមិនឱ្យធ្វើពីកាលពីអតីតកាល តែត្រូវបានបើកឱកាសឱ្យទៅវិញ ដែលក្នុងនោះក៏មានវិស័យពាណិជ្ជកម្មផងដែរ។ យ៉ាងណាមិញ ព័ត៌មាននានាអំពីការឈានជើងចូលក្នុងវិស័យពាណិជ្ជកម្មរបស់ស្ត្រី ពុំទាន់មានភាពទូលំទូលាយនៅឡើយទេ ដែលវាគឺជាបញ្ហារាំងដល់ស្ត្រីមួយចំនួនមិនហ៊ានសម្រេចចិត្តចូលប្រឡូក។ យោលទៅលើ សេចក្តីដែលបានរៀបរាប់ខាងលើនេះ វាបានបង្កើតជាកត្តាមួយ ដែលធ្វើឱ្យក្រុមយើងខ្ញុំសម្រេចចិត្តលើកយកនូវប្រធានបទមួយដែលពុំសូវមានអ្នកជ្រើសរើសយកមកសិក្សាស្រាវជ្រាវ និងស្វែងយល់ពីគុណតម្លៃរបស់វា ទោះជាគេបានឃើញផ្ទាល់ភ្នែកជារៀងរាល់ថ្ងៃក៏ដោយ មកធ្វើការចងក្រងជាឯកសារ។ ប្រធានបទដែលក្រុមយើងខ្ញុំលើកយកមកសិក្សាស្រាវជ្រាវ ពិចារណា ដើម្បីធ្វើជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំមានចំណងជើងថា "**ស្ត្រីជាពាណិជ្ជករ**"។ តើប្រធានបទមួយនេះមានខ្លឹមសារ សារៈប្រយោជន៍ និងការចង្អុលបង្ហាញដូចម្តេចខ្លះ?

ស្ត្រីជាពាណិជ្ជករ! ក្រៅពីបណ្តាវិស័យវិជ្ជាជីវៈនានា ស្ត្រីក៏ត្រូវបានសង្គមកម្ពុជាទទួលស្គាល់នូវសមត្ថភាព និងតួនាទីរបស់ពួកគាត់នៅក្នុងការធ្វើពាណិជ្ជកម្ម ដែលវាបានអនុញ្ញាតឱ្យស្ត្រីអាចគ្រប់គ្រង និងមានជំនួយសេដ្ឋកិច្ចដោយខ្លួនឯងតាមរយៈការឈានជើងចូលក្នុងវិស័យពាណិជ្ជកម្មនេះ ដោយមិនចាំបាច់ពឹងពាក់ជំនួយសេដ្ឋកិច្ចពីស្វាមី ឬអ្នកដ៏ទៃនោះទេ។ លើសពីបំណងឯករាជ្យភាពសេដ្ឋកិច្ច ស្ត្រីមួយចំនួនចូលទៅក្នុងវិស័យពាណិជ្ជកម្ម ព្រោះមិនចង់ខ្ជះខ្ជាយពេលវេលាឥតប្រយោជន៍ ហើយមានមុខរបរមួយជាក់លាក់ដើម្បីរកចំណូលចូលក្នុងគ្រួសារ ឬធ្វើជាចំណែកមួយ

ដើម្បីជួយដល់ស្វាមី។ ទាំងនេះ បានធ្វើឱ្យស្ត្រីកសាងខ្លួនទៅជាពាណិជ្ជករដែលមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពីជំនះនូវឧបសគ្គទាំងឡាយដែលកើតចេញពីផ្នត់គំនិតសង្គម។ ដោយសារតែប្រពៃណី ទំនៀមទម្លាប់ ការប្រតិបត្តិតៗគ្នាបានធ្វើឱ្យរាំងស្ទះកំណើនពាណិជ្ជករជាស្ត្រី ព្រោះថា កាលពីដើមឡើយ ស្ត្រីនៅក្នុងសង្គមខ្មែរយើងមានតួនាទីតែនៅផ្ទះ ធ្វើកិច្ចការផ្ទះ ចិញ្ចឹមប្តីបាច់ អប់រំកូនៗតែប៉ុណ្ណោះ។ រីឯស្វាមីជាអ្នកចេញធ្វើការ រកស៊ីនៅខាងក្រៅដើម្បីរកចំណូលសម្រាប់គ្រួសារ។ យ៉ាងណាមិញ សង្គមកម្ពុជាយើងកំពុងតែធ្វើការដោះស្រាយនៅបញ្ហានេះ ដូចដែលបានរៀបរាប់កន្លងមក គឺកំពុងតែបង្ហាញការអភិវឌ្ឍសិទ្ធិរបស់ស្ត្រី។ សង្គមកម្ពុជាបច្ចុប្បន្ន បាននឹងកំពុងកែប្រែនូវផ្នត់គំនិតទាំងនេះ។ ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដែលត្រូវបានលើកឡើងអំពីសេរីភាពក្នុងការជ្រើសរើសមុខរបរផងដែរ។

ដើម្បីក្លាយខ្លួនជាពាណិជ្ជករមួយរូប ទាំងស្ត្រីនៅលីវ និងស្ត្រីរៀបការរួចអាចធ្វើបានដោយគ្រាន់តែបំពេញតាមលក្ខខណ្ឌតម្រូវតាមច្បាប់។ ស្ត្រីទាំងពីរប្រភេទ ត្រូវតែធ្វើការចុះបញ្ជីពាណិជ្ជកម្មផ្ទាល់របស់ខ្លួន ពោលស្ត្រីរៀបការរួចត្រូវចុះបញ្ជីពាណិជ្ជកម្មផ្សេងពីស្វាមីរបស់ខ្លួន ខណៈពេលដែលស្ត្រីនៅលីវគ្រាន់តែចុះជាបញ្ជីជាពាណិជ្ជកររូបវន្តបុគ្គលដូចគ្នា។ វាស្របជាមួយនឹងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលនិយាយពីសិទ្ធិស្មើគ្នារបស់ស្ត្រី និងបុរសក្នុងការជ្រើសរើសមុខរបរចិញ្ចឹមជីវិត។ នៅក្នុងច្បាប់ខ្មែរដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ក៏មានចែងអំពីលក្ខណៈសម្បត្តិជាពាណិជ្ជករផងដែរ។ ទន្ទឹមនឹងមានច្បាប់គោលដែលអនុញ្ញាតឱ្យស្ត្រីមានសិទ្ធិជ្រើសរើសមុខរបរដូចបុរស គួរបញ្ជាក់ផងដែរថា យើងពុំទាន់មានក្រមពាណិជ្ជកម្ម និងក្រមនីតិវិធីពាណិជ្ជកម្មនៅឡើយទេ ដែលវាបានឱ្យដឹងថាការសិក្សាពីពាណិជ្ជកម្មនៅមានលក្ខណៈរាយប៉ាយ។ ដូចនេះ ដើម្បីជាតឹកតាង យើងត្រូវក្រឡេកទៅមើលច្បាប់ដែលពាក់ព័ន្ធនានាជាច្រើន។ ជាក់ស្តែង រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៣៦ បានចែងអំពីសិទ្ធជ្រើសរើសមុខរបររបស់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ។ ដូចនេះ វាចង្អុលបង្ហាញថាស្ត្រីជាភេទមួយដែលអាចយកពាណិជ្ជកិច្ចជាមុខរបររបស់ខ្លួនបាន ដែលស្ត្រីនៅលីវគឺចាត់ចូលទៅក្នុងពាណិជ្ជករជារូបវន្តបុគ្គលដូចបុគ្គលទូទៅដែរ (មាត្រា១នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥)។ ជាមួយគ្នានេះដែរ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ ត្រង់មាត្រា៦ ក៏បាននិយាយពីសិទ្ធិស្ត្រីក្នុងការដែលអាចក្លាយខ្លួនជាពាណិជ្ជករបានដែរ ចំពោះស្ត្រីរៀបការរួច គឺត្រូវចុះបញ្ជីដោយឡែកពីស្វាមី។ ចំណាងគតិយុត្តនានា នឹងត្រូវបានអនុវត្តក្រោយពីស្ត្រីទទួលបានលក្ខណៈសម្បត្តិជាពាណិជ្ជករ ដូចជាការបង់ពន្ធ ការចំណេញ និងការខាតបង់ជាដើម។ នេះបានឆ្លុះបញ្ចាំងពីសមភាពយេនឌ័រ ដែលស្ត្រីមានសិទ្ធិស្មើនឹងបុរស ជាពិសេស

ចំពោះវិស័យពាណិជ្ជកម្មនេះតែម្តង។ គូររំលឹកឡើងចំពោះស្ត្រីរៀបការជាមួយពាណិជ្ជករ ពុំអាចរាប់ថាជាពាណិជ្ជករបានទេ នៅពេលដែលគាត់គ្រាន់តែសហការជួយកិច្ចការដល់ស្វាមីរបស់គាត់។ ដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ក៏បានចែងថា ពាណិជ្ជករត្រូវតែចេះគិតពិចារណាដឹងខុសត្រូវ និងយល់ដឹងពីប្រតិបត្តិការពាណិជ្ជកម្មដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌដើម្បីអនុវត្តសកម្មភាពពាណិជ្ជកម្ម។ បន្ថែមពីលើនេះ អ្នកដែលអនុវត្តសកម្មភាពពាណិជ្ជកម្មត្រូវតែជានីតិជន ឬអនីតិជនដែលទទួលបានអត្តាធិនភាព។

ចំពោះស្ត្រីនៅលីវ ដោយសារតែនាងនៅខ្លួនមួយ រាល់ការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់ប្រតិបត្តិការពាណិជ្ជកម្មរបស់នាងពុំមានលក្ខណៈស្មុគស្មាញទេ ព្រោះនាងប្រើប្រាស់តែទ្រព្យផ្ទាល់របស់នាងប៉ុណ្ណោះ។ រាល់ការចាត់ចែងទាំងអស់របស់ស្ត្រីនៅលីវជាពាណិជ្ជករ រាប់ទាំងបំណុលរបស់តតិយជន គឺនាងជាអ្នកចេញមុខដោះស្រាយដោយខ្លួនឯង។ ចំណែកឯកស្ត្រីដែលមានស្វាមីវិញ គឺត្រូវផ្តោតសំខាន់ទៅលើរបបទ្រព្យសម្បត្តិឱ្យបានច្បាស់លាស់សម្រាប់ដំណើរការសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន ព្រោះថាវាមិនទៀងទាត់ទេក្នុងជីវិតស្វាមីភរិយាដែលថាមិនមានបញ្ហារឿងគ្រប់គ្រងទ្រព្យសម្បត្តិ។ ស្ត្រីរៀបការរួចជាពាណិជ្ជករ ត្រូវធ្វើការប្រកាសរបបទ្រព្យសម្បត្តិរបស់ខ្លួនព្រោះវាពិតជាសំខាន់មែនទែនចំពោះការទទួលខុសត្រូវទាំងឡាយ ក្នុងសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន។ ការកំណត់របបទ្រព្យសម្បត្តិនេះ មានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ដែលត្រូវបែងចែកជាពីរប្រភេទគឺ ប្រព័ន្ធទព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិកំណត់តាមច្បាប់។ ដោយឡែកនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ មានចែងនៅក្នុងប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌។ ស្ត្រីរៀបការរួចត្រូវយកចិត្តទុកដាក់ ថាតើខ្លួនជ្រើសរើសទ្រព្យសម្បត្តិណាខ្លះមកប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន។ វាជាឆន្ទៈរបស់របស់គូស្វាមីភរិយាចពោះការសម្រេចចិត្តថាប្រើប្រាស់ទ្រព្យសម្បត្តិរួម ឬដោយឡែក ដែលជាប្រព័ន្ធទ្រព្យកំណត់ដោយច្បាប់ ឬធ្វើការចុះកិច្ចសន្យាលើទ្រព្យសម្បត្តិ។ ការសម្រេចចិត្តណាមួយបង្ហាញលទ្ធផលអំពីការទទួលខុសត្រូវរាល់ការចាត់ចែងរបស់ស្ត្រីក្នុងមុខរបរពាណិជ្ជកម្មរបស់ខ្លួន។ ដោយករណីភាគច្រើន ស្វាមីភរិយាជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់តាមច្បាប់។ ចំពោះករណីនេះ បើស្ត្រីជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិរួមទៅបម្រើប្រយោជន៍ពាណិជ្ជកិច្ចរបស់ខ្លួន ស្វាមីភរិយាមានសិទ្ធិស្មើគ្នា មានន័យថាភរិយាត្រូវតែមានការយល់ព្រមពីស្វាមីរាល់ការចាត់ចែង។ ប្រសិនបើស្ត្រីជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកមកដំណើរការពាណិជ្ជកម្មរបស់ខ្លួន ស្ត្រីមានសិទ្ធិផ្តាច់មុខក្នុងការចាត់ចែងដោយពុំចាំបាច់មានការយល់ព្រមពីស្វាមីទេ។ ក្រៅពីការជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិមកប្រើប្រាស់ ស្ត្រីក៏ត្រូវគិត និងចាត់ចែងនូវ

ទំនួលខុសត្រូវ និងកាតព្វកិច្ចទាំងឡាយផងដែរប្រសិនបើមានការរំលាយចំណងអាពាហ៍ពិពាហ៍ដោយលក្ខខណ្ឌណាមួយ។ វាជាបន្ទុករបស់ស្វាមី និងអ្នកពាក់ព័ន្ធរបស់នាងផងដែរប្រសិនបើនាងទទួលមរណភាព។

ប្រធានបទរបស់ក្រុមយើងខ្ញុំ "ស្ត្រីជាពាណិជ្ជករ" នេះ នឹងធ្វើការបកស្រាយខ្លឹមសារតាមរយៈអត្ថបទខាងក្រោមតាមវិធីសាស្ត្រទិន្នភាព (Collective Research Method) ពោលគឺយើងខ្ញុំធ្វើការចងក្រងដោយវិភាគទៅលើរបបគតិយុត្ត អត្ថបទច្បាប់នានា និងឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដែលយើងខ្ញុំបានធ្វើការប្រមែប្រមូលមក។ ប៉ុន្តែ មុននឹងឈានចូលដល់ការសិក្សាពីខ្លឹមសារ យើងខ្ញុំសូមធ្វើការរំលឹកសារជាថ្មីផងដែរថា ប្រធានបទរបស់យើងខ្ញុំមានវិសាលភាពត្រឹមតែស្ត្រីនៅលីវ និងស្ត្រីរៀបការរួចជាពាណិជ្ជករជារូបវន្តបុគ្គលប៉ុណ្ណោះ មិនឈានដល់ស្ត្រីជាពាណិជ្ជករនីតិបុគ្គលទេ។ ជាមួយគ្នានឹងការដែលស្ត្រីត្រូវបានលើកតម្កើងដូចបុរស យើងខ្ញុំសង្កេតឃើញថាកំណើននៃស្ត្រីដែលចង់ក្លាយខ្លួនជាពាណិជ្ជករមានការកើនឡើងទាំងស្ត្រីនៅលីវ និងស្ត្រីរៀបការរួចបើក្រឡេកទៅមើលសង្គមកម្ពុជាយើងបច្ចុប្បន្ន។ តើ "ស្ត្រីជាពាណិជ្ជករ" នឹងត្រូវបកស្រាយខ្លឹមសារដូចម្តេចខ្លះ? តើស្ត្រីជាពាណិជ្ជករមានតួនាទី ភារកិច្ចដូចម្តេចខ្លះចំពោះសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន? តើស្ត្រីជាពាណិជ្ជករអាចចូលរួមអភិវឌ្ឍប្រទេសយើងបានដូចម្តេចខ្លះ? ដើម្បីជាស្ពានឆ្លងដល់ការបង្ហាញខ្លឹមសារ យើងខ្ញុំសូមធ្វើការប្រកាសប្លង់នៃប្រធានបទនេះដូចខាងក្រោម។ ប្រធានបទ "ស្ត្រីជាពាណិជ្ជករ" ចែកចេញជា ២ជំពូក ដូចតទៅ៖ ស្ត្រីមិនទាន់រៀបការជាពាណិជ្ជករ (ជំពូក១) បែងចែកជាបីផ្នែក លក្ខខណ្ឌគតិយុត្តដើម្បីក្លាយជាពាណិជ្ជកររបស់ស្ត្រីមិនទាន់រៀបការ (ផ្នែកទី១) សិទ្ធិរបស់ពាណិជ្ជករជាស្ត្រីមិនទាន់រៀបការ (ផ្នែកទី២) កាតព្វកិច្ចរបស់ពាណិជ្ជករជាស្ត្រីមិនទាន់រៀបការ (ផ្នែកទី៣) ព្រមទាំង ស្ត្រីរៀបការជាពាណិជ្ជករ (ជំពូក២) បែងចែកជាបីផ្នែក លក្ខខណ្ឌគតិយុត្តដើម្បីក្លាយជាពាណិជ្ជកររបស់ស្ត្រីរៀបការ (ផ្នែកទី១) ករណីលែងលះ (ផ្នែកទី២) និង ករណីមរណភាពរបស់សហព័ទ្ធជាពាណិជ្ជករម្ខាងណាមួយ (ផ្នែកទី៣) ។ នៅខាងក្រោមនេះយើងនឹងធ្វើការបកស្រាយខ្លឹមសារទាំងស្រុងទៅទំព័របន្តបន្ទាប់។

# ជំពូកទី១

# ជំពូកទី១ ស្ត្រីមិនទាន់រៀបការជាពាណិជ្ជករ

ស្ត្រីនៅលីវមួយរូបអាចក្លាយជាពាណិជ្ជករបាន។ តើនេះជាការពិតឬទេ? វាគឺជាការពិត។ ស្ត្រីមិនទាន់រៀបការក៏ត្រូវបានចាត់ចូលជារូបវន្តបុគ្គលមួយរូបដែរ។ ដូចនេះ ក្រោមការគាំពាររបស់ច្បាប់ ស្ត្រីមានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសពាណិជ្ជកិច្ចជាមុខរបររបស់ខ្លួនដរាបណានាងបានបំពេញតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ដើម្បីក្លាយជាពាណិជ្ជករ ហើយគោរព និងអនុវត្តបាននូវសិទ្ធិ និងកាតព្វកិច្ចក្នុងនាមជាពាណិជ្ជករមួយរូប។ ដើម្បីជាតឹកតាងក្នុងការគាំទ្រថាតើស្ត្រីដែលពុំទាន់រៀបការម្នាក់អាចធ្វើប្រតិបត្តិការសកម្មភាពពាណិជ្ជកម្មរបស់ខ្លួនបានយ៉ាងដូចម្ដេចនោះ យើងត្រូវក្រឡេកមើលបទបញ្ញត្តិដែលកំណត់ដោយច្បាប់ដូចជាច្បាប់ស្ដីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រមទាំងច្បាប់ដែលពាក់ព័ន្ធសំខាន់ផ្សេងៗទៀត។ សូម្បីតែរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងថាប្រទេសកម្ពុជាប្រកាន់យកសេដ្ឋកិច្ចទីផ្សារដែរ[1] មានន័យថាបុគ្គលណាក៏អាចបំពេញលក្ខណ្ឌជាពាណិជ្ជករដើម្បីចូលរួមរួមក្នុងសេដ្ឋកិច្ចទីផ្សារនេះដែរ។ ការធ្វើពាណិជ្ជកម្មរបស់ស្ត្រីមិនទាន់រៀបការ គឺដូចតែបុគ្គលទូទៅ ពោលគឺដូចរូបវន្តបុគ្គលជាបុរសដែរ ដោយសារពាណិជ្ជករ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយយកពាណិជ្ជកិច្ចនេះជាមុខរបរខ្លួនជាប្រចាំ[2]។ គួរបញ្ជាក់ថា ស្ត្រីមិនទាន់រៀបការ ពុំមានភាពស្មុគស្មាញក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់ចាត់ចែងក្នុងដំណើរការពាណិជ្ជកម្មទេ ព្រោះមិនមានស្វាមីដែលជាហេតុនៃការជ្រើសរើសរបបទ្រព្យសម្បត្តិ។

## ១.១ លក្ខខណ្ឌគតិយុត្តដើម្បីក្លាយជាពាណិជ្ជកររបស់ស្ត្រីមិនទាន់រៀបការ

### ១.១.១ សមត្ថភាពបំពេញពាណិជ្ជកិច្ច

រូបវន្តបុគ្គលដែលមានសមត្ថភាពអាចបំពេញពាណិជ្ជកិច្ចបាន លុះណាតែមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ឬអនីតិជនដែលទទួលបានអត្តាធីនភាព ហើយមានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះសកម្មភាព និងគ្រប់អំពើដែលខ្លួនបានប្រព្រឹត្ត[3]។ ដូចនេះ សមត្ថភាពគឺជាលក្ខណៈរបស់បុគ្គលមួយរូបដែលជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច ហើយអាចពិចារណាសកម្មភាពរបស់ខ្លួនទៅតាមផ្លូវច្បាប់។ មុននឹងស្វែងយល់ពីសមត្ថភាពដើម្បីបំពេញពាណិជ្ជកិច្ចយ៉ាងណាទៀតនោះ យើងគប្បីដឹងថា ពាណិជ្ជកិច្ចជាអ្វីជាមុនសិន។ ពាណិជ្ជកិច្ច ជាសកម្មភាពទិញ លក់ទំនិញ ឬសេវាដែល

[1] មាត្រា៥៦ វាក្យខ័ណ្ឌ១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)
[2] មាត្រា១ វាក្យខ័ណ្ឌ១ ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)
[3] មាត្រា១៧ និង២១ ក្រមរដ្ឋប្បវេណី (២០០៧)

ត្រូវបានអនុវត្តជាប្រចាំ ក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកចំណេញ[4]។ ពុំចាត់ទុកជាពាណិជ្ជកិច្ចទេ ប្រសិនបើគ្រាន់តែធ្វើសកម្មភាពយូរៗម្តង។ យោងតាមច្បាប់ស្តីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម តាមយុទ្ធសាស្ត្រ និងតាមប្រពៃណី ពាណិជ្ជកិច្ច ត្រូវបានបែងចែកដូចជា ពាណិជ្ជកិច្ចតាមលក្ខណៈ ឬតាមកម្មវត្ថុនៃកិច្ច ពាណិជ្ជកិច្ចតាមទម្រង់ ឬតាមកំណត់របស់យុទ្ធសាស្ត្រ ពាណិជ្ជកិច្ចតាមលក្ខណៈបន្ទាប់បន្សំ និងកិច្ចចំរុះ។

### ១.១.១.១ ពាណិជ្ជកិច្ចតាមលក្ខណៈ ឬតាមកម្មវត្ថុ

ពាណិជ្ជកិច្ចតាមលក្ខណៈ ឬតាមកម្មវត្ថុ គឺជាពាណិជ្ជកិច្ចដែលទទួលស្គាល់ដោយរបបទូទៅនៃពាណិជ្ជកិច្ច ដែលផ្សេងពីក្រមរដ្ឋប្បវេណី ហើយគ្រប់កិច្ចការទាំងអស់ត្រូវបានធ្វើឡើងដោយពាណិជ្ជករ។ ពាណិជ្ជកិច្ចតាមលក្ខណៈ ឬតាមកម្មវត្ថុបែងចែកជា២ប្រភេទគឺ ពាណិជ្ជកិច្ចតាមលក្ខណៈជាបុគ្គល (តាមលក្ខណៈរៀងៗខ្លួន) និងពាណិជ្ជកិច្ចតាមលក្ខណៈជាសហគ្រាស។

#### ក ពាណិជ្ជកិច្ចតាមលក្ខណៈជាបុគ្គល

ពាណិជ្ជកិច្ចតាមលក្ខណៈជាបុគ្គល ជាពាណិជ្ជកិច្ចដែលបុគ្គលម្នាក់គ្រាន់តែបំពេញពាណិជ្ជកិច្ចខ្លះៗប៉ុណ្ណោះ ហើយកិច្ចទាំងនោះគឺជាពាណិជ្ជកិច្ចសម្រាប់បុគ្គលទាំងអស់ តែខ្លួនមិនបានបំពេញសកម្មភាពពាណិជ្ជកិច្ចជាមុខរបរប្រចាំថ្ងៃទេ។ តើសកម្មភាពណាខ្លះដែលអាចចាត់ទុកថាជាពាណិជ្ជកិច្ចបាន? យោងតាមច្បាប់ស្តីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ ត្រង់មាត្រា២ បានកំណត់នូវសកម្មភាពដែលអាចចាត់ទុកជាពាណិជ្ជកិច្ចដូចខាងក្រោមៈ

- **ការទិញដើម្បីលក់ទៅវិញ រាប់បញ្ចូលទាំងវិស័យចលន និងអចលនទ្រព្យៈ**

**ក្នុងគោលដៅរកប្រាក់ចំណេញ តែពេលខ្លះក៏មានការខាតបង់ វាជាសកម្មភាពមួយដែលពាណិជ្ជករទិញហើយលក់ទៅវិញ ឬធ្វើការដោះដូរ។** គេអាចចាត់ទុកសកម្មភាពនោះជាពាណិជ្ជកិច្ចនៅពេលដែលរាល់ការទិញលក់ត្រូវបានធ្វើទៅលើចលនទ្រព្យ និងអចលនទ្រព្យ។ ចលនទ្រព្យ និងអចលនទ្រព្យ យើងអាចហៅម្យ៉ាងទៀតបានថា ចលនវត្ថុ ឬអចលនវត្ថុ។ ចំពោះចលនវត្ថុ គឺបែងចែកជា២គឺ ចលនវត្ថុរូបទ្រព្យ និងចលនវត្ថុអរូបទ្រព្យ។ សកម្មភាពពាណិជ្ជកិច្ចចំពោះចលនវត្ថុរូបទ្រព្យ គឺពាណិជ្ជកម្មលក់រាយ ការទិញទំនិញនានាពីអ្នកបោះដុំ ហើយលក់ទៅវិញទាំងសភាពដើមទៅឱ្យអ្នកប្រើប្រាស់ និងសកម្មភាពឧស្សាហកម្មកែច្នៃវត្ថុធាតុដើមដែលអតិថិជនផ្តល់ឱ្យ ឬបានទិញឱ្យទៅជាផលិតផលពាក់កណ្តាលសម្រេច ឬសម្រេច ហើយលក់ទៅវិញ ដូចជា ការផលិតអាហារ

---

[4] មាត្រា១ វាក្យខណ្ឌ២ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

កំប៉ុងជាដើម។ ចំណែកឯសកម្មភាពពាណិជ្ជកិច្ចចំពោះចលនវត្ថុអរូបទ្រព្យ គឺពាណិជ្ជកម្មដែលមានប្រតិបត្តិការទិញលក់នូវមូលនិធិពាណិជ្ជកម្ម មូលប័ត្រ ប្រកាសនីយប័ត្រ និងបំណុលជាដើម។ ដោយឡែកសកម្មភាពពាណិជ្ជកិច្ចវិញគឺជាការទិញ ហើយលក់ទៅវិញទាំងសភាពដើម ដូចជាការទិញលក់ផ្ទះ និងដីជាដើម។

- **ប្រតិបត្តិការហិរញ្ញវត្ថុ**

**គេធ្វើការបែងចែកប្រតិបត្តិការហិរញ្ញវត្ថុជា ប្រតិបត្តិការធនាគារ និងទូទាត់រូបិយវត្ថុ និង ប្រតិបត្តិការធានារ៉ាប់រងគ្រប់គ្រងប្រភេទ។** ចំពោះប្រតិបត្តិការធនាគារ និងទូទាត់រូបិយវត្ថុ រួមមានគោលដៅសំខាន់ៗដូចជា ប្រតិបត្តិការដែលមាននៅលើរូបិយវត្ថុ លោហៈធាតុមានតម្លៃ ប្រតិបត្តិការអប្បហារិកលើឧបករណ៍ទូទាត់ពាណិជ្ជកម្ម ការផ្ញើរមូលនិធិ និងប័ណ្ណ ការខ្ចីប្រាក់ និងការផ្តល់ឥណទាន សម្រាប់ប្រតិបត្តិការធនាគារ និង ការទូទាត់ដោយផ្ទាល់ដៃពីរូបិយវត្ថុមួយទៅរូបិយវត្ថុមួយទៀត ការទូទាត់ធ្វើឡើងពីភាគីបង្គាប់ទៅភាគីទទួលបង្គាប់ក្នុងទំនាក់ទំនងរូបិយាណត្តិ ហើយបុគ្គលដែលបានសន្យាជាមួយបុគ្គលម្នាក់ទៀត តាមមធ្យោបាយផ្តល់ប្រាក់លាភការដែលបង់ប្រាក់តាមទំហំទឹកប្រាក់ដែលបានកំណត់ពីកន្លែងមួយទៅកន្លែងមួយទៀត និងប្រតិបត្តិការលើប្រាក់ និងឥណទានទៅតាមលក្ខខណ្ឌដែលត្រូវធ្វើជាមួយមូលធនអ្នកដទៃ និងតាមប័ណ្ណវិជ្ជាជីវៈ។ នេះបើយោងតាមមាត្រា២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឆ្នាំ១៩៩៩។ ចំណែកឯប្រតិបត្តិការធានារ៉ាប់រងវិញត្រូវបានចាត់ទុកថាជាពាណិជ្ជកិច្ចដោយមាន ប្រតិបត្តិការធានារ៉ាប់រងគ្រប់ប្រភេទតាមតម្លៃកំណត់ ដូចជាធានារ៉ាប់រងជិវិត មរណភាព គ្រោះអគ្គីភ័យ និងការទទួលខុសត្រូវផ្សេងៗ ប្រតិបត្តិការធានារ៉ាប់រងតាមផ្លូវគោក តាមផ្លូវទឹកដែលចំណុចនេះឆ្លុះបញ្ចាំងថាជាប្រតិបត្តិការធានារ៉ាប់រង។ ប្រតិបត្តិការធានារ៉ាប់រងគឺជាសកម្មភាពដែលទាញយកប្រាក់ចំណេញពីអតិថិជន ហើយផ្តល់ការផ្គត់ផ្គង់សេវាទៅអតិថិជននៅពេលដែលអតិថិជនមានបញ្ហា។ ការធានារ៉ាប់រងគឺជាការធ្វើកិច្ចសន្យាពាណិជ្ជកម្មធានារ៉ាប់រងមួយដែលក្នុងនោះអតិថិជនត្រូវបង់ប្រាក់បុព្វលាភ ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិដែលបង្កដោយគ្រោះថ្នាក់ ឬធ្វើសំណងនៅពេលដែលអតិថិជនរងរបួស ស្លាប់ ពិការ ឬមានជម្ងឺ ឬដល់ដំណាក់កាលព្រមព្រៀងគ្នាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង[5]។

[5] មាត្រា៣ ច្បាប់ស្តីពីធានារ៉ាប់រង (២០០០)

➢ **ប្រតិបត្តិការអន្តរី និងការផ្តល់សេវាជាអន្តរការី**

**ត្រូវបានបែងចែកជា ការផ្តល់សេវាជាអន្តរការី ការផ្តល់សេវាទីភ្នាក់ងារ និងការិយាល័យសម្រួលកិច្ចការ។** ការផ្តល់សេវាជាអន្តរការី ជាសកម្មភាពដែលធ្វើឡើងដោយក្រុមវិជ្ជាជីវៈដែលមានតួនាទីជាអ្នកនាំការរវាងបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ហើយជាអ្នកតំណាងដែលធ្វើឱ្យខិតជិតចូលគ្នា។ ប៉ុន្តែក្រុមនេះមិនលក់ទំនិញ និងមិនផលិតទំនិញ ឬធ្វើកិច្ចសន្យាដោយខ្លួនឯង និងនាមខ្លួនឯងទេ។ អន្តរការីនេះតម្រូវឱ្យមានអត្តសញ្ញាណប័ណ្ណវិជ្ជាជីវៈ និងចុះនិទ្ទេសប្រតិបត្តិការដែលខ្លួនត្រូវបំពេញ ព្រមទាំងមានលក្ខខណ្ឌធានារ៉ាប់រងហិរញ្ញវត្ថុ និងសីលធម៌។ ឯការផ្តល់សាវាភ្នាក់ងារ គឺជាភ្នាក់ងារវិជ្ជាជីវៈដែលចាត់ចែងលើកិច្ចការអ្នកដទៃតាមរបៀបវិជ្ជាជីវៈដូចជា ការិយាល័យទទួលរឿងវិវាទ ភ្នាក់ងារព័ត៌មាន ភ្នាក់ងារធ្វើដំណើរ និងទស្សនីយភាពល្ខោន និងភ្នាក់ងារផ្សព្វផ្សាយសាធារណៈជាដើម។ ចំណែកឯការិយាល័យសម្រួលកិច្ចការវិញ គឺជាប្រភេទបន្ទប់ដាក់វត្ថុគ្រប់យ៉ាង ដែលអាចអនុញ្ញាតឲ្យថៅក្រមសន្មតថាជាពាណិជ្ជកិច្ចតាមស្ថានភាពជាច្រើន នៅពេលទំនាក់ទំនងពាណិជ្ជកម្មមានលក្ខណៈល្អិតល្អន់ ដូចជាការិយាល័យទទួលរឿងវិវាទបណ្ណាធិការអចលនវត្ថុ និងការិយាល័យពង្សាវិទូ ហើយពេលខ្លះជាកន្លែងផ្តល់ដំបូន្មានក្នុងការបង្កើតកិច្ចសន្យា និងមានអ្នកតំណាងណែនាំរឿងក្តីនៅតុលាការ។[6]

➢ **ការផ្តល់សេវាវប្បធម៌ និងអាជីវកម្មទស្សនីយភាពសាធារណៈ**

គឺជាសកម្មភាពរៀបចំសេវាកម្មខ្សែភាពយន្ត សាលតូរ្យន្ត្រី និងការធ្វើអាជីវកម្មល្ខាងកំផ្ទ ធម្មជាតិ ព្រមទាំងការរៀបចំក្លិបវិជ្ជាជីវៈកីឡា បាល់ទាត់ ប្រដាល់និងការធ្វើអាជីវកម្មបន្ទប់ធ្វើសន្និសិទ្ធមានលក្ខណៈជាពាណិជ្ជកិច្ច ដែលមានប្រភពផ្តល់ប្រាក់ចំណេញ។[7]

➢ **អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើ និងរ៉ែ**

អាជីវកម្មនេសាទ រួមមានគ្រប់សកម្មភាពនេសាទជាមុខរបរតាមនាវា ហើយមានប្រយោជន៍សម្រាប់ការធ្វើពាណិជ្ជកម្មផលិតផលសមុទ្រ។ ទៀតសោធ ការធ្វើអាជីវកម្មសមុទ្រនេះ គឺប្រើប្រាស់នូវឧបករណ៍ទំនើប តាមបែបបច្ចេកទេសវិទ្យាសាស្ត្រ ដែលនាំឱ្យទិន្នផលបានហួសពីសេចក្តីត្រូវការរបស់ខ្លួន។ អាជីវកម្មនេសាទក៏មានការព្រមព្រៀង និងកិច្ចសន្យាសម្រាប់ជួលកម្មករដែលទទួលប្រាក់បៀវត្ស និងការជួលឧបករណ៍ប្រើប្រាស់តាមសមុទ្រផងដែរ ហើយគ្រប់ការព្រមព្រៀងសម្រេចដោយមនុស្សក្នុងដែនសមុទ្រ សម្រាប់សេវាអគារពាណិជ្ជកម្ម។ សូមបញ្ជាក់ថា ការនេសាទដែលធ្វើ

[6] គង់ សាផន, *នីតិពាណិជ្ជកម្ម*, បោះពុម្ព ២០១២, ទំព័រ២៦ និង២៧

ជាលក្ខណៈគ្រួសារ ដោយប្រើប្រាស់នូវឧបករណ៍បុរាណ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការប្រចាំថ្ងៃ មិនរាប់ចូលជាសកម្មភាពពាណិជ្ជកិច្ចទេ ព្រោះវាជាកិច្ចស៊ីវិល។

អាជីវកម្មព្រៃឈើ និងរ៉ែ ជាប្រភេទអាជីវកម្មមួយដែលមានលក្ខណៈយូរអង្វែង ដែលមានសកម្មភាពផ្លាស់ប្តូរផលិតកម្មដូចជា ការដាំដើមទំពាំងបាយជូរ (Fraise)ដើម្បីធ្វើជាស្រាទំពាំងបាយជូរ និងធ្វើជាដំណាប់ ការដាំដើមឈើ រួចកាប់ច្នៃទៅជាក្តារបន្ទះ ឬគ្រឿងសង្ហារឹមនានា និងការកៀបជ័រពីដើមកៅស៊ូជាដើម។ លើសពីនេះ មានសកម្មភាពជួយគាំទ្រដល់ការធ្វើអាជីវកម្មដូចជា ការបោះជំរុំនៅកសិដ្ឋាន សកម្មភាពជួយដល់ទេសចរណ៍ និងធ្វើជំរកនៅទីជនបទ។ ឯប្រភេទរ៉ែផ្សេងៗត្រូវបានធ្វើអាជីវកម្មដោយប្រើប្រាស់បច្ចេកទេសទំនើបៗតាមបែបឧស្សាហកម្មវិទ្យាសាស្ត្រ រួមមានរ៉ែមាស រ៉ែដែក រ៉ែប្រេងកាតជាដើម។

## ខ ពាណិជ្ជកិច្ចតាមលក្ខណៈជាសហគ្រាស

ជាស្ពានចម្លងក្នុងការស្វែងយល់អំពីខ្លឹមសារនៃ ពាណិជ្ជកម្មតាមលក្ខណៈជាសហគ្រាស យើងគប្បីយល់ពីសហគ្រាសជាអ្វីសិន។ សហគ្រាសគឺជាគ្រឹះស្ថានសេដ្ឋកិច្ចដែលបញ្ចូលទាំងធនធានមនុស្ស មធ្យោបាយ និងសំភារៈផលិតកម្ម ឬមធ្យោបាយនៃការរីកចម្រើន ការមានបាន ឬការចាត់ចែងគម្រោងផែនការរៀបចំទុកជាមុន។[8] វាគឺជាគ្រប់អង្គការវិជ្ជាជីវៈដែលបានចាត់ចែងសំភារៈ និងបុគ្គលដែលមានគុណភាពដើម្បីអនុញ្ញាតឱ្យអនុវត្តតាមរបៀបមួយស្ថិតស្ថេរ និងមុខរបរទៀងទាត់មួយ ដើម្បីផ្តល់ឱ្យតាមរបៀបអចិន្ត្រៃយ៍នូវសេវាដល់សារធារណៈជន។

មាត្រា២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ បានកំណត់អំពីពាណិជ្ជកម្មតាមរយៈសហគ្រាស រួមមានសហគ្រាសជួល សហគ្រាសផ្គត់ផ្គង់ សហគ្រាសការណកម្ម សហគ្រាសដឹកជញ្ជូន សហគ្រាសយកកម្រៃជើងសារ សហគ្រាសសំណង់ និងសហគ្រាសបោះពុម្ពផ្សាយ។ តើសហគ្រាសទាំងនេះមានលក្ខណៈដូចម្តេចខ្លះ?

- **សហគ្រាសជួល**

សហគ្រាសជួល មានបេសកកម្មធ្វើយ៉ាងណាឱ្យសម្រេចនៅក្នុងក្របខណ្ឌសហគ្រាសពាណិជ្ជកម្មដោយការជួលចលនវត្ថុ និងអចលនវត្ថុ។ ការជួលចលនវត្ថុអាចមានដូចជាការជួលរថយន្ត រថយន្តទេសចរណ៍ ជួលម៉ាស៊ីនឧបករណ៍ ។ល។ តើការជួលអចលនវត្ថុជាពាណិជ្ជកិច្ច ឬជាកិច្ចស៊ីវិល? ការជួលអចលនវត្ថុអាចជាពាណិជ្ជកិច្ច និង/ឬជាកិច្ចរដ្ឋប្បវេណី។ តែវាអាស្រ័យលើ

[7] គង់ សាផន, *នីតិពាណិជ្ជកម្ម*, បោះពុម្ព ២០១២, ទំព័រ២៧

[8] គង់ សាផន, *នីតិពាណិជ្ជកម្ម*, បោះពុម្ព ២០១២, ទំព័រ២៨

សកម្មភាពនៃការជួលអចលនវត្ថុ ថាតើត្រូវបានធ្វើឡើងដោយនរណា ហើយដោយម្តេចខ្លះ។ ប្រសិនបើសកម្មភាពនៃការជួលនោះត្រូវបានធ្វើឡើងដោយបុគ្គលឯកជន នោះវាជាកិច្ចរដ្ឋប្បវេណី ព្រោះការជួលនោះគ្រាន់តែសម្រាប់តម្រូវការគ្រួសារតែប៉ុណ្ណោះ។ ប៉ុន្តែវាគឺជាសកម្មភាពពាណិជ្ជកិច្ច នៅពេលដែលវាធ្វើឡើងដោយពាណិជ្ជករ ឬដោយក្រុមហ៊ុនពាណិជ្ជកម្ម។ យ៉ាងណាមិញ យើងគួរដឹងថាការជួលអចលនវត្ថុគឺជាពាណិជ្ជកិច្ច គឺមិនស្ថិតនៅក្នុងកិច្ចរដ្ឋប្បវេណីទេ។

➢ **សហគ្រាសផ្គត់ផ្គង់**

សហគ្រាសផ្គត់ផ្គង់បែងចែកសកម្មភាពជាពីរប្រភេទគឺ ការផ្គត់ផ្គង់សំភារៈ និងការផ្គត់ផ្គង់សេវាកម្ម។ ការផ្គត់ផ្គង់សំភារៈ គឺជាការផ្តល់ជូនអតិថិជននូវវត្ថុដែលគេត្រូវការដូចជាវត្ថុវាស់បាន វត្ថុថ្លឹងបានតាមការគណនា ឬវត្ថុមានរូបរាង ដូចជាការផ្គត់ផ្គង់ទឹកស្អាតជាដើម។ ឯការផ្គត់ផ្គង់សេវាកម្ម គឺជាការបម្រើជូនអតិថិជន នូវការប្រើប្រាស់សេវាយ៉ាងណាឱ្យមានប្រសិទ្ធភាព និងជាទីគាប់ចិត្ត ដូចជាសេវារៀបចំអាពាហ៍ពិពាហ៍ជាដើម។

➢ **សហគ្រាសការណកម្ម**

យើងអាចហៅម្យ៉ាងទៀតថា សហគ្រាសកាមន្តសាល។ វាជាសហគ្រាសដែលធ្វើសកម្មភាពផ្លាស់ប្តូរទ្រង់ទ្រាយវត្ថុធាតុដើមបន្ទាប់ពីការរលាយ ឬផលិតផលដែលបានដាក់ឱ្យក្រោមការផលិតជាលើកដំបូង ដែលហៅថាសហគ្រាសឧស្សាហកម្ម។ សកម្មភាពឧស្សាហកម្មនេះធ្វើប្រតិបត្តិការលើវត្ថុធាតុដើមដែលបានទិញ ហើយលក់ទៅវិញ។ វាផ្លាស់ប្តូរវត្ថុធាតុដើមដែលផ្តល់ដោយអតិថិជន ដូចជាឧស្សាហកម្មស្លដែកជាដើម។ សហគ្រាសការណកម្មមានសកម្មភាពមួយទៀតគឺ ការជួសជុលវត្ថុ ដែលធ្វើការកាត់បន្ថយទំហំ ធ្វើឱ្យវែងឬខ្លី តូចឬធំ។ ឧទាហរណ៍ៈ កន្លែងជួសជុលរថយន្ត។

➢ **សហគ្រាសដឹកជញ្ជូន**

គឺជាសហគ្រាសដែលធ្វើប្រតិបត្តិការប្លែកៗដូចជាសកម្មភាពបម្លាស់ទីរបស់មនុស្ស ឬទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត តាមផ្លូវគោក ផ្លូវទឹក ផ្លូវដែក និងផ្លូវអាកាស។ រីឯការបម្លាស់ទីនៃទំនិញ ឬមនុស្សមិនមែនជាពាណិជ្ជកិច្ចទេ ករណីដែលម្ចាស់យានយន្តគ្រាន់តែធ្វើសកម្មភាពរកប្រាក់សម្រាប់តែជីវភាពគ្រួសារ ទោះបីខ្លួនជាម្ចាស់យានយន្ត ឬក៏ប្រព្រឹត្តិជាប្រចាំ។

➢ **សហគ្រាសយកកម្រៃជើងសារ**

មានប្រភេទប្រតិបត្តិការជាសេវាអន្តរការី សហគ្រាសនេះគឺជាអ្នកខ្ទះខ្នែងរវាងអ្នកលក់ និងអ្នកទិញដើម្បីឱ្យមានការអនុគ្រោះចំពោះការសម្រេចកិច្ចសន្យាលក់ ដែលជាអ្នកអនុវត្តកិច្ចសន្យាអាណត្តិ កិច្ចសន្យាមៅការ ហើយធ្វើប្រតិបត្តិការជាភាគីយកកម្រៃជើងសារ។ អ្នកយកកម្រៃជើង

សារធ្វើកិច្ចសន្យាក្នុងនាមខ្លួន នូវកិច្ចព្រមព្រៀងណាមួយដើម្បីជាប្រយោជន៍នៃអាណត្តិទាយក ហើយមិនបញ្ចេញឈ្មោះអាណត្តិទាយកទេ។ អ្នកយកម្រៃជើងសារ ទទួលខុសត្រូវលើកិច្ចសន្យាជាមួយតតិយជនដែលខ្លួនបានព្រមព្រៀងជាមួយ។ ក្នុងទំនាក់ទំនងជាមួយអ្នកយកកម្រៃជើងសារ និងអ្នកចុះកិច្ចសន្យាជាមួយ គ្រប់យ៉ាងត្រូវធ្វើឡើងដូចក្នុងនាមរបស់ខ្លួន។ នេះមានន័យថា អ្នកធ្វើកិច្ចសន្យាជាមួយ មិនធ្វើការប្តឹងផ្ទាល់ប្រឆាំងទៅនឹងអ្នកជួលឡើយ។ ជាមួយគ្នានេះដែរ នៅក្នុងទំនាក់ទំនងរបស់អ្នកយកកម្រៃជើងសារត្រូវតែស្ថិតនៅក្រោមវិធាន និងការគ្រប់គ្រងអាណត្តិ។ អ្នកយកកម្រៃជើងសារមានកាតព្វកិច្ចធ្វើបេសកកម្មរបស់ខ្លួនដោយស្មោះត្រង់ និងមានកាទទួលខុសត្រូវចំពោះអ្នកជួល ហើយអ្នកជួលមានកាតព្វកិច្ចចំពោះកាតព្វកិច្ចដែលបានធ្វើចំពោះខ្លួន និងត្រូវបង់ប្រាកកម្រៃជើងសារ និងសោហ៊ុយទៅអ្នកយកកម្រៃជើងសារដែលមានមធ្យោបាយជាកាតព្វកិច្ច។

➢ **សហគ្រាសសំណង់**

សកម្មភាពប្រតិបត្តិការរបស់សហគ្រាសសំណង់គឺជាពាណិជ្ជកិច្ច ដែលសហគ្រាសនេះមានបេសកកម្មសាងសង់ កសាងអគារ ផ្លូវថ្នល់ ជួសជុលអចលនវត្ថុស្នាក់នៅ និងការស្ថាបនានានា ហើយសហគ្រាសនេះយកផលចំណេញ និងកេងកម្រៃពីការបំពាក់បរិក្ខាមេកានិកលើសលប់ និងកម្លាំងការងាររបស់អ្នកដទៃ។ នេះ ដោយយោងតាមមាត្រា២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥។

➢ **សហគ្រាសបោះពុម្ពផ្សាយ**

មានកំណត់នៅក្នុងមាត្រាដដែល នៃច្បាប់ដដែល សកម្មភាពពាណិជ្ជកិច្ចរបស់សហគ្រាសបោះពុម្ពផ្សាយ គឺធ្វើសកម្មភាពឧស្សាហកម្ម ហើយប្រតិបត្តិការលើវត្ថុធាតុដើមដែលទិញពីខាងក្រៅ ឬផ្តល់ជូនពីភាគីដែឡចុះកិច្ចសន្យាជាមួយខ្លួន។ ការបោះពុម្ពផ្សាយ ត្រូវបានផលិតចេញពីស្នាដៃខាងប្រាជ្ញា។ គេទិញសំណៅពីស្នាដៃអ្នកនិពន្ធ ហើយយកទៅផលិតជាខ្សែ ឬភាគច្រើនច្បាប់រួមមាន ការផ្តិតរូបថត ថាសស៊ីឌី សារព័ត៌មាន ខ្សែភាពយន្ត ទស្សនាវដ្តី និងសេវាដទៃទៀតរបស់អ្នកបង្កើត និងសាធារណៈជន។

### ១.១.១.២ ពាណិជ្ជកិច្ចតាមលក្ខណៈបន្ទាប់បន្សំ

ឬយើងអាចហៅបានម្យ៉ាងទៀតថា ពាណិជ្ជកិច្ចតាមអត្តវិស័យ។ វាគឺជាកិច្ចស៊ិវិល ប៉ុន្តែអាចក្លាយទៅជាពាណិជ្ជកិច្ចដោយអាស្រ័យលើការប្រើប្រាស់របស់បុគ្គលដែលជាពាណិជ្ជករ ដើម្បីសម្រេចសេចក្តីត្រូវការរបស់បុគ្គលនោះ។ ពាណិជ្ជកិច្ចតាមអត្តវិស័យនេះមានលក្ខណ្ឌពីរដែលត្រូវ

បំពេញគឺ ចំពោះអ្នកបង្កើតកិច្ច និងកិច្ចធម្មតាជាស៊ីវិល។ ចំពោះអ្នកបង្កើតកិច្ច៖ ទាល់តែជាពាណិជ្ជករជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយមានសារៈសំខាន់តិចតួចណាស់ដែលភាគីម្ខាងទៀតមានគុណភាព ឬមិនមានគុណភាពជាពាណិជ្ជករ។ ចំពោះកិច្ចធម្មតាជាស៊ីវិល៖ សម្រាប់បំពេញសេចក្តីត្រូវការក្នុងសកម្មភាពពាណិជ្ជកម្មដើម (វត្ថុវិស័យ) នៃអ្នកបង្កើតដោយអនុវត្តតាមទ្រឹស្តីបន្ទាប់បន្សំ។ យើងធ្វើការវិភាគទៅលើសកម្មភាពមួយក្នុងគោលបំណងពីរខុសគ្នា ដែលជាកត្តាដែលនាំឱ្យវាមិនក្លាយ និងក្លាយជាពាណិជ្ជកិច្ច។ សកម្មភាពទិញរថយន្តរបស់ពាណិជ្ជករម្នាក់ បើគ្រាន់តែទិញសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ នោះវាមិនមែនជាពាណិជ្ជកិច្ចទេ តែជាកិច្ចស៊ីវិល។ ប៉ុន្តែ បើការទិញរថយន្តនោះយកមកប្រើប្រាស់ក្នុងសកកម្មភាពពាណិជ្ជកម្ម នោះវានឹងក្លាយជាពាណិជ្ជកិច្ច។ នេះសបញ្ជាក់ឱ្យឃើញថា រាល់សកម្មភាពទាំងឡាយដែលអនុវត្តដោយពាណិជ្ជករ ត្រូវបានសន្មតថាយ៉ាងជាក់ច្បាស់ថាជាពាណិជ្ជកិច្ច[9]។ ដោយសារតែសកម្មភាពមួយចំនួនអាចជាសកម្មភាពពាណិជ្ជកិច្ចនោះមិនមានការស្មុគស្មាញក្នុងការកំណត់ថាវាស្ថិតនៅក្រោមរបបគតិយុត្តមួយណាទេ។ វាស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្ម។ ប៉ុន្តែ ប្រសិនបើវាជាកិច្ចស៊ីវិលដែលអនុវត្តដោយពាណិជ្ជករដើម្បីបំពេញតម្រូវការរបស់ខ្លួន នោះវានឹងក្លាយជាពាណិជ្ជកិច្ច ដោយគិតទាំងសកម្មភាពនៃកិច្ចសន្យា និងក្រៅកិច្ចសន្យា លើកលែងតែមានភស្តុតាងផ្ទុយបញ្ជាក់ថាកិច្ចស៊ីវិលនោះមិនមែនជាពាណិជ្ជកិច្ចតាមលក្ខណៈបន្ទាប់បន្សំ។

**១.១.១.៣ ពាណិជ្ជកិច្ចតាមទម្រង់**

ពាណិជ្ជកិច្ចតាមទម្រង់ គឺជាកិច្ចដែលត្រូវផ្ទេរ ឬប្រគល់ទៅឱ្យបុគ្គលអ្នកបង្កើតកិច្ចនូវលក្ខណៈសម្បត្តិជាពាណិជ្ជកិច្ច ទោះបីជាកម្មវត្ថុរបស់វាជារដ្ឋប្បវេណី ឬជាពាណិជ្ជកម្មក៏ដោយ ហើយបុគ្គលដែលចូលរួមក្នុងកិច្ចការនោះជាអ្វីក៏ដោយ មិនថាជាពាណិជ្ជករ កម្មករ ឬកសិករទេ។[10]




ដែលយើងអាចហៅពាណិជ្ជកិច្ចតាមទម្រង់នេះបានម្យ៉ាងទៀតថា ពាណិជ្ជកិច្ចតាមការកំណត់ដោយយុត្តិសាស្ត្រ ព្រោះវាពុំមានចែងនៅក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ ទេ។ ពាណិជ្ជកិច្ចតាមទម្រង់នេះផងដែរ យុត្តិសាស្ត្របានវាយតម្លៃជាលក្ខណៈពាណិជ្ជកម្មចំពោះប្រតិបត្តិការមួយចំនួនដូចជា ប្រតិបត្តិការរូបិយាណត្តិ និងកិច្ចដែលធ្វើឡើងដោយ

[9] មាត្រា៨ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

ក្រុមហ៊ុនពាណិជ្ជកម្មតាមទម្រង់។ ចំពោះប្រតិបត្តិការរូបិយាណត្តិ វាមានលក្ខណៈជាពាណិជ្ជកិច្ចតាមទម្រង់ ព្រោះវាត្រូវបានផ្តើមចេញពីភាគីបង្គាប់ទៅកាន់ភាគីទទួលបង្គាប់ឱ្យសងប្រាក់ ទៅភាគីមួយទៀតដែលហៅថា ភាគីទទួលកម្រៃ។ ឯចំពោះកិច្ចដែលធ្វើឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មតាមទម្រង់វិញ គឺយុត្តិសាស្ត្របានឱ្យដំណោះស្រាយជាស្ថាពរ ដល់គ្រប់ប្រតិបត្តិការទាំងអស់របស់ក្រុមហ៊ុនពាណិជ្ជកម្ម។ ដំណោះស្រាយទាំងអស់នោះ រួមមានដូចតទៅ៖ តាមទម្រង់គតិយុត្ត វាបានអនុញ្ញាតឱ្យក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់បំពេញកិច្ចទៅតាមកម្មវត្ថុដែលមានចែងនៅក្នុង លក្ខន្តិកៈរបស់ក្រុមហ៊ុនទាំងនោះ ការចុះឈ្មោះចូលហ៊ុន ហើយឈានដល់ការផ្សាយចេញភាគហ៊ុន ត្រូវចាត់ទុកថាជាពាណិជ្ជកិច្ចតាមទម្រង់ ទោះបីបុគ្គលនោះជាពាណិជ្ជករ ឬមិនមែនជាពាណិជ្ជករក៏ដោយ ការលក់ភាគហ៊ុនរបស់សមាជិកគឺជាកិច្ចស៊ីវិល តែការលក់ភាគហ៊ុនទៅឱ្យអ្នកខាងក្រៅដោយមានការត្រួតពិនិត្យពីក្រុមហ៊ុន និងមានការសុំការអនុញ្ញាតពីសមាជិកហ៊ុនមតិភាគច្រើន គឺជាពាណិជ្ជកិច្ចតាមទម្រង់, ការសន្យាទិញយកមកវិញនូវសិទ្ធិក្រុមហ៊ុន វាយតម្លៃដោយកិច្ចព្រមព្រៀងដែលបានធានារ៉ាប់រងនូវការត្រួតពិនិត្យដោយក្រុមហ៊ុន និងការធានារ៉ាប់រងរបស់បណ្ណាធិការ ឬស្ថាបនិកដើម ចំពោះប្រាក់បំណុលរបស់ក្រុមហ៊ុន ក៏ជាពាណិជ្ជកិច្ចតាមទម្រង់ដែរ។[11]

**១.១.១.៤ កិច្ចចំរុះ**

មានភាគីពីរនៅក្នុងប្រតិបត្តិការកិច្ចចំរុៈ គឺម្ខាងជាពាណិជ្ជករ ហើយម្ខាងទៀតមិនមែនជាពាណិជ្ជករ ឬជាបុគ្គលធម្មតា។ ភាគីជាពាណិជ្ជករធ្វើសកម្មភាពពាណិជ្ជកម្មជាមួយនិងបុគ្គលធម្មតាដែលធ្វើសកម្មភាពស៊ីវិល។ នៅក្នុងកិច្ចចំរុះនេះ ភាគីទាំងសងខាងទទួលរងវិធានខុសគ្នា ដោយភាគីម្ខាងទទួលរងវិធានពាណិជ្ជកម្ម ឯម្ខាងទៀតទទួលរងវិធានរដ្ឋប្បវេណី។ នៅពេលមានវិវាទកើតឡើង សមត្ថកិច្ចតុលាការគឺអាស្រ័យទៅលើចុងចម្លើយ។ តើតុលាការណាទើបមានសមត្ថកិច្ច? កាលណាចុងចម្លើយជាពាណិជ្ជករ ហើយដើមចោទមិនមែនជាពាណិជ្ជករ នោះដើមចោទមានសិទ្ធិជ្រើសរើសតុលាការពាណិជ្ជកម្មក៏បាន តុលាការរដ្ឋប្បវេណីក៏បាន។ ប៉ុន្តែ ប្រសិនបើចុងចម្លើយមិនមែនជាពាណិជ្ជករ ហើយដើមចោទជាពាណិជ្ជករ នោះដើមចោទត្រូវប្តឹងទៅតុលាការរដ្ឋប្បវេណីដែលក្នុងករណីនេះមិនបានធ្វើឱ្យដើមចោទមានជម្រើសជ្រើសរើសតុលាការទេ។ ទន្ទឹមនឹងនេះ ត្រង់មាត្រា៤៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់រយៈពីរឆ្នាំ ជារយៈពេលដែលភាគីទាំងសងខាងចាំបាច់ត្រូវអនុវត្តអាជ្ញាយុកាលចំពោះសិទ្ធិលើបំណុល។

---

[10] សំ បូណែល, *ច្បាប់ពាណិជ្ជកម្មកម្ពុជា* , បោះពុម្ព ២០១៥, ទំព័រ២០

[11] គង់ សាផន, *នីតិពាណិជ្ជកម្ម* , បោះពុម្ព ២០១២, ទំព័រ៣១ និង៣២

### ១.១.១.៥ អនីតិជន និងនីតិជនជាពាណិជ្ជករ

តើអនីតិជនជានរណា? យោងតាមមាត្រា១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ជាក់ថា អនីតិជន សំដៅទៅលើជនដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ។ ដោយឡែក មាត្រា៧ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ បានចែងថា អនីតិជនមិនអាចក្លាយជាពាណិជ្ជករបានទេ លើកលែងតែអនីតិជននោះរួចផុតពីអាណាព្យាបាល។ នេះសបញ្ជាក់យ៉ាងច្បាស់ថា ទាល់តែជានីតិជនទើបមានសិទ្ធិធ្វើជា ពាណិជ្ជករដែលមានសមត្ថភាពពេញលេញក្នុងការប្រកបអាជីវកម្មរបស់ខ្លួន ដូចមានពន្លេចនៅក្នុងមាត្រា២០ វក្យខណ្ឌ១ នៃក្រោមរដ្ឋប្បវេណីឆ្នាំ២០០៧។ ប្រសិនបើអនីតិជនធ្វើការដឹកនាំពាណិជ្ជកិច្ច នោះវាអាចនឹងប្រឈមមុខនឹងហានិភ័យជាច្រើន ដូចជាការក្ស័យធនជាដើម។ ការដែលច្បាប់កំណត់មិនឱ្យអនីតិជនអាចក្លាយជាពាណិជ្ជករបានព្រោះក្រុមនេះពុំមានសមត្ថភាពគ្រប់គ្រាន់ទេ ដោយត្រូវបានកំណត់អាយុ និងសន្និដ្ឋានថាខ្វះការពិចារណា ខ្វះការគួរបានល្អិតល្អន់ក្នុងការគ្រប់គ្រងដំណើរការអាជីវកម្មរបស់ខ្លួន។ ផ្ទុយមកវិញ ក៏នៅតែមានករណីលើកលែងដែលអតិថិជនអាចក្លាយជាពាណិជ្ជករបានដែរ។ នោះគឺ តាមរយៈ**អត្តាធីនភាព**។

ជាគោលការណ៍ទូទៅ ទោះបីជាអនីតិជនត្រូវបានបដិសេដដោយច្បាប់ ដែលមិនអនុញ្ញាតឱ្យក្លាយជាពាណិជ្ជករក៏ដោយ ក៏ច្បាប់នៅមានអញ្ញត្រកម្មមួយដែលធ្វើឱ្យអនីតិជនមានឱកាសក្លាយជាពាណិជ្ជករបាន។ អញ្ញត្រកម្មនោះគឺ អត្តាធីនភាព។ ការទទួលបានអត្តាធីនភាព គឺជាស្ថានភាពដែលអនីតិជនអាចរួចផុតពីអាណាព្យាបាល ឬអំណាចមេបា។ នៅពេលដែលអនីតិជនបានរួចផុតពីស្ថានភាពនេះ អនីតិជនអាចមានសមត្ថភាពដូចជានីតិជនទូទៅដែរ។ តើមានលក្ខខណ្ឌអ្វីខ្លះដែលត្រូវបានកំណត់ដើម្បីទទួលបានអត្តាធីនភាព[12]?

ដើម្បីទទួលបាននូវអត្តាធីនភាព អនីតិជនត្រូវគោរពនូវលក្ខខណ្ឌដូចខាងក្រោម៖

- ✓ ក្នុងករណីដែលអនីតិជនដែលមានអាយុដល់១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនៅអត្តាធីនភាពរបស់អនីតិជននោះបានតាមពាក្យសុំរបស់គេ ប្រសិនបើតុលាការយល់ឃើញថាអត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ដែលតុលាការត្រូវសួរយោបល់អ្នកមានសិទ្ធិអំណាចមេបា។

[12] មាត្រា២១ ក្រមរដ្ឋប្បវេណី (២០០៧)

- ✓ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាពដោយពុំចាំបាច់មានការប្រកាសពីតុលាការឡើយ។ ទោះបីជាលែងលះគ្នាក្រោយរៀបអាពាហ៍ពីពាហ៍ក៏ដោយ ក៏អនីតិជនមិនត្រូវបាត់បង់អត្តាធីនភាពឡើយ។

ក្រោយពីទទួលបានអត្តាធីនភាព អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាព[13]។ ដរាបណាបានដល់នីតិភាព អនីតិជនអាចមានសិទ្ធិប្រកបរបរអាជីវកម្មដូចជានីតិជនដទៃទៀតដែរ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏ការនៅតែមានភាពលំបាកដល់អនីតិជននោះដែរ ព្រោះរឿងពាណិជ្ជកម្មជារឿងដែលមានភាពស្មុគស្មាញ។ យ៉ាងណាមិញ ប្រសិនបើអនីតិជននោះធ្លាប់មានបទពិសោធន៍ខ្លះៗ អាចយល់ដឹង ដោយសារតែកើតក្នុងគ្រួសារពាណិជ្ជករ ឬធ្លាប់បានធ្វើការដោយស្ម័គ្រចិត្តនានាទាក់ទងនឹងពាណិជ្ជកម្ម ឬជាចំណង់ចំណូលចិត្ត នោះវាជាការប្រសើរ។

នីតិជនដែលមានវិបត្តិខាងស្មារតី ឬបុគ្គលដែលពិការអវៈយវៈណាមួយត្រូវបានច្បាប់ជួយគាំពារឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងក្រោមរបបហិតូបត្ថម្ភកៈ ករណីដែលនីតិជននោះត្រូវបានចាត់ថ្នាក់ទៅតាមស្ថានភាពទម្ងន់។ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈ មិនអាចជាពាណិជ្ជករបានទេ។ ប្រសិនបើគេជាពាណិជ្ជករមុខការដែលត្រូវបានប្រកាសឲ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬហិតូបត្ថម្ភកៈ គេត្រូវធ្វើការប្រកាសជាសាធារណៈ ជូនដំណឹងដល់សាធារណៈជនថាមានសាលក្រមប្រកាសដាក់ឱ្យស្ថិតនៅក្រោមរបបទាំងនេះ ហើយត្រូវចុះនិទ្ទេសក្នុងសៀវភៅបញ្ជីពាណិជ្ជកម្ម។[14]

### ១.១.២ យកពាណិជ្ជកិច្ចជាមុខរបរប្រចាំខ្លួន

ដូចដែលបានជ្រាបរួចមកហើយថា ប្រសិនបើគ្រាន់តែបុគ្គលម្នាក់ធ្វើសកម្មភាពទិញ លក់ម្តងម្កាល នោះមិនអាចចាត់ទុកថាជាពាណិជ្ជកិច្ចបានទេ។ ដូចនេះ ដើម្បីបំពេញឱ្យគ្រប់លក្ខខណ្ឌការធ្វើសកម្មភាពជាប្រចាំគឺជាចំណែកមួយយ៉ាងសំខាន់។ បន្ទាប់ពីបានចុះបញ្ជីពាណិជ្ជកម្ម ហើយទទួលបានលក្ខណៈសម្បត្តិជាពាណិជ្ជកររួចហើយ ពាណិជ្ជករត្រូវប្រាកដថាខ្លួនធ្វើប្រតិបត្តិការជាមុខរបរប្រចាំ ពោលគឺ ត្រូវធ្វើឱ្យទៀងទាត់ និងឯករាជ្យ ហើយសកម្មភាពនោះបានផ្តល់ចំណូលដល់ខ្លួន។ មានចែងនៅក្នុងមាត្រា១ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម គឺការប្រតិបត្តិជាប្រចាំនេះបានផ្តល់លក្ខណៈឱ្យក្លាយជាពាណិជ្ជករ។ ដូច្នេះ ពាណិជ្ជករត្រូវធ្វើការងារពិតប្រាកដដដែលៗ ច្រំដែលៗ ឥតប្រែប្រួល ហើយមុខរបរដែលខ្លួនប្រកបនោះមិនស្ថិតនៅក្រោមការគ្រប់គ្រង

[13] មាត្រា២២ ក្រមរដ្ឋប្បវេណី (២០០៧)

[14] សំ បូណែល, *ច្បាប់ពាណិជ្ជកម្មកម្ពុជា*, បោះពុម្ព ២០១៥, ទំព័រ២៥

របស់បុគ្គលណាម្នាក់ឡើយ។ ជារួមគឺ មុខរបរជាប្រចាំត្រូវវាយតម្លៃថាមានធាតុផ្សំពីរគឺ តាមទម្លាប់ និងតាមស្ថានភាព។

### ១.១.៣ ចាត់ចែងសកម្មភាពក្នុងនាមខ្លួន និងប្រយោជន៍ខ្លួន

ដោសារតែវិសាលភាពនៃប្រធានបទនេះ គឺនិយាយពីស្ត្រីជាពាណិជ្ជកររូបវន្តបុគ្គល យើងនឹងធ្វើការសិក្សាក្នុងចំណុចនេះតែអំពីពាណិជ្ជករជារូបវន្តបុគ្គលតែប៉ុណ្ណោះ។

ពាណិជ្ជករអនុវត្តពាណិជ្ជកិច្ចរបស់ខ្លួន ក្នុងនាមខ្លួន គឺមានលក្ខណៈឯករាជ្យ ហើយត្រូវទទួលរងនូវការទទួលខាតបង់ពីសកម្មភាពមុខរបរជាប្រចាំ។ រាល់ចំណូល និងចំណាយត្រូវស្ថិតនៅក្រោមការចាត់ចែង និងការគ្រប់គ្រងរបស់ខ្លួន ក្នុងគោលបំណងដើម្បីប្រយោជន៍តែមួយរបស់ខ្លួន ហើយត្រូចបានទទួលស្គាល់ក្នុងនាមពាណិជ្ជករ។

ការចាត់ចែងសកម្មភាពក្នុងនាមខ្លួន និងប្រយោជន៍ខ្លួនមានការផ្ដាច់ចេញនូវលក្ខខណ្ឌខាងក្រោមនេះ៖

- ✓ កម្មកររបស់ពាណិជ្ជករដែលធ្វើពាណិជ្ជកិច្ច សម្រាប់គណនីនិយោជក និងត្រូវចំណុះនិយោជកដោយកិច្ចសន្យាការងារ ហើយមិនធានានូវការខាតបង់របស់សហគ្រាសទេ។
- ✓ អន្តរការីដែលចាត់ចែងគណនីពាណិជ្ជករ លើកលែងតែភាគីយកកម្រៃជើងសារ ភាគីជំនួញជើងសារ និងការិយាល័យសម្របសម្រួលកិច្ចការដែលកំណត់ដោយមាត្រា២ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥។ អន្តរការីមានដូចខាងក្រោម: អ្នកដំណើរ អ្នកតំណាង អ្នករៀបចំកន្លែងពាណិជ្ជកម្ម ភ្នាក់ងារពាណិជ្ជកម្ម សម្បទានិក អ្នកទិញមូលនិធិពាណិជ្ជកម្ម អភិបាលមូលនិធិពាណិជ្ជកម្ម និងអភិបាលសេរី។[15]

## ១.២ សិទ្ធិរបស់ពាណិជ្ជករជាស្ត្រីមិនទាន់រៀបការ

ក្រោយពីពិភពលោកបានឆ្លងកាត់នូវមហន្តរាយនានាជាច្រើន បានធ្វើឱ្យមានការរើបម្រាស់ ហើយស្វែងរកវិធីទប់ស្កាត់កុំឱ្យកើតមានឡើងទៀត ហើយជាពិសេសដើម្បីលើកតម្កើងជនរងគ្រោះដែលភាគច្រើននៃជនរងគ្រោះគឺស្ត្រី និងកុមារ។ នេះមិនត្រឹមតែជួយឱ្យស្ត្រីត្រូវបានលើកតម្កើងទេ តែក៏បានជួយឱ្យស្ត្រីក្រោកចេញពីប្រពៃណីសង្គមបុរាណដែលបានគៀបសង្កត់ពួកគេ។ តាមរយៈនេះ នាំឱ្យមានការបង្កើតនូវលិខិតតូបករណ៍អន្តរជាតិនានាដោយអង្គការសហប្រជាជាតិ ដើម្បីយកមកទ្រទ្រង់ ការពារសិទ្ធិស្ត្រីរួមមាន សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨

[15] គង់ សាផន, *នីតិពាណិជ្ជកម្ម*, បោះពុម្ព ២០១២ ទំព័រ៧១

មាត្រា ២៣ មនុស្សគ្រប់រូបមានសិទ្ធិធ្វើការ ជ្រើសរើសការងារដោយសេរី....មាត្រាផ្សេងៗទៀត) កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឆ្នាំ១៩៦៦[16] អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ឆ្នាំ១៩៨១[17] ជាដើម ដែលវាបានបញ្ញត្តិឡើងដើម្បីការពារនិងលើកកម្ពស់ស្ត្រីធ្វើយ៉ាងណាឲ្យមានសិទ្ធិស្មើរគ្នា ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម ការងារជាដើម។ ដោយឡែក ប្រទេសកម្ពុជាក៏បានចូលរួមចំណែកក្នុងកិច្ចការនេះដែរ គឺតាមរយៈរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់ខ្លួនដែលមានចែងនៅត្រង់មាត្រា៣៥ និង៣៦។ លើសពីនេះ ត្រង់មាត្រា៩៥ និង ៩៦ក៏បានលុបចោលរាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងការធ្វើអាជីវកម្មនានាលើស្ត្រីផងដែរ។ ជាពិសេសមាត្រានេះបានបញ្ជាក់ថាស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាចំពោះអាពាហ៍ពិពាហ៍ និងគ្រួសារ ហើយស្ត្រីមិនត្រូវបានបញ្ឈប់ពីការងារទេនៅពេលមាន មាតុភាព ទទួលបានប្រាក់បៀវត្ស រក្សាអតីតភាពការងារ និងទទួលផលផ្សេងៗខាងសង្គមកិច្ច។ ប្រទេសកម្ពុជាក៏បានបញ្ជាក់អំពីការលើកកម្ពស់ស្ត្រីផងដែរ គឺថាស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ[18]។ ដូចបានលើកឡើងជាញឹកញាប់ខាងលើរួចមកហើយ ថាស្ត្រីត្រូវបានលើកតម្កើង ដែលនេះគឺដោយសារតែសង្កេតឃើញថាសិទ្ធិស្ត្រីមានការរីកចម្រើនយ៉ាងខ្លាំង ខណៈពេលដែលស្ត្រីត្រូវបានលើកស្ទួតឱ្យចូលរួមទៅក្នុងវិស័យនានាដូចជា វិស័យនយោបាយ សង្គមកិច្ច និងសេដ្ឋកិច្ច។ល។ សញ្ញាណទាំងអស់នេះ បានធ្វើឱ្យស្ត្រីមាន ឱកាសប្រកបរបរអាជីវកម្មក្នុងមានជាពាណិជ្ជករមួយរូប ដើម្បីជាចំណែកមួយក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ។

### ១.២.១ សិទ្ធិរបស់ពាណិជ្ជករ

ការសម្ដែងឡើងនូវឆន្ទៈរបស់ពាណិជ្ជករ ចំពោះនូវរាល់ការអនុវត្តសកម្មភាពពាណិជ្ជកម្មរបស់ខ្លួនតាមរបបគតិយុត្តនៃពាណិជ្ជកិច្ច និងកិច្ចសន្យា គឺជាសិទ្ធិរបស់ពាណិជ្ជករ។ ត្រូវបានបែងចែកជាសិទ្ធិនានាក្នុងការអនុវត្តសកម្មភាពពាណិជ្ជកម្ម ដែលពាណិជ្ជករអនុវត្តសិទ្ធិរបស់ខ្លួនដោយមិនអាចផ្ដាច់ចេញពីសកម្មភាពពាណិជ្ជកម្ម និងសមត្ថកិច្ចតុលាការបានឡើយ។

[16] មាត្រា៣ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានានូវសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ក្នុងការអាស្រ័យផលសេដ្ឋកិច្ច.......

[17] មាត្រា១០ រដ្ឋភាគីត្រូវយកវិធានការដើម្បីលុបបំបាត់ការរើសអើងស្ត្រីភេទធានាឲ្យបុរសនិងស្ត្រីមានសិទ្ធស្មើគ្នា

[18] ប្រសាសន៍របស់ លោកស្រី ម៉ែនសំអន ប្រធានសមាគមនារីកម្ពុជាដើម្បីអភិវឌ្ឍន៍ និងជាឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឲ្យកាសខួបអនុស្សាវរីយ៍៣០ឆ្នាំ នៃការបង្កើតសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ កាលពីថ្ងៃចន្ទ ទី០១ ធ្នូ ឆ្នាំ២០០៨ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា

សិទ្ធិរបស់ពាណិជ្ជករមានដូចជា ចំពោះការគ្រប់គ្រងអាជីវកម្មរបស់ខ្លួន សិទ្ធិចំពោះតតិយជន និងអ្នកប្រើប្រាស់ និងសិទ្ធិចំពោះមុខរបរ។[19]

### ១.២.១.១ ការគ្រប់គ្រងអាជីវកម្ម

ពាណិជ្ជករត្រូវចាត់ចែងសកម្មភាពពាណិជ្ជកម្មដោយខ្លួនឯង គ្រប់គ្រងព័ត៌មានដែលទាក់ទងទៅនឹងទីផ្សារ និងសិទ្ធិទាញយកអត្ថប្រយោជន៍ និងប្រាក់ចំណេញពីកម្មសិទ្ធិពាណិជ្ជកម្មរបស់ខ្លួន។ លើសពីនេះ ពាណិជ្ជករអាចជួលគ្រប់គ្រង (ជួលធ្វើអាជីវកម្មផ្តាច់មុខ) ឬលក់មូលនិធិពាណិជ្ជកម្ម។ ពាណិជ្ជករអាចធ្វើភតិសន្យាពាណិជ្ជកម្មជាថ្មីឡើងក្នុងរយៈពេលពីរឆ្នាំម្តង ប្រសិនបើមានសារៈប្រយោជន៍។ ប៉ុន្តែ ត្រូវរក្សាទុកក្នុងសារៈមន្ទីរជាតិ ប្រសិនបើគ្មានអត្ថប្រយោជន៍។[20]

### ១.២.១.២ សិទ្ធិចំពោះតតិយជន និងអ្នកប្រើប្រាស់

#### ក សិទ្ធិចំពោះតតិយជន

ពាណិជ្ជករមានសិទ្ធិប្តឹងទៅតុលាការចំពោះកូនបំណុល ជាពាណិជ្ជករក្នុងករណីមិនសងប្រាក់ឱ្យមានការជម្រះបញ្ជីទ្រព្យសម្បត្តិ និងការស្តារលទ្ធភាពតាមផ្លូវតុលាការ។ ពាណិជ្ជករត្រូវចាត់ចែងយ៉ាងរហ័សនូវការកំណត់អាជ្ញាយុកាលដ៏ខ្លី គឺ២ឆ្នាំចំពោះរឿងពាណិជ្ជកម្ម។ ឯសម្រាប់បណ្តឹងឱ្យសងប្រាក់តបទៅនឹងអ្នកទិញមិនមែនជាពាណិជ្ជករដែលមិនអនុវត្តកាតព្វកិច្ច គឺមានអាជ្ញាយុកាល៥ឆ្នាំ។

#### ខ សិទ្ធិចំពោះអ្នកប្រើប្រាស់

នរណាជាអ្នកប្រើប្រាស់? អ្នកប្រើប្រាស់គឺ អតិថិជន។ អតិថិជនមានសិទ្ធិប្តឹងពាណិជ្ជករឱ្យទទួលខុសត្រូវ ចំពោះកាតព្វកិច្ច និងធានាចំពោះវិការៈខាងក្នុង និងការរំខានពីតតិយជន។ ចំពោះពាណិជ្ជករវិញមានសិទ្ធិប្តឹងតបទៅអ្នកទិញមិនមែនជាពាណិជ្ជករឱ្យអនុវត្តបានដូចគ្នា។ ពាណិជ្ជករមានសិទ្ធិទទួលបាននូវកិច្ចឧបត្ថម្ភពីអតថិជនរបស់ខ្លួននៅពេលអនាគត។

### ១.២.១.៣ សិទ្ធិចំពោះមុខរបរ

សិទ្ធិចំពោះមុខរបរ ពាណិជ្ជករមានសិទ្ធិសំខាន់ៗមួយចំនួនដូចតទៅៈ

ពាណិជ្ជករមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតក្នុងសភាពាណិជ្ជកម្ម ព្រមទាំងជាចៅក្រមជ្រើសតាំងក្នុងតុលាការពាណិជ្ជកម្ម។ ពាណិជ្ជករមានសេរីភាពពេញទីក្នុងការចូល

---

[19] សំ បូណែល, *ច្បាប់ពាណិជ្ជកម្មកម្ពុជា*, បោះពុម្ព ២០១៥, ទំព័រ៣៣

[20] គង់ សាផន, *នីតិពាណិជ្ជកម្ម*, បោះពុម្ព ២០១២, ទំព័រ៨៧

រួមប្រកួតប្រជែងក្នុងទីផ្សារ។ ជាមួយគ្នានេះដែរ ពាណិជ្ជករក៏មានសិទ្ធិដាក់បដិបញ្ញត្តិ ដោយចែងក្នុងកិច្ចសន្យាពីវិធានសមត្ថកិច្ចតុលាការតាមដែនដី និងបញ្ចូលទៅក្នុងកិច្ចសន្យានូវកិច្ចព្រមព្រៀងផ្សះផ្សា ឬអាចហៅថា ខសម្របសម្រួល។ ក្រៅពីនេះ ពាណិជ្ជករមានសិទ្ធិផងដែរក្នុងការចូលរួមក្នុងសកម្មភាពជាប្រយោជន៍សាធារណៈ។ ការចូលរួមក្នុងប្រយោជន៍សាធារណៈ ពាណិជ្ជករអាចធ្វើជាសប្បុរសធម៌ជាដើម។

### ១.២.២ របបទ្រព្យសម្បត្តិដែលស្ត្រីមិនទាន់រៀបការជាពាណិជ្ជករប្រើប្រាស់

កាលណាយើងនិយាយពីស្ត្រីដែលពុំទាន់រៀបអាពាហ៍ពិពាហ៍ គឺជាស្ត្រីដែលពុំទាន់មានស្វាមី។ ការដែលស្ត្រីមិនមានស្វាមី វាគឺជាកត្តាមួយដែលពុំបណ្តាលឱ្យមានភាពស្មុគស្មាញក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ព្រោះវាមិនពិបាកក្នុងការជ្រើសរើសរបបទ្រព្យសម្បត្តិមួយណាមកធ្វើការប្រតិបត្តិការសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន។ ស្ត្រីនៅលីវមានឯករាជ្យផ្ទាល់ខ្លួនក្នុងការយកទ្រព្យសម្បត្តិនានារបស់ខ្លួនមកចាត់ចែងក្នុងអាជីវកម្មរបស់ខ្លួនបាន មិនថាចលនវត្ថុ ឬអចលនវត្ថុទេ។ ទាំងសម្រាប់ការផ្គត់ផ្គង់សកម្មភាពពាណិជ្ជកិច្ចប្រចាំថ្ងៃ និងរាល់បំណុលជាមួយតតិយជន ស្ត្រីនៅលីវប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ប៉ុន្តែ ក្នុងករណីដែលស្ត្រីនៅលីវមានអាណាព្យាបាលជាអ្នកប្រឹក្សា ឬផ្តល់យោបល់ គេក៏អាចធ្វើការពឹងពាក់ទ្រព្យសម្បត្តិបានដែរ គឺទៅតាមលទ្ធភាពរបស់អាណាព្យាបាលនាង។ និយាយជាភាសាសាមញ្ញ ស្ត្រីនៅលីវអាចធ្វើការកាន់កាប់ទ្រព្យផ្ទាល់ ឬទ្រព្យដោយឡែករបស់ខ្លួន និងចាត់ចែងទៅតាមតម្រូវការ។ ដរាបណា មិនទាន់រៀបអាពាហ៍ពិពាហ៍ គ្រប់ទ្រព្យសម្បត្តិទាំងអស់ដែលនាងរកបាន គឺជាកម្មសិទ្ធិផ្ទាល់របស់នាងដែលយើងហៅថា ទ្រព្យដោយឡែក[21]។

## ១.៣ កាតព្វកិច្ចរបស់ពាណិជ្ជករជាស្ត្រីមិនទាន់រៀបការ

ការចាប់ផ្តើមនៃការធ្វើសកម្មភាពពាណិជ្ជកម្មរបស់ពាណិជ្ជករ ដែលមានច្រើន និងប្លែកៗពីគ្នា គឺជាកាតព្វកិច្ចរបស់ពាណិជ្ជករ។ កាតព្វកិច្ច វាត្រូវបានស្តែងឡើងជាបន្តបន្ទាប់នៅគ្រប់ពេលវេលាទាំងអស់ដែលអនុវត្តសកម្មភាព ហើយវាមានលក្ខណៈគតិយុត្ត។

### ១.៣.១ ការចុះបញ្ជីពាណិជ្ជកម្ម

ក្នុងនាមជាពាណិជ្ជករមួយរូប ត្រូវតែមានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។ ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវធ្វើឡើងយ៉ាងតិច១៥ថ្ងៃមុនពេលចាប់ផ្តើមបើកដំណើរការពាណិជ្ជ

[21] មាត្រា៩៧២ ក្រមរដ្ឋប្បវេណី (២០០៧)

កម្មឲ្យតែមានជាប់ពន្ធលើប្រាក់ចំណេញ។[22] ពាណិជ្ជករមិនជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មនេះឡើយ ប្រសិនបើមិនជាប់ពន្ធលើប្រាក់ចំណេញ ពោលគឺពាណិជ្ជករដែលមានប្រាក់ចំណេញប្រចាំឆ្នាំមិនលើសពី ០៦លានរៀល។ ចំពោះករណីនេះ ពាណិជ្ជករមិនជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្ម នៅតែមានកាតព្វកិច្ចសុំលិខិតអនុញ្ញាតប្រកបរបរអាជីវកម្ម និងសេវាកម្មពីមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង។ ក្រសួងពាណិជ្ជកម្មបានកំណត់ថា គ្រប់អាជីវកម្ម សេវាកម្ម គ្រប់ក្រុមហ៊ុនដែលមិនជាប់ពន្ធលើប្រាក់ចំនេញ ឬមិនជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ត្រូវមានកាតព្វកិច្ចមកសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មសេវាកម្មពីមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង។ ការដាក់ពាក្យសុំធ្វើលិខិតអនុញ្ញាតនេះ ត្រូវសុំនៅមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ដែលកន្លែងអាជីវកម្មនោះតាំងនៅ។ លិខិតអនុញ្ញាតមានសុពលភាព១ឆ្នាំ ហើយអាចត្រូវបន្តថ្មីក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរមុនពេលផុតកំណត់លិខិតអនុញ្ញាតនេះ។ ក្នុងករណីដែលពាណិជ្ជករបានផ្តល់ព័ត៌មានមិនពិតចំពោះការដាក់ពាក្យ ឬមិនបានអនុវត្តតាមលក្ខខណ្ឌនៃការដាក់ពាក្យស្នើសុំនេះ ពាណិជ្ជករនោះត្រូវទទួលទណ្ឌកម្ម ដែលត្រូវបានចេញពីមន្ទីរពាណិជ្ជកម្មខេត្ត ក្រុងដូចខាងក្រោម៖

- លើកទីមួយ ធ្វើការណែនាំឱ្យអនុវត្ត
- លើកទីពីរ ព្រមានជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យមកបំពេញតាមច្បាប់ជាធរមាន
- ផ្អាកមិនឱ្យធ្វើអាជីវកម្ម ឬពាណិជ្ជកម្មមួយរយៈ ដើម្បីទុកពេលឱ្យពាណិជ្ជករមកបំពេញបែបបទជាចុងក្រោយ។[23]

ប្រសិទ្ធិភាពនៃការចុះបញ្ជី មានចំណុចសំខាន់ៗគួរឱ្យចាប់អារម្មណ៍មួយចំនួន។ ការចុះបញ្ជីបណ្តាលឱ្យមានការប្តឹងទាស់ពីតតិយជន ចំពោះកិច្ច ឬអំពើដែលពាណិជ្ជករធ្វើការផ្សព្វផ្សាយជាសាធារណៈក្នុងសៀវភៅបញ្ជីពាណិជ្ជកម្ម ឬតាមសារព័ត៌មាន ត្រូវទទួលយកការប្តឹងទាស់នេះ។ ចំពោះកិច្ច ឬអំពើដែលធ្វើដោយភាគីពីរ មិនមានប្រសិទ្ធិភាពទៅលើតតិយជនទេ គឺមានប្រសិទ្ធិភាពរវាងតែពីរនាក់តែប៉ុណ្ណោះ។ ឯកិច្ច ឬអំពើដែលមិនបានធ្វើការផ្សព្វផ្សាយ ត្រូវបានប្តឹងទាស់ពីតតិយជន បើសិនជាបុគ្គលដែលស្ថិតនៅក្រមការចុះបញ្ជី ត្រូវបង្ហាញពីការយល់ដឹងរបស់តតិយជន។

ក្រោយពីបានចុះបញ្ជី ស្ត្រីមិនទាន់រៀបការទទួលបានលក្ខណៈជាពាណិជ្ជករ។ ជាគោលការណ៍ ការសន្មតនេះ ជាការសន្មតធម្មតា នាំឱ្យការបដិសេធនានាត្រូវស្ថិតនៅក្រោមរបបភស្តុតាងផ្ទុយ។ ប៉ុន្តែ ករណីនៃការលក់មូលនិធិពាណិជ្ជកម្ម និងការជួលគ្រប់គ្រងមូលនិធិពាណិជ្ជកម្មវិញ ការសន្មតមិនអាចប្រកែកបានទេ ហើយមិនអាចមានភស្តុតាងផ្ទុយ។

[22] មាត្រា១២, ១៤ និង១៧ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

គួរបញ្ជាក់ផងដែរថា បច្ចុប្បន្ននេះ ក្រសួងពាណិជ្ជកម្មបានធ្វើកំណែទម្រង់អំពីការចុះបញ្ជីពាណិជ្ជកម្មបន្ថែមលើរបៀបធម្មតាដែលធ្លាប់ប្រើប្រាស់ គឺការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីដើរឱ្យទាន់សម័យបច្ចេកវិទ្យា ដែលនីតិវិធីនានាត្រូវបានបញ្ជាក់នូវក្នុងវេបសាយរបស់ក្រសួង។ ក្រសួងបានលើកទឹកចិត្តដោយចេញសេចក្ដីប្រកាសឱ្យពាណិជ្ជករគ្រប់រូបប្ដូរមកប្រើប្រាស់ប្រព័ន្ធនេះវិញ[24]។

### ១.៣.១.១ ការចុះបញ្ជីកែប្រែ

ពាណិជ្ជករមានកាតព្វកិច្ច ធ្វើការផ្សព្វផ្សាយជាសាធារណៈតាមសារព័ត៌មានស្របច្បាប់នូវព័ត៌មានដែលទាក់ទងទៅនឹងការកែប្រែស្ថានភាពផ្ទាល់ខ្លួន ព្រមទាំងការកែប្រែស្ថានភាពអាជីវកម្មឱ្យសាធារណៈជន និងអ្នកប្រើប្រាស់ទំនិញ និងសេវារបស់ខ្លួនបានដឹងតាមមធ្យោបាយផ្សេងៗ ហើយត្រូវគោរព និងទទួលខុសត្រូវចំពោះការប្រើប្រាស់។[25]

### ១.៣.១.២ ការលុបឈ្មោះចេញពីបញ្ជី

នៅពេលណាមួយដែលពាណិជ្ជករឈប់ប្រកបរបរពាណិជ្ជកម្មរបស់ខ្លួន ឬទទួលមរណភាពដោយពុំបានធ្វើអនុប្បទាននូវមូលនិធិពាណិជ្ជកម្មរបស់ខ្លួន នាំឱ្យត្រូវលុបឈ្មោះពាណិជ្ជករនោះចេញពីបញ្ជីពាណិជ្ជកម្ម។

ក្នុងករណីដែលមិនមានការលុបឈ្មោះចេញដោយពាណិជ្ជករ ឬដោយអ្នកទទួលមរតក ឬដោយអ្នកជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះត្រូវធ្វើឡើងដោយបញ្ញត្តិ តាមសេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម។ រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មត្រូវចម្លងជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតម្កល់ធ្វើជាយុត្តាធិការពាណិជ្ជកម្មនៅពេលក្រោយៗទៀត[26]។

### ១.៣.១.៣ ទណ្ឌកម្ម

ចំពោះពាណិជ្ជករណា ដែលមិនបានសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ នឹងត្រូវប្ដឹងទៅតុលាការពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់ និងត្រូវផ្ដន្ទាទោសឱ្យទទួល

---

[23] សំ បូណែល, *ច្បាប់ពាណិជ្ជកម្មកម្ពុជា*, បោះពុម្ព ២០១៥, ទំព័រ៣២

[24] ប្រកាសលេខ២៩៩ ពណចបប្រក ចុះថ្ងៃ២៩ ធ្នូ ២០១៥ ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

[25] មាត្រា១៥, ១៨ និង២០ ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

[26] មាត្រា២៨, ៣៣ និង៣៨ ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

ខុសត្រូវខាងរដ្ឋប្បវេណី និងព្រហ្មទណ្ឌតាមបញ្ញត្តិច្បាប់។ គ្រប់ប្រាក់ពិន័យទាំងអស់ ត្រូវបង់ចូលថវិការដ្ឋ។

បើយោងតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ដដែល ទោសដែលត្រូវផ្តន្ទាដល់ពាណិជ្ជករប្រភេទនេះ មានកំណត់ដូចខាងក្រោម៖

- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៥ម៉ឺនរៀល ទៅ ៥សែនរៀល ចំពោះ
  - ✓ រាល់ពាណិជ្ជករដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិ
  - ✓ រាល់ពាណិជ្ជករដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក័យប័ត្រ លិខិតស្នាម កំណត់បញ្ជាទិញ តារាងតម្លៃ និងឯកសារផ្សព្វផ្សាយអំពីទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម ដែលខ្លួនបានចុះឈ្មោះ និងលេខដែលខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម។
- ពាណិជ្ជករដែលផ្តល់ព័ត៌មានមិនពិតដោយគំនិតអាក្រក់ដើម្បីសុំចុះលេខ ឬសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ១លានទៅ១០លានរៀល។
- ពាណិជ្ជករដែលមិនបានបំពេញបែបបទ នៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីមានការកែប្រែ ត្រូវផ្តន្ទាទោសជាប្រាក់ពី ៥សែនរៀនទៅ ១លានរៀល។
- ពាណិជ្ជករដែលប្រើប្រាស់ឯកសារក្លែងក្លាយដោយចេតនា នៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម ត្រូវជាប់ពន្ធនាគារពី ១ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ១០លានរៀល។
- ក្នុងករណីមិនរៀងចាល ការផ្តន្ទាទោសនឹងត្រូវបន្ថែមទម្ងន់ដូចមានចែងនៅក្នុងមាត្រា៤៤ នៃច្បាប់ដដែល។

ការដែលមិនបំពេញកាតព្វកិច្ចសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមការកំណត់របស់ច្បាប់ អាចធ្វើឱ្យពាណិជ្ជករមានទោសនិទ្ទភាពសាមញ្ញ ក្នុងករណីក្ស័យធន។ ចំពោះជនណាដែលបានជំរិត ឬបានទទួលនូវរបស់ ឬប្រាក់ដោយប្រើអំណាចនៃមុខងាររបស់ខ្លួន ជននោះត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស ហើយត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។[27]

[27] មាត្រា៤១,៤៥ និង៤៦ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

### ១.៣.២ ការផ្សព្វផ្សាយជាសាធារណៈតាមផ្លូវច្បាប់

ពាណិជ្ជករ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈតាមសារព័ត៌មានស្របច្បាប់ណាមួយដែលរដ្ឋទទួលស្គាល់ ឬទស្សនាវដ្ដីប្រចាំតំបន់ដែលគ្រឹះស្ថានពាណិជ្ជកម្ម ឬក៏ទីស្នាក់ការក្រុមហ៊ុនតាំងនៅក្នុងគោលបំណងឱ្យសាធារណៈជនបានដឹងឮ និងធ្វើការប្ដឹងទាស់។

### ១.៣.៣ ការគ្រប់គ្រងបញ្ជីគណនេយ្យ

ជាកាតព្វកិច្ច ពាណិជ្ជករត្រូវមានសៀវភៅគណនេយ្យ ដោយសំអាតហេតុផលទូលំទូលាយពីគណនេយ្យផ្ទាល់ខ្លួន ដែលនេះមានន័យថា ពាណិជ្ជករគ្រប់រូបត្រូវកាន់កាប់សៀវភៅគណនេយ្យមួយក្នុងគោលបំណងគ្រប់គ្រង និងផ្ដល់ព័ត៌មានជូនអាជ្ញាធរមានសមត្ថកិច្ចជាពិសេសអាជ្ញាធរពន្ធ និងប្រធានតុលាការពាណិជ្ជកម្ម។ យោងតាមមាត្រា៤៧ និង៤៨ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ បានកំណត់ថា រាល់ពាណិជ្ជករ មានកាតព្វកិច្ចកាន់កាប់គណនេយ្យមួយទៅតាមវិធានគណនេយ្យ និងតាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការណែនាំផ្សេងៗទៀត ដែលទាក់ទងដល់ការអនុវត្ត។ បន្ថែមពីនេះ គ្រប់ពាណិជ្ជករដែលប្រព្រឹត្តបទល្មើសផ្ទុយនឹងបទបញ្ញាគណនេយ្យដូចបានរៀបរាប់ខាងលើ ត្រូវចោទប្រកាន់ និងផ្ដន្ទាទោសតាមច្បាប់ជាធរមាន។ ជាមួយគ្នានេះ ពាណិជ្ជករត្រូវបើកគណនីយ៉ាងហោចមួយ នៅក្នុងធានាគារណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។ អានុភាពនៃឯកសារគណនេយ្យដែលមានចំពោះភស្តុតាងត្រូវរក្សាទុកជាភស្តុតាងសម្រាប់រឿងក្ដីល្មើសទៅនឹងថេរវេលានៃអាជ្ញាយុកាលពាណិជ្ជកម្ម។

### ១.៣.៤ កាតព្វកិច្ចបង់ពន្ធ

ដោយគោរពទៅតាមច្បាប់ជាធរមាន ពាណិជ្ជករត្រូវបំពេញនូវកាតព្វកិច្ចដល់រដ្ឋជាចាំបាច់គឺត្រូវបង់ពន្ធពិសេសដូចជា ពន្ធអាជីវកម្ម អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ ការបង់វិភាគទានលើផ្នែកសន្តិសុខសង្គមជាដើម។

### ១.៣.៥ កាតព្វកិច្ចផ្សេងៗទៀត

ក្រៅពីកាតព្វកិច្ចដូចដែលបានរៀបរាប់ខាងលើ ពាណិជ្ជករត្រូវបំពេញកិច្ចមួយចំនួនទៀតដូចជា ត្រូវចូលរួមវិភាគទានហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់សភាពាណិជ្ជកម្ម ត្រូវគោរពកាតព្វកិច្ចប្រកួតប្រជែងស្របច្បាប់។

ដោយយោងតាមមាត្រា៤៩ នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ ចំពោះការលក់ទំនិញ ឬការធ្វើសេវាឱ្យអ្នកប្រើប្រាស់ ពុំចាំបាច់ធ្វើវិក័យប័ត្រ ឬសក្ខីប័ត្រទេ លុះណា

តែអតិថិជនទាមទារ។ គ្រប់ពាណិជ្ជកិច្ចដែលធ្វើឡើងដោយអាជីវករ និងអាជីវករត្រូវមានវិក័យប័ត្រយ៉ាងហោចណាស់ពីរច្បាប់ គឺច្បាប់ដើមមួយសន្លឹកសម្រាប់ផ្តល់ជូនអតិថិជន ហើយសន្លឹកផ្សេងទៀតត្រូវរក្សាទុកដោយអ្នកលក់។ ពាណិជ្ជករត្រូវអនុលោមតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយចុះនិទ្ទេសនៅក្នុងវិក័យប័ត្រ។ ពាណិជ្ជករទាំងអស់ត្រូវបិទតម្លៃ និងលក្ខខណ្ឌនៃការលក់ដូរដែលមានកំណត់ដោយក្រសួងពាណិជ្ជកម្ម។[28]

[28] មាត្រា៥០ និង៥១ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

# ជំពូកទី២

# ជំពូកទី២ ស្ត្រីរៀបការជាពាណិជ្ជករ

ពុំមានការខុសគ្នាប៉ុន្មានទេជាមួយស្ត្រីមិនទាន់រៀបការ ពាក់ព័ន្ធនឹងលក្ខខណ្ឌគតិយុត្តនានាដើម្បីក្លាយជាពាណិជ្ជករ។ ប៉ុន្តែគ្រាន់តែស្ត្រីរៀបការរួចត្រូវមានលក្ខខណ្ឌបន្ថែមច្រើនជាងមួយចំនួន និងមានការប្រែប្រួលខ្លះៗ ដោយព្រោះខ្លួនបានបន្ថែមចំណងអាពាហ៍ពិពាហ៍ ដែលចំណងអាពាហ៍ពិពាហ៍នេះហើយ ជាអ្នកដែលធ្វើឱ្យមានបម្រែបម្រួល ជាពិសេសការជ្រើសរើសទ្រព្យសម្បត្តិមកចាត់ចែងក្នុងសកម្មភាពអាជីវកម្ម និងការកំណត់របស់ទំនៀមទម្លាប់សង្គមមួយចំនួនទៀត។ នៅក្នុងមាត្រា៩៧២ ដល់៩៧៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងពីសិទ្ធិស្មើគ្នារវាងស្វាមីភរិយាក្នុងការគ្រប់គ្រង និងចាត់ចែងលើទ្រព្យសម្បត្តិដោយឡែក និងទ្រព្យរួមផងដែរ។ ការធ្វើពាណិជ្ជកម្មរបស់សហព័ទ្ធជាភរិយា គឺត្រូវមានការប្រាកដប្រជាក្នុងការជ្រើសរើសរបបទ្រព្យសម្បត្តិណាមួយមកធ្វើការប្រើប្រាស់។ រីឯប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌វិញក៏បានកំណត់លក្ខខណ្ឌ និងរបៀបដែលប្តីប្រពន្ធជ្រើសរើសទ្រព្យសម្បត្តិតាមកិច្ចសន្យាដើម្បីចាត់ចែងផងដែរ។

## ២.១ លក្ខខណ្ឌគតិយុត្តដើម្បីក្លាយជាពាណិជ្ជកររបស់ស្ត្រីរៀបការ

### ២.១.១ ការសុំការអនុញ្ញាត ឬមានការព្រមព្រៀងពីស្វាមីរបស់ខ្លួន

ដោយសារសង្គមខ្មែរបានឱ្យតម្លៃជាពិសេសទៅលើមនោសញ្ចេតនា ទើបប្តីប្រពន្ធមានតួនាទីសំខាន់ណាស់ក្នុងការបង្ហាញមនោសញ្ចេតនាទៅកាន់គ្នាទៅវិញទៅមក។ ការពិភាក្សាគ្នាគឺជារូបភាពមួយដ៏សំខាន់ដែរក្នុងការបង្ហាញ។ ទោះបីជាស្ត្រីមានឯករាជ្យភាពពេញលេញក៏ដោយ ក៏ស្ត្រីគួរធ្វើការប្រឹក្សាយោបល់ជាមុនសិន។ ដូចនេះ ក្រោយពីត្រូវបានភ្ជាប់ដោយចំណងអាពាហ៍ពិពាហ៍ស្ត្រីមុននឹងក្លាយជាពាណិជ្ជករត្រូវតែមានការព្រមព្រៀងពីស្វាមីដោយធ្វើការសុំការអនុញ្ញាត។ នេះមានន័យថាស្ត្រីត្រូវធ្វើការពិភាក្សាជាមួយស្វាមីចំពោះការចាប់ផ្តើមអាជីវកម្មរបស់ខ្លួន ព្រោះថាការព្រមព្រៀងពីស្វាមីអាចជាកត្តាដើមចមមួយដែលធ្វើឱ្យសកម្មភាពអាជីវកម្មជោគជ័យ ឬបរាជ័យបាន។ ប្រសិនបើស្វាមីបានព្រមព្រៀង ឱ្យភរិយាធ្វើជាពាណិជ្ជករ នោះមានន័យថាស្វាមីបានគាំទ្រចំពោះសកម្មភាពនានារបស់ភរិយា សូម្បីតែជំនួយទៅលើបំណុលក្នុងរឿងពាណិជ្ជកម្មរបស់ភរិយាមិនថាភរិយាជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិណាទៅប្រើប្រាស់ទេ។ វាបានបញ្ជាក់ថាការព្រមព្រៀងរបស់ស្វាមីជាចំណែកមួយជួយឱ្យពាណិជ្ជកិច្ចរបស់ភរិយាជោគជ័យ។ ប៉ុន្តែ ប្រសិនបើស្វាមីធ្វើការបដិសេធវិញ វាគឺជាឧបសគ្គរបស់ស្ត្រីដែលចង់ក្លាយខ្លួនជាពាណិជ្ជករ ព្រោះថាទោះបីជាជំនះបាន

យប្រប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ក៏វាប្រឈមនឹងហានីភ័យដល់សុភមង្គលក្នុងគ្រួសារផង ដែរ។ បញ្ហាសុភមង្គលក្នុងគ្រួសារអាចជះឥទ្ធិពលដល់ការប្រកបរបរពាណិជ្ជកម្មរបស់ស្ត្រី។

ចំពោះករណីស្វាមីជាពាណិជ្ជករ ស្ត្រីដែលចង់ក្លាយខ្លួនជាពាណិជ្ជករអាចជ្រើសរើសចូលរួម ជាមួយស្វាមី ដែលលក្ខណៈសម្បត្តិជាពាណិជ្ជករ គឺអាស្រ័យទៅលើការធ្វើសកម្មភាពដែលបាន ចូលរួម។

ដោយឡែកចំពោះស្ត្រីមានរបរពាណិជ្ជកម្មមុនពេលរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវធ្វើការសួរ យោបល់ពីស្វាមីដូចគ្នា ថាតើគួរបន្តធ្វើជាពាណិជ្ជករ ឬបញ្ឈប់ក្រោយពេលរៀបអាពាហ៍ពិពាហ៍។ យ៉ាងណាក៏ដោយ យើងសង្កេតឃើញថា ស្វាមីភាគច្រើនបានយល់ព្រម ហើយស្ត្រីខ្លួនឯងភាគ ច្រើនធ្វើការបន្ត ទោះបីជាមានការយល់ព្រម ឬមិនយល់ព្រម។ មូលហេតុនោះគឺស្ត្រីទាំងនោះមាន ភាពរឹងមាំរួចជាស្រេចក្នុងរឿងពាណិជ្ជកម្ម និងមួយវិញទៀតគឺ ក្រៅពីរបរពាណិជ្ជកម្ម ស្ត្រីជា ពាណិជ្ជករមួយចំនួនពុំមានជំនាញណាផ្សេងទៀតដែលប្រសើរជាងពាណិជ្ជកិច្ច។

ទោះបីស្ថិតនៅក្នុងសមត្ថកម្មបែបណាក៏ដោយ ការព្រមព្រៀងពីស្វាមីគឺជាលក្ខខណ្ឌមួយ ដែលមិនអាចខ្វះបានសម្រាប់ស្ត្រី ដើម្បីក្លាយខ្លួនជាពាណិជ្ជករម្នាក់ហើយអាចកាត់បន្ថយបញ្ហាសុភ មង្គលក្នុងគ្រួសារ។

### ២.១.២ ការប្រកាសរបបទ្រព្យសម្បត្តិ

ខុសពីស្ត្រីជាពាណិជ្ជករមិនទាន់រៀបការ ស្ត្រីរៀបការហើយជាពាណិជ្ជករមានភាពស្មុគ ស្មាញជាងត្រង់របបទ្រព្យសម្បត្តិ ខណៈដែលស្ត្រីនៅលីវចាត់ចែងទ្រព្យផ្ទាល់ខ្លួនសម្រាប់ប្រតិបត្តិ ការអាជីវកម្ម។

ស្ត្រីរៀបការរួចអាចធ្វើការជ្រើសរើសរវាងទ្រព្យសម្បត្តិពីរប្រព័ន្ធគឺ ប្រព័ន្ធទ្រព្យសម្បត្តិតាម កិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺ សហព័ទ្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយអាពាហ៍ពិពាហ៍បានដោយ គោរពលើសិទ្ធិទាមទារអាហារកិច្ច និងភាគបម្រុង។ នីតិវិធីនៃការចុះកិច្ចសន្យាទ្រព្យសម្បត្តិនេះត្រូវ បានកំណត់ដោយប្រកាសស្តីពីនីតិវិធីចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ២០១៤ របស់ក្រសួង យុត្តិធម៌។ ដោយឡែក ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ចែកចេញជាពីរទៀតគឺ ទ្រព្យ សម្បត្តិដោយឡែក (ទ្រព្យផ្ទាល់) និងទ្រព្យសម្បត្តិរួម។ គេសង្កេតឃើញថា ភាគច្រើន សហព័ទ្ធ ជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់មកប្រើប្រាស់។ ក្នុងករណីនេះ ស្ត្រីរៀបការ រួចត្រូវមានភាពច្បាស់លាស់ថា ខ្លួនជ្រើសរើសប្រភេទទ្រព្យសម្បត្តិមួយណាមកធ្វើសកម្មភាព

ពាណិជ្ជកម្មរបស់ខ្លួន ឬក៏ប្រើប្រាស់ទាំងពីរ។ វាអាស្រ័យទៅលើការសម្រេចចិត្តផ្ទាល់ និងការពិភាក្សាជាមួយស្វាមីរបស់នាង។ ទន្ទឹមនឹងនេះ ស្ត្រីត្រូវធ្វើការប្រកាសជាសាធារណៈអំពីរបបទ្រព្យសម្បត្តិដែលខ្លួនយកមកធ្វើប្រតិបត្តិការពាណិជ្ជកម្ម។

យើងនឹងធ្វើការសិក្សា ថាតើស្ត្រីរៀបការរួចជាពាណិជ្ជករ និងសហាព័ទ្ធមានសិទ្ធិលើទ្រព្យណាខ្លះ ហើយទ្រព្យសម្បត្តិណាខ្លះជាទ្រព្យផ្ទាល់ ហើយណាខ្លះទៀតជាទ្រព្យរួមដូចខាងក្រោម។

### ២.១.២.១ ទ្រព្យផ្ទាល់

មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ជាក់អំពីប្រភេទទ្រព្យសម្បត្តិផ្ទាល់។ មាត្រានេះបានកំណត់ទ្រព្យដោយឡែកថាគឺជា៖

- ✓ ទ្រព្យដែលសហាព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍
- ✓ ទ្រព្យសម្បត្តិ ដែលសហាព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍
- ✓ ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងពីទ្រព្យសម្បត្តិទាំងពីរខាងលើ។

ទ្រព្យដែលសហាព័ទ្ធមាននៅមុនពេលអាពាហ៍ពិពាហ៍ ជាទ្រព្យដែលសហាព័ទ្ធជាម្ចាស់កម្មសិទ្ធិតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍។ វាអាចជាទ្រព្យដែលកើតចេញពីការខិតខំប្រឹងប្រែង ឬការសន្សំតាំងពីមុនពេលរៀបការដូចជា ការប្រកបអាជីវកម្មមុនពេលរៀបការជាដើម។ លើសពីនេះ វាអាចជាទ្រព្យដែលសហាព័ទ្ធម្ខាងទទួលបានពីឪពុកម្ដាយរបស់ខ្លួនមុនពេលរៀបការ ឬអាចពេលក្រោយថ្ងៃរៀបការ។

ទ្រព្យសម្បត្តិដែលទទួលបានជាអំណោយ អច្ច័យទាន សន្តតិកម្ម ក្នុងអំឡុងពេលមានអាពាហ៍ពិពាហ៍ ត្រូវបានកំណត់ថាជាទ្រព្យដោយឡែកព្រោះថា វាមិនបានកើតចេញពីការខិតខំរបស់សហាព័ទ្ធណាម្នាក់ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ទេ។ ផ្ទុយទៅវិញ វាមានគោលបំណងធានានូវការថែរក្សាទ្រព្យសម្បត្តិដែលបានបន្សល់នៅក្នុងគ្រួសារ។

ទ្រព្យសម្បត្តិដែលជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិផ្ទាល់ខ្លួន គឺជាទ្រព្យដែលកើតចេញពីការលក់ ឬដោះដូរជាដើម។ ការចាត់ចែងលក់ ឬដោះដូរនោះ អាចចេញទៅជារូបរាងទ្រព្យមួយ ឬច្រើនផ្សេងទៀត ឬអាចទៅជាសាច់ប្រាក់។ ទោះបីជាលក់ ឬដោះដូរក្នុងអំឡុងពេលមាន ឬមិនមានចំណងអាពាហ៍ពិពាហ៍ វានៅតែជាទ្រព្យដោយឡែក។ យ៉ាងណាមិញ ប្រភពនៃកំណើនតម្លៃទ្រព្យដែលបានចាត់ចែងនោះ ជាកត្តាកំណត់ថាកំណើននោះជាទ្រព្យដោយឡែក ឬមិនមែន។ ប្រសិនបើ ប្រភពនៃកំណើនតម្លៃនោះកើតចេញពីការខិតខំប្រឹងប្រែងរបស់សហាព័ទ្ធតែ

ម្ខាងកំណើនតម្លៃនោះនៅតែជាទ្រព្យដោយឡែក។ ប៉ុន្តែ ប្រសិនបើវាកើតចេញពីការប្រឹងប្រែងរបស់សហព័ទ្ធទាំងសងខាង កំណើនតម្លៃនោះមិនមែនជាទ្រព្យដោយឡែកទៀតទេ។

### ២.១.២.២ ទ្រព្យរួម

ទ្រព្យរួម គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍[29]។

ទ្រព្យមួយចំនួនខាងក្រោមអាចរាប់បញ្ចូលជាទ្រព្យសម្បត្តិរួមៈ

- ✓ ទ្រព្យដែលកើតចេញពីការងារៈ វាអាចជាប្រាក់ចំណូល ប្រាក់បុព្វលាភ សោហ៊ុយ ប្រាក់សោធននិវត្តន៍ និង/ឬប្រាក់ចំណូលផ្សេងៗទៀតដែលកើតចេញពីកម្លាំងពលកម្ម និងសកម្មភាពស្របច្បាប់របស់សហព័ទ្ធតែម្ខាង ឬទាំងសងខាង។ ត្រូវចាត់ទុកថាជាទ្រព្យរួម ទោះបីជាធ្វើការងាររួមគ្នា ឬបែកគ្នាក្តី ឬការងារប្រភេទណាក៏ដោយ ព្រោះថាការរកបាននោះគឺក្នុងគោលបំណងផ្គត់ផ្គង់ប្រយោជន៍ជីវភាពគ្រួសារ។
- ✓ ទ្រព្យដែលកើតចេញពីការគ្រប់គ្រងទ្រព្យសម្បត្តិរួម ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនៈ ទ្រព្យដែលកើតចេញពីទ្រព្យរួមត្រូវចាត់ទុកថាជាទ្រព្យរួម ព្រោះវាជាផលប្រយោជន៍រួម។ ឯផលដែលកើតចេញពីទ្រព្យដោយឡែកក្នុងករណីនេះ ក៏ត្រូវចាត់ទុកជាទ្រព្យរួមដែរ ដែលវាអាចជាផលធម្មជាតិ និងផលស៊ីវិល។ ផលធម្មជាតិ គឺជាចំណីទាំងឡាយណាដែលកើតឡើងដោយឯកឯងតាមធម្មជាតិដូចជា ដើមឈើ និងសត្វជាដើម។ ឯផលស៊ីវិល គឺជាចំណូលដែលផ្តល់តាមរយៈការគ្រប់គ្រងដោយប្រយោលនូវទ្រព្យសម្បត្តិដូចជាប្រាក់ឈ្នួលផ្ទះ ឬការប្រាក់ជាដើម។
- ✓ ទ្រព្យដែលទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ៈ ក្រៅពីទ្រព្យដែលកើតចេញពីកម្លាំងរបស់សហព័ទ្ធទាំងសងខាងធ្វើការរួមគ្នា គឺជាទ្រព្យដែលពួកគេទទួលបានរួមគ្នាជាប្រទានកម្ម អច្ច័យទាន ឬសន្តតិកម្មក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍។ មានន័យថាវាអាស្រ័យលើឆន្ទៈអ្នកឱ្យ ត្រង់ថាឱ្យដល់ទាំងពីរនាក់។ ជាមួយគ្នានេះដែរ តម្លៃកំណើនដែលកើតចេញពីទ្រព្យដោយឡែក ដែលមានប្រភពជាការខិតខំប្រឹងប្រែងទាំងពីរនាក់ក៏ត្រូវបានចាត់ទុកថាជាទ្រព្យរួមដែរ។

[29] មាត្រា៩៧៣ ក្រមរដ្ឋប្បវេណី (២០០៧)

### ២.១.៣ ការទទួលខុសត្រូវចំពោះប្រាក់បំណុលរបស់តតិយជន

ការទទួលខុសត្រូវចំពោះប្រាក់បំណុលរបស់តតិយជន ពាណិជ្ជករអាចត្រូវបានប្តឹងទៅតុលាការដោយម្ចាស់បំណុលក្នុងករណីមិនសងប្រាក់ ឱ្យមានការជម្រះបញ្ជីទ្រព្យសម្បត្តិ និងការស្តារលទ្ធភាពតាមផ្លូវតុលាការ។ សម្រាប់បណ្តឹងឱ្យសងប្រាក់តបទៅនឹងអ្នកទិញមិនមែនជាពាណិជ្ជករដែលមិនអនុវត្តកាតព្វកិច្ច គឺមានអាជ្ញាយុកាល៥ឆ្នាំ។ ឯពាណិជ្ជករត្រូវចាត់ចែងយ៉ាងរហ័សនូវការកំណត់អាជ្ញាយុកាលដ៏ខ្លី គឺ២ឆ្នាំចំពោះរឿងពាណិជ្ជកម្ម។ ក្នុងករណីដែលម្ចាស់បំណុលប្តឹងទាមទារ ស្ត្រីត្រូវប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិដែលខ្លួនយកមកចាត់ចែងក្នុងសកម្មភាពពាណិជ្ជកម្ម។ ប្រសិនបើស្ត្រីយកប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកមកប្រើប្រាស់ តតិយជនអាចធ្វើការប្តឹងទាមទារបានតែចំពោះស្ត្រីនោះប៉ុណ្ណោះ គឺមិនអាចប្តឹងទៅសហព័ទ្ធរបស់ស្ត្រីបានទេ។ ផ្ទុយមកវិញប្រសិនបើស្ត្រីប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិរួមមកចាត់ចែងក្នុងពាណិជ្ជកិច្ច តតិយជនអាចធ្វើការប្តឹងទៅស្ត្រីឱ្យទូទាត់ ហើយស្ត្រីអាចពិភាក្សាជាមួយប្តីអំពីរឿងនោះ។ តែបើតាមការអនុវត្តជាក់ស្តែង ប្តីភាគច្រើនតែងតែជួយដល់ប្រពន្ធក្នុងរឿងនេះ។ មូលហេតុនោះគឺ ស្ត្រីធ្វើការប្រកបរបរពាណិជ្ជកម្មឡើងក៏ព្រោះតែជួយរកចំណូលគ្រួសារផងដែរ។ មួយវិញទៀត ការភ្ជាប់ចំណងអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធ គឺតែងតែសម្តែងនូវចំណងមនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នា ដែលវាជាហេតុធ្វើឱ្យប្តីជួយជ្រោមជ្រែងប្រពន្ធ ទោះបីប្រពន្ធយកប្រព័ន្ធទ្រព្យសម្បត្តិណាមកប្រើប្រាស់ក៏ដោយ។

### ២.១.៤ ការចុះបញ្ជីពាណិជ្ជកម្ម

ដូចគ្នាទៅនឹងស្ត្រីមិនទាន់រៀបការជាពាណិជ្ជករដែរ ជាកាតព្វកិច្ច ស្ត្រីដែលរៀបការរួចត្រូវទៅចុះបញ្ជីពាណិជ្ជកម្ម ដើម្បីទទួលបានលក្ខណៈសម្បត្តិជាពាណិជ្ជករមួយរូប។ ស្ត្រីដែលរៀបការរួច ត្រូវចុះបញ្ជីដោយឡែកពីប្តីរបស់ខ្លួន។ ការចុះបញ្ជីពាណិជ្ជកម្មនេះត្រូវធ្វើឡើងឱ្យបានមុនយ៉ាងតិចបំផុតរយៈពេល១៥ថ្ងៃ មុនពេលចាប់ផ្តើមពាណិជ្ជកម្មរបស់ខ្លួន ដោយចុះនៅកន្លែងដែលធ្វើអាជីវកម្ម។

គួរចងចាំថា បច្ចុប្បន្នស្ត្រីរៀបការរួចជាពាណិជ្ជករអាចធ្វើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម។

ពាណិជ្ជករដែលមានប្រាក់ចំណេញប្រចាំឆ្នាំមិនលើសពី ០៦លានរៀលមិនចាំបាច់ធ្វើការចុះបញ្ជីទេ[30]។ ទោះបីជាយ៉ាងនេះក៏ដោយ ពាណិជ្ជករមិនជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មនៅតែមានកាតព្វកិច្ចសុំលិខិតអនុញ្ញាតប្រកបរបរអាជីវកម្ម និងសេវាកម្មពីមន្ទីរពាណិជ្ជកម្មខេត្តក្រុង។

[30] មាត្រា ២០ ច្បាប់ស្តីពីសារពើពន្ធ (១៩៩៧)

ក្រសួងពាណិជ្ជកម្មបានកំណត់ថា គ្រប់អាជីវកម្ម សេវាកម្ម គ្រប់ក្រុមហ៊ុនដែលមិនជាប់ពន្ធលើប្រាក់ចំនេញ ឬមិនជាប់កាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ត្រូវមានកាតព្វកិច្ចមកសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មសេវាកម្មពីមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង។ ការដាក់ពាក្យសុំធ្វើលិខិតអនុញ្ញាតនេះ ត្រូវសុំនៅមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ដែលកន្លែងអាជីវកម្មនោះតាំងនៅ។ លិខិតអនុញ្ញាតមានសុពលភាព១ឆ្នាំ ហើយអាចត្រូវបន្តថ្មីក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរមុនពេលផុតកំណត់លិខិតអនុញ្ញាតនេះ។

ចំពោះទណ្ឌកម្មនានាពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មនេះ ស្ត្រីដែលរៀបការរួចក៏ត្រូវទទួលនូវការពិន័យផ្សេងៗទៅតាមច្បាប់ដូចជាស្ត្រីនៅក្រមុំជាពាណិជ្ជករដែរ។

ជារួម ត្រង់ចំណុចនៃការចុះបញ្ជីពាណិជ្ជកម្មនេះ ស្ត្រីដែលរៀបការរួចជាពាណិជ្ជករ ត្រូវប្រតិបត្តិចំណុចទាំងឡាយដូចជាស្ត្រីនៅលីវដែរ គ្រាន់តែធ្វើយ៉ាងណាចុះបញ្ជីដោយឡែកពីប្តី ដើម្បីកុំឱ្យមានភាពស្មុគស្មាញ។

### ២.១.៥ ការគ្រប់គ្រងអាជីវកម្ម: ករណីស្វាមីជាពាណិជ្ជករ ឬ/និងភរិយាជាពាណិជ្ជករ

សម័យបច្ចុប្បន្ននេះ ក្រោយពីសិទ្ធិស្ត្រីត្រូវបានទទួលស្គាល់ជាងមុន នាំឱ្យបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ស្ត្រីពុំសូវមានគំនាបក្នុងការស្វែងរកមុខរបរឯករាជ្យមួយទេ។ ជាក់ស្តែង ស្ត្រីអាចធ្វើការប្រកបរបរពាណិជ្ជកម្មបានទៅតាមគំនិត ទៅតាមឆន្ទៈរបស់ខ្លួន ប៉ុន្តែក៏ត្រូវធ្វើការគោរពតាមទម្លាប់សង្គមខ្លះៗដែរ។ ក្នុងករណីនេះ សម្រាប់ការចាប់ផ្តើម និងដំណើរការសកម្មភាពអាជីវកម្មរបស់ខ្លួន ស្ត្រីត្រូវសួរយោបល់ពីស្វាមីរបស់ខ្លួនដែរ។ ដោយឡែកក្នុងករណីដែលស្ត្រីមានស្វាមីជាពាណិជ្ជករដែរ ស្ត្រីជាពាណិជ្ជករ និងស្វាមីត្រូវបង្ហាញការគោរពទៅកាន់គ្នា ពេលត្រូវចេះសួរយោបល់គ្នាទៅវិញទៅមក។ ភរិយា ឬស្វាមីអាចក្លាយជាពាណិជ្ជករដូចគ្នាបាន ដោយធ្វើការគ្រប់គ្រងតាមរយៈការជ្រើសរើសរបបទ្រព្យសម្បត្តិដោយឡែក ហើយទទួលខុសត្រូវរៀងៗខ្លួនទៅលើសកម្មភាពនានាដែលខ្លួនបាននឹងកំពុងធ្វើប្រតិបត្តិការ។

#### ២.១.៥.១ ការអនុវត្តសកម្មភាពពាណិជ្ជកម្មដាច់ដោយឡែក

គឺស្វាមីពុំអាចលូកដៃចូលក្នុងកិច្ចការរបស់ភរិយាបាន ហើយភរិយាក៏មិនអាចលូកដៃចូលក្នុងកិច្ចការប្តីបានឡើយ ប្រសិនបើទាំងស្វាមី ទាំងភរិយាជាពាណិជ្ជករដូចគ្នា ដោយយោងលើគោលការណ៍ទ្រព្យសម្បត្តិដោយឡែក។ សហព័ទ្ធនីមួយៗមានកាតព្វកិច្ចទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនរៀងៗខ្លួន ដោយពុំមានពាក់ព័ន្ធដល់សហព័ទ្ធមួយទៀតឡើយ។ ជារួម ការដែលសហព័ទ្ធមួយៗអាចក្លាយជាពាណិជ្ជករទាំងពីរបាន គឺទាមទារការចុះបញ្ជីពាណិជ្ជកម្មដាច់ដោយឡែកពីគ្នា។

### ក លក្ខខណ្ឌអនុវត្តសកម្មភាពដាច់ដោយឡែក

មានលក្ខខណ្ឌពីរសំខាន់ៗ ដែលស្ត្រីជាពាណិជ្ជករត្រូវតែគោរព នៅពេលដែលស្ត្រីនោះចង់ប្រកបមុខរបរពាណិជ្ជកម្មផ្សេងពីស្វាមីរបស់ខ្លួន។

លក្ខខណ្ឌទីមួយ គឺមានចែងនៅក្នុងមាត្រា៦ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥។ មាត្រានេះបានចែងថា សហព័ទ្ធនៃពាណិជ្ជករ ត្រូវចាត់ទុកជាពាណិជ្ជករដែរ បើសហព័ទ្ធនោះប្រកបមុខរបរពាណិជ្ជកម្ម ដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្មដោយឡែក ហើយការយល់ព្រមពីសហព័ទ្ធ ត្រូវមានការចាំបាច់ សម្រាប់ពាណិជ្ជកម្មនោះ។ នេះជាលក្ខខណ្ឌដាច់ខាត ដែលសហព័ទ្ធនីមួយៗត្រូវតែគោរព។ អត្ថប្រយោជន៍នៃការចុះបញ្ជីដោយឡែកនេះមានច្រើនរួមមាន ការបង្ហាញពីសិទ្ធិស្ត្រីថាមានការគាំទ្រជាជំហាន ព្រោះវាបានកំណត់នូវលក្ខណៈសម្បត្តិជាពាណិជ្ជកររបស់ស្ត្រីផ្សេងពីស្វាមីរបស់ខ្លួន។ ការគ្រប់គ្រង និងកាន់កាប់បញ្ជីពាណិជ្ជកម្មជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។ គួរបញ្ជាក់ផងដែរថា ស្ត្រីត្រូវធ្វើការប្តឹងសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវធ្វើមុនពេលធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនយ៉ាងតិចឱ្យបាន១៥ថ្ងៃ នៅទីកន្លែងដែលអាជីវកម្មតាំងនៅ។ យើងតាមមាត្រា១៤ នៃច្បាប់ដដែល ពាណិជ្ជករត្រូវបំពេញព័ត៌មានមួយចំនួនដូចខាងក្រោម៖

- ✓ នាមត្រកូល និងនាមខ្លួនរបស់ពាណិជ្ជករ និងលេខនៃលិខិតអត្តសញ្ញាណរបស់ខ្លួន
- ✓ មានប្រើប្រាស់ក្នុងពាណិជ្ជកម្ម ឬរហ័ស្សនាម
- ✓ ថ្ងៃ ខែ ឆ្នាំ ឬទីកន្លែងកំណើត ព្រមទាំងអសយដ្ឋានផ្ទាល់ខ្លួន
- ✓ សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀត ត្រូវបញ្ជាក់អំពីបែបបទ និងថ្ងៃ ខែ ឆ្នាំដែលបានទទួលសញ្ជាតិនេះ
- ✓ កម្មវត្ថុពាណិជ្ជកម្ម
- ✓ ទីកន្លែងធ្វើអាជីវកម្មនិងអសយដ្ឋានគ្រឹះស្ថាន ឬសាខានៃមូលនិធិពាណិជ្ជកម្ម ដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា
- ✓ ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន និងហត្ថលេខាគម្រូរបស់សាមីខ្លួន ព្រមទាំងស្នាមត្រាគម្រូ
- ✓ លិខិតអត្តសញ្ញាណប័ណ្ណរបស់អ្នកតំណាងពេញសិទ្ធិ ដែលទទួលរ៉ាប់រងក្នុងការសុំចុះបញ្ជីពាណិជ្ជកម្ម
- ✓ គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកបានស្នើសុំធ្វើអាជីវកម្មពីមុន ឬគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើកំពុងធ្វើអាជីវកម្មក្នុងរង្វង់សមត្ថកិច្ចក្រសួងពាណិជ្ជកម្ម

- ✓ សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃក្នុងកិច្ចការពាណិជ្ជកម្ម
- ✓ ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឱ្យប្រកបមុខរបរចំពោះមុខរបរណា ឬចំពោះកម្មវត្ថុពាណិជ្ជកម្មណាដែលតម្រូវឱ្យមានលិខិតអនុញ្ញាត។

ឯមន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិជ្ជកម្ម ដោយប្រគល់ប្រតិវេទន៍នេះមួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនដល់អ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលក្នុងបញ្ជីរួចហើយ"។

ក្នុងករណីមានការផ្លាស់ប្តូរ ឬកែប្រែនូវចំណុចណាមួយខាងលើ ក៏ត្រូវតែមានការចុះបញ្ជីដែរ ហើយត្រូវបញ្ជ្រាបឱ្យអតិថិជនបានដឹងឮតាមរយៈការបិទផ្សាយជាសាធារណៈ។ ប្រសិនបើមិនបានចុះបញ្ជីតាមកាលបញ្ញត្តិ នាំឱ្យការប្រកបរបរពាណិជ្ជកម្មនេះមិនស្របច្បាប់ ហើយត្រូវផ្តន្ទាទោសទៅតាមបញ្ញត្តិនៃមាត្រា៩០ នៃច្បាប់ដដែល។

លក្ខខណ្ឌទីពីរ សហព័ទ្ធដែលចង់ក្លាយជាពាណិជ្ជករ ត្រូវធ្វើការប្រកាសទ្រព្យសម្បត្តិរបស់ខ្លួន។ ដូចដែលបានជ្រាបរួចមកហើយថា ប្រព័ន្ធទ្រព្យសម្បត្តិត្រូវបានបែងចែកជាពីរប្រភេទ គឺប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។ នេះបើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ គូរស្វាមីភរិយាអាចធ្វើការចុះកិច្ចសន្យាទ្រព្យសម្បត្តិជាមួយគ្នាក៏បានដែរ ដែលកិច្ចសន្យានេះអាចកំណត់ពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុខ ឬក្រោយអាពាពិពាហ៍បាន។ យ៉ាងណាមិញ ការចុះកិច្ចសន្យាទ្រព្យសម្បត្តិនេះ ពុំទាន់មានភាពពេញនិយមនៅឡើយទេ។

ពាណិជ្ជករដែលរៀបអាពាហ៍ពិពាហ៍រួច អាចទទួលបាននូវអត្ថប្រយោជន៍ និងភាពងាយស្រួលពីការចុះកិច្ចសន្យាទ្រព្យសម្បត្តិនេះ ព្រោះវាបានបង្កើនូវទំនាក់ទំនងរវាងម្ចាស់បំណុល និងកូនបំណុល។ នេះមានន័យថា ប្រសិនបើសហព័ទ្ធណាមួយក្លាយជាកូនបំណុល ហើយបានចុះកិច្ចសន្យាទ្រព្យសម្បត្តិជាមួយសហព័ទ្ធម្ខាងទៀត ម្ចាស់បំណុលអាចធ្វើការទាមទារបានតែពីកូនបំណុលរបស់ខ្លួនតែប៉ុណ្ណោះ គឺមិនអាចទាមទារពីសហព័ទ្ធរបស់កូនបំណុលខ្លួនបានទេ។ ជារួម កិច្ចសន្យាទ្រព្យសម្បត្តិនេះ បានដើរតួជាលក្ខខណ្ឌកំណត់នូវកម្រិតនៃការទទួលខុសត្រូវចំពោះគ្រប់បំណុលទាំងឡាយ ដែលកម្រិតត្រឹមតែទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងៗប៉ុណ្ណោះ។ ការចុះកិច្ចសន្យាទ្រព្យសម្បត្តិជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌ជាអ្នកមានតួនាទីតម្កល់ទុកនូវបញ្ជី។

ទោះបីជាយ៉ាងណាក៏ដោយ គេពុំសូវមានការចាប់អារម្មណ៍ទៅលើការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធប៉ុន្មានទេ។ តែផ្ទុយមកវិញ ប្តីប្រពន្ធភាគច្រើន បានជ្រើសរើសយកការបែងចែកទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ដែលត្រូវបានបែងចែលជាពីរ គឺប្រព័ន្ធទ្រព្យសម្បត្តិរួម និង

ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក។ នេះអាចបង្ហាញឱ្យដឹងថា ប្រសិនបើស្ត្រីចង់ក្លាយជាពាណិជ្ជករ ស្ត្រីត្រូវធ្វើការជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិឱ្យបានច្បាស់លាស់ ដើម្បីមានភាពងាយស្រួលក្នុងការចាត់ចែងក្នុងសកម្មភាពពាណិជ្ជកម្មរបស់គាត់។ ការដែលជ្រើសរើសឱ្យបានច្បាស់លាស់នេះ មានសារៈសំខាន់ដល់ ត្រង់ថាស្ត្រីធ្វើឱ្យប្រាកដថា ខ្លួនយកទ្រព្យសម្បត្តិដោយឡែកទៅធ្វើអ្វី ហើយទ្រព្យរួមយកទៅធ្វើអ្វី។ បើស្ត្រីយកទ្រព្យសម្បត្តិដោយឡែកទៅប្រើប្រាស់មិនមានបញ្ហាទេ តែត្រូវមានការឯកភាពពីសហព័ទ្ធចំពោះការយកទ្រព្យសម្បត្តិរួមទៅប្រើប្រាស់ក្នុងប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន។

### ខ ការអនុវត្តតាមលក្ខណៈបីយ៉ាង

ដើម្បីដឹងថាលក្ខណៈសម្បត្តិជាពាណិជ្ជកររបស់ស្ត្រីយ៉ាងណាទៀត ក្នុងករណីដែលនាងចូលរួមជាមួយស្វាមីរបស់នាង យើងនឹងធ្វើការសិក្សាទៅលើសមត្ថកម្មដែលយើងជួបប្រទះចំនួនបីដូចខាងក្រោម។

#### ខ.១ ភរិយាចាត់ចែងក្រោមការដឹកនាំត្រួតពិនិត្យរបស់ស្វាមី ហើយស្វាមីអនុវត្តពាណិជ្ជកម្មពិតប្រាកដ

នៅក្នុងសង្គមខ្មែរ មុនពេលដែលមានមុខមាត់ស្ត្រីចេញធ្វើអាជីវកម្ម គឺបុរសបានចេញមុខយ៉ាងពេញទំហឹងក្នុងកិច្ចការនេះ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺ បច្ចុប្បន្ននេះមានទាំងស្វាមីភរិយាជាពាណិជ្ជករ ឬភរិយាជាពាណិជ្ជករ ហើយស្វាមីមិនមែន ឬក៏ស្វាមីជាពាណិជ្ជករ ហើយភរិយាគ្រាន់តែជាអ្នកជួយ។ ក្នុងករណីដែលស្វាមីបានបានដើរតួជាអ្នកគ្រប់គ្រងចាត់ចែងសកម្មភាពពាណិជ្ជកម្ម រួមទាំងការទទួលខុសត្រូវនានាចំពោះសកម្មភាពរបស់ខ្លួន មានន័យថាស្វាមីជាអ្នកដើរតួជាពាណិជ្ជករមួយរូប។ ភរិយាពុំទទួលបានលក្ខណៈជាពាណិជ្ជករទេ ព្រោះស្វាមីជាអ្នកដឹកនាំគ្រប់គ្រង និងត្រួតពិនិត្យទាំងស្រុងលើប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន។

ស្វាមីមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងមុខរបរពាណិជ្ជកម្មរបស់ខ្លួនដូចខាងក្រោម៖

- ✓ ស្វាមីត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្ម ក្នុងនាមជាពាណិជ្ជកររូបវន្តបុគ្គល ហើយធ្វើការផ្សព្វផ្សាយជាសាធារណៈតាមសារព័ត៌មានស្របច្បាប់នានា អំពីព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពអាជីវកម្មឱ្យអ្នកប្រើប្រាស់ និងសាធារណៈជនបានដឹង។ នេះបើយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥។
- ✓ គ្រប់គ្រងអាជីវកម្មរបស់ខ្លួនដូចជា ការទំនាក់ទំនងជាមួយអតិថិជន ការចុះកិច្ចសន្យាជាមួយអតិថិជន ការស្វែងរកទីផ្សារដោយខ្លួនឯង រួមទាំងសកម្មភាពផ្សេងៗទៀត។

- ✓ ត្រូវតែមានគណនីមួយនៅក្នុងធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគោរពតាមវិធានគណនេយ្យ[31]
- ✓ ចំពោះកាតព្វកិច្ចសារពើពន្ធ ស្វាមីដែលជាពាណិជ្ជករ ត្រូវតែបង់ពន្ធទៅលើពន្ធអាជីវកម្ម អាករលើតម្លៃបន្ថែម និងពន្ធលើប្រាក់ចំណេញជាដើម។

យើងអាចយល់បានថា ក្នុងករណីនេះ ស្ត្រីគ្រាន់តែជាជំនួយរបស់ស្វាមីប៉ុណ្ណោះ ព្រោះស្វាមីបានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តពាណិជ្ជកិច្ចរបស់ខ្លួន។ ស្ត្រី ត្រង់ចំណុចនេះ មិនអាចចាត់ទុកថាជាពាណិជ្ជករទេ។ ឬក៏យើងអាចនិយាយបានថា ភរិយាគឺជានិយោជិតរបស់ស្វាមីខ្លួន ខណៈដែលស្វាមីខ្លួនគឺជានិយោជក។

### ខ.២ ភរិយាអនុវត្តពាណិជ្ជកម្មពិតប្រាកដ ហើយស្វាមីជាជំនួយការ

ផ្ទុយពីសម្មតកម្មនៃចំណុចខាងលើ ពេលនេះ ស្ត្រីដើរតួជាពាណិជ្ជករ ខណៈពេលដែលស្វាមី គឺជាជំនួយការរបស់នាង។ យ៉ាងណាមិញ ស្វាមីរបស់ស្ត្រីក៏អាចមានអាជីពមួយដោយឡែកផងដែរក្រៅពីធ្វើជាជំនួយការដល់ភរិយា។

ស្ត្រីដើរតួជាម្ចាស់អាជីវកម្មផ្ដាច់មុខ ហើយជាអ្នកដឹកនាំ គ្រប់គ្រង និងចាត់ចែងសកម្មភាពពាណិជ្ជកិច្ចក្នុងនាមខ្លួនតែម្នាក់ឯង។ ដើម្បីក្លាយខ្លួនជាពាណិជ្ជករ ស្ត្រីត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ✓ ជាកម្មសិទ្ធិករលើមូលនិធិពាណិជ្ជកម្ម
- ✓ មានតួនាទីសក្ដានុពលក្នុងការគ្រប់គ្រង
- ✓ ចុះឈ្មោះក្នុងសៀវភៅបញ្ជីពាណិជ្ជកម្ម
- ✓ មិនអនុញ្ញាតឱ្យស្វាមីគ្រប់គ្រងនូវផ្នែកណាមួយនៃអាជីវកម្មទេ។

លក្ខខណៈជាពាណិជ្ជកររបស់ស្ត្រីដែលស្ត្រីទទួលបាន បានតម្រូវឱ្យស្ត្រីគោរពនូវរាល់សិទ្ធិ និងកាតព្វកិច្ចដែលមានចែងនូវក្នុងច្បាប់ជាធរមាន ដើម្បីធានាឱ្យបានក្នុងនាមជាពាណិជ្ជករមួយរូប។

### ខ.៣ ស្វាមីភរិយាបង្កើតអាជីវកម្មរួមមួយពិតប្រាកដ

រួមបញ្ចូលនូវចំណុចទាំងពីរខាងលើ មានសមត្ថកម្មមួយទៀត គឺភរិយា និងស្វាមីរួមគ្នាបង្កើតអាជីវកម្មមួយពិតប្រាកដ។ ស្វាមី និងភរិយារួមដៃរួមជើងគ្នាយ៉ាងពេញទំហឹងក្នុងការធ្វើឱ្យសកម្មភាពពាណិជ្ជកម្មមានប្រតិបត្តិការរីកចម្រើនលូតលាស់ទៅមុខ។ ភរិយាអាចសន្យារួមជាមួយ

[31] មាត្រា៩៨ ច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

នឹងស្វាមី ដើម្បីអនុវត្តកិច្ចការនៅពេលស្វាមីអវត្តមាន ហើយអាចចុះហត្ថលេខាលើកិច្ចសន្យាលើផលប័ត្រពាណិជ្ជកម្ម។ ភរិយា ក្នុងករណីនេះ ត្រូវបានចាត់ទុកថាជាអាណត្តិគាហកៈមួយរូបតែប៉ុណ្ណោះ ដែលទទួលបានសិទ្ធិអំណាចមួយចំនួនដើម្បីចាត់ចែងការងារ ដោយស្វាមីជាអាណត្តិទាយក។ ភរិយាមិនអាចក្លាយជាពាណិជ្ជករបានទេ ឯស្វាមីទើបជាពាណិជ្ជករ ពីព្រោះថាភរិយាគ្រាន់តែជួយកិច្ចការប្តីខ្លះៗតែប៉ុណ្ណោះ។ ថ្វីបើបែបនេះក៏ដោយ យើងអាចសង្កេតលើគោលការណ៍សំខាន់ៗពីរដែលបង្ហាញពីលក្ខណៈសម្បត្តិរបស់ភរិយា។ គោលការណ៍ទីមួយ គឺគោលការណ៍អនុវត្តស្មើដៃស្មើជើងរវាងស្វាមី និងភរិយាដោយចូលរួមក្នុងសកម្មភាពយ៉ាងសកម្មដូចគ្នា ពោលមានភាពស្មើគ្នាក្នុងការគ្រប់គ្រងប្រតិបត្តិការពាណិជ្ជកម្មក្នុងក្រុមហ៊ុនមួយចំនួនដូចជា ក្រុមហ៊ុនសហកម្មសិទ្ធិជាដើម។ ការធ្វើបែបនេះ នាំឱ្យស្វាមីភរិយាគឺជាសហកម្មសិទ្ធិករទូទៅទទួលបានលក្ខណៈសម្បត្តិជាពាណិជ្ជករ។ រីឯគោលការណ៍ទីពីរវិញ គឺភរិយាត្រូវបានចាត់ទុកថាជាជំនួយការរបស់ស្វាមី ព្រោះស្វាមីអនុវត្តសកម្មភាពតែម្នាក់ឯង។ ចពោះករណីនេះ ភរិយាមិនទទួលខុសត្រូវលើប្រាក់បំណុល និងសកម្មភាពផ្សេងៗក្នុងសកម្មភាពពាណិជ្ជកម្មទេ។

### គ សហាព័ទ្ធជាពាណិជ្ជករព្រមព្រៀងលើបេតិកភណ្ឌ

ដូចបានរំឭកជារឿយៗថា ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ប្រព័ន្ធទ្រព្យសម្បត្តិត្រូវបានបែងចែកជាពីរ គឺប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។ វាពិតជាចាំបាច់ដែលសហាព័ទ្ធណាម្នាក់សម្រេចចិត្តជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិណាមួយមកធ្វើការប្រើប្រាស់ក្នុងការធ្វើអាជីវកម្ម គឺអាចរើសប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ឬក៏ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់ ទៅតាមដែលគាត់គិតថាវាមានភាពងាយស្រួល និងមានគុណសម្បត្តិប៉ុណ្ណាខ្លះ។ របបទ្រព្យសម្បត្តិទាំងពីរនេះ មានលក្ខណៈពិសេសដោយឡែកពីគ្នា ហើយមានសារៈប្រយោជន៍របស់វារៀងៗខ្លួន ខណៈដែលវាមានលក្ខណៈខុសគ្នាដាច់ស្រឡះ។

ប្រសិនបើសហាព័ទ្ធណាមួយធ្វើការជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិ ដោយឡែកមកចាត់ចែងក្នុងមុខរបរពាណិជ្ជកម្ម សហាព័ទ្ធម្នាក់ៗមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិនោះ។ នេះក៏ព្រោះតែទ្រព្យសម្បត្តិដោយឡែកគឺជាកម្មសិទ្ធិរបស់សហាព័ទ្ធតែម្ខាងប៉ុណ្ណោះ។ សហាព័ទ្ធអាចប្រើប្រាស់ដោយពុំចាំបាច់មានការពិភាក្សា ឬការយល់ព្រមពីពីសហាព័ទ្ធម្ខាងទៀតទេ ព្រោះសហាព័ទ្ធនោះមានសិទ្ធិផ្តាច់មុខដែលបានកំណត់ដោយច្បាប់រួចទៅហើយ។ សហាព័ទ្ធដែលជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកនោះ មានអំណាចពេញលេញ ដោយអាចយកទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនទៅប្រើប្រាស់តាមតម្រូវការ ដូចជាអាចយកទៅដាក់ហ៊ីប៉ូតែក ឬដាក់បញ្ចាំជាដើម។

ដោយឡែក ប្រសិនបើសហព័ទ្ធណាម្នាក់ជ្រើសរើសយកទ្រព្យរួមមកធ្វើពាណិជ្ជកម្ម ត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត[32] ព្រោះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ ចំពោះប្រព័ន្ធទ្រព្យសម្បត្តិរួមនេះ ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រងឱ្យបានល្អ ព្រមទាំងត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមក ជាពិសេសត្រូវចេះពិភាក្សាគ្នាក្នុងការគ្រប់គ្រងថែរក្សា។ ហេតុនេះ រាល់ការយកទៅប្រើប្រាស់ក្នុងរបរពាណិជ្ជកម្ម ត្រូវតែមានការពិភាក្សាគ្នាឱ្យបានច្បាស់លាស់ជាមុនសិន។

### គ.១ ការស្វែងយល់ពីទ្រព្យក្នុងការអនុវត្តសកម្មភាពពិតប្រាកដមួយដោយខ្លួនឯង

ដើម្បីឱ្យអាជីវកម្មមានភាពរីកសម្រើនទៅមុខ វាទាមទារឱ្យមានការយល់ស្រប ការជ្រោមជ្រែង និងលើកទឹកចិត្តពីសហព័ទ្ធម្ខាងទៀត។ វាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាជាកម្លាំងចិត្តក្នុងការប្រកបមុខរបរពាណិជ្ជកិច្ច ជាពិសេសជាកត្តាដែលនាំឱ្យមានការកើនឡើងទាំងទ្រព្យរួម និងទ្រព្យដោយឡែក។ ភាពជោគជ័យក្នុងកិច្ចការពាណិជ្ជកម្មរបស់សហព័ទ្ធម្ខាង ក៏កើតឡើងពីជំនួយកម្លាំងកាយ កម្លាំងចិត្ត និងផ្នែកស្មារតីរបស់សហព័ទ្ធម្ខាងទៀតផងដែរ។ ក្រៅពីនេះ ការចេះយោគយល់អាធ្យាស្រ័យ និងចូលរួមរវាងស្វាមីភរិយាចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរួម និងដោយឡែក ពិតជាវិសេសវិសាលណាស់ ព្រោះកាលណាសហព័ទ្ធទាំងសងខាងប្រើប្រាស់ការយល់ដឹងដើម្បីគ្រប់គ្រង វាអាចធ្វើឱ្យមានការចាត់ចែងបានល្អប្រសើរ ហើយមានកំណើននៃទ្រព្យសម្បត្តិនៅក្នុងគ្រួសារ។ ជារួម ការគ្រប់គ្រងទ្រព្យសម្បត្តិដោយប្រាជ្ញាញាណរបស់ស្វាមីភរិយា គឺជាកត្តាដែលនាំឱ្យប្រតិបត្តិការពាណិជ្ជកម្មមានភាពល្អប្រសើរ ហើយកំណើននៃទ្រព្យសម្បត្តិជាប្រភពមួយផ្នែកនៃភាពសុខុដុមរមនាផងដែរ។

### គ.២ អត្ថប្រយោជន៍ទទួលបានរបស់សហព័ទ្ធនីមួយៗ

ការមានភាពច្បាស់លាស់ក្នុងការសម្រេចចិត្តរើសយក ប្រព័ន្ធទ្រព្យសម្បត្តិណាមួយដែលសហព័ទ្ធម្ខាងយកមកប្រើប្រាស់នៅក្នុងសកម្មភាពពាណិជ្ជកម្ម គឺវាពិតជាមានសារៈសំខាន់ណាស់ចំពោះពាណិជ្ជកម្មនោះ ព្រោះសហព័ទ្ធនីមួយៗមិនអាចត្រូវបានរឹបអូសទ្រព្យសម្បត្តិរបស់ខ្លួនដោយម្ចាស់បំណុលរបស់សហព័ទ្ធម្ខាងទៀតឡើយ ដូចជាទៅលើ ប្រាក់ចំណេញ ប្រាក់បៀវត្ស ឬប្រាក់លាភការនានា។ បើតាមទំនៀមទម្លាប់ខ្មែរ ដែលប្រជាជនគោរពប្រតិបត្តិតៗគ្នា ទោះបីជាវាគឺជាអត្ថប្រយោជន៍មួយពីការមិនរឹបអូសទ្រព្យសម្បត្តិរបស់សហព័ទ្ធម្ខាងទៀតក៏ដោយ ក៏ប៉ុន្តែសហព័ទ្ធទាំងសងខាងអាចជួយគ្នាទៅវិញទៅមក ព្រោះយ៉ាងណាមិញអ្នកទាំងពីរមានមនោសញ្ចេតនាជាប្តី

[32] មាត្រា៩៧៦ ក្រមរដ្ឋប្បវេណី (២០០៧)

ប្រពន្ធដែលរួមរស់ជាមួយគ្នា[33]។ ម្យ៉ាងវិញទៀត វាជាចំណងនៃក្ដីស្រឡាញ់របស់ប្ដីប្រពន្ធចំពោះគ្នាទៅវិញទៅមក។ ទាំងនេះក៏ដោយសារតែប្ដីប្រពន្ធមិនអាចមើលឃើញទាំងស្រុងអំពីបញ្ហាដែលអាចនឹងកើតមានក្នុងប្រតិបត្តិការពាណិជ្ជកម្មបានដែរ។ ដូច្នេះ ដើម្បីអាចចូលរួមដោះស្រាយឧបសគ្គហើយបន្តសកម្មភាពពាណិជ្ជកម្ម ឬក៏ត្រូវបញ្ឈប់ត្រឹមណានោះ និងទទួលបានអត្ថប្រយោជន៍នានាសហព័ទ្ធនីមួយៗត្រូវធ្វើការគិតឱ្យបានល្អិតល្អន់ជាមុន មុននឹងសម្រេចរើសយកប្រព័ន្ធទ្រព្យសម្បត្តិណាមួយមកចាត់ចែង។

## ២.១.៥.២ ការអនុវត្តសកម្មភាពពាណិជ្ជកម្មរួមដោយសហព័ទ្ធទាំងពីរ

នៅពេលដែលស្ត្រីធ្វើការជាមួយប្ដី របស់ខ្លួន មានឋានៈពីរដែលស្ត្រីអាចជ្រើសរើសបាន គឺជាកម្មករ ឬសមាជិកហ៊ុន។ កម្មករ ឬសមាជិកហ៊ុននេះហៅថា សហការិនី ដែលវាអាចកើតឡើងពេលដែលស្ត្រីធ្វើការតាមលក្ខខន្តិកៈជាមួយប្ដីរបស់ខ្លួន។ មួយវិញទៀតប្ដីអាចជាពាណិជ្ជករ ហើយប្រពន្ធជាពាណិជ្ជករ ប្រសិនបើអ្នកទាំងពីរបានចុះបញ្ជីពាណិជ្ជកម្មទៅតាមនីតិវិធីដែលច្បាប់កំណត់។ យើងអាចសួរថា តើស្ត្រីចង់បានឋានៈមួយណាដែលខ្លួនពេញចិត្ត ឬយ៉ាងណា។

ក្នុងករណីដែលស្ត្រីជ្រើសរើសលក្ខណៈសម្បត្តិជាកម្មករ នាំឱ្យគាត់មិនមានកាតព្វកិច្ចដូចប្ដីរបស់គាត់ទេ ពោលគាត់មិនត្រូវជាប់ពន្ធដូចប្ដី ហើយគាត់ត្រូវទទួលបានរបបសង្គមកិច្ច ប្រាក់បៀវត្ស និងធានារ៉ាប់រងសុខភាពជាដើម។ ប៉ុន្តែ ប្រសិនបើស្ត្រីជ្រើសរើសយកឋានៈជាសមាជិកហ៊ុនវិញ នោះស្ត្រីនឹងទទួលបានលក្ខណៈសម្បត្តិជាពាណិជ្ជករ ដែលនាំឱ្យគាត់មានកាតព្វកិច្ចដូចប្ដីរបស់គាត់ដែរ គឺត្រូវទទួលខុសត្រូវលើប្រយោជន៍ខាងពន្ធ ដោយបង់ពន្ធចំពោះសារពើពន្ធទាំងឡាយ។

### ក លក្ខន្តិកៈរបស់សហប្រតិបត្តិករ

យើងនឹងធ្វើការយកចិត្តទុកដាក់ទៅលើចំណុចចំនួនបីរួមមាន លក្ខខណ្ឌអនុវត្ត ផលវិបាកនៃសង្គមកិច្ច និងការដកខ្លួនចេញរបស់សហព័ទ្ធដែលនៅរស់ជាសហការិនី ដើម្បីសិក្សាពីលក្ខន្តិកៈរបស់សហប្រតិបត្តិករ។

#### ក.១ លក្ខខណ្ឌអនុវត្ត

សមត្ថកម្មទីមួយៈ បើស្ត្រីជាពាណិជ្ជករក្នុងករណីដែលគាត់ទទួលបានលក្ខណៈសម្បត្តិតាមរយៈសហព័ទ្ធរបស់គាត់ដែលជាម្ចាស់សហគ្រាស គឺគាត់ត្រូវទទួលបាននូវកិច្ចសន្យាអាណត្តិដើម្បីបំពេញកិច្ចការក្នុងនាមប្ដីរបស់គាត់។ នេះសបញ្ជាក់ឱ្យឃើញថា ស្ត្រីមិនមែនអនុវត្តពាណិជ្ជកិច្ចក្នុង

---

[33] មាត្រា៩៦៦ ក្រមរដ្ឋប្បវេណី (២០០៧)

នាមផ្ទាល់ខ្លួនទេ។ ស្ត្រីពេលនេះមានឋានៈជាអាណត្តិគាហកៈ ហើយត្រូវធ្វើតាមកិច្ចសន្យាអាណត្តិរហូតដល់រយៈពេលដែលបានសន្មតនៅក្នុងកិច្ចសន្យាថាបញ្ចប់កិច្ចសន្យាអាណត្តិនេះ។ កិច្ចសន្យាអាណត្តិត្រូវធ្វើឡើងចំពោះមុខសាការី រវាងអាណត្តិគាហកៈ និងអាណត្តិទាយក ហើយត្រូវតែចុះបញ្ជី និងចុះផ្សាយជាសាធារណៈ ដើម្បីឱ្យតតិយជនបានដឹងឮអំពីកិច្ចសន្យានេះ ព្រមទាំងអាចធ្វើការតតាំងផងដែរ។

សមត្ថកម្មទីពីរៈ ប្រសិនបើស្ត្រីជាពាណិជ្ជករ គាត់ត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្ម។ វាគឺជាកាតព្វកិច្ចសំខាន់បំផុត ដែលស្ត្រីត្រូវតែធ្វើការចុះបញ្ជីពាណិជ្ជកម្ម ព្រោះវាបានផ្តល់ឱ្យស្ត្រីនូវបុគ្គលភាពគតិយុត្ត គឺស្ត្រីមានលក្ខណៈសម្បត្តិជាពាណិជ្ជករ ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ចទៅតាមផ្លូវច្បាប់។ នៅពេលដែលក្លាយជាពាណិជ្ជករ ស្ត្រីត្រូវតែជួយដល់ការងាររបស់សហព័ទ្ធដែលជាម្ចាស់សហគ្រាសដោយមិនគិតយកប្រាក់ឈ្នួលទេ។ ស្ត្រីមានកាតព្វកិច្ចអនុវត្តការងារតែចំពោះសហគ្រាសដែលគាត់កំពុងតែជួយតែប៉ុណ្ណោះ ពោលមិនអាចទៅអនុវត្តសកម្មភាពវិជ្ជាជីវៈផ្សេងៗទៀតឡើយ។

សមត្ថកម្មទីបីៈ ប្រសិនបើស្ត្រីជាកម្មករ គាត់មិនតម្រូវឱ្យមានការចុះបញ្ជីដូចពាណិជ្ជករ និងសិប្បករទេ។ កាតព្វកិច្ចរបស់ស្ត្រីជាកម្មករគឺត្រូវចុះកិច្ចសន្យាការងារជាមួយម្ចាស់សហគ្រាស។ ករណីនេះ ពេលដែលគាត់ធ្វើការជាមួយប្តីរបស់គាត់ដែលជាម្ចាស់សហគ្រាសនោះ ប្តីរបស់គាត់ត្រូវតែផ្តល់ថ្លៃឈ្នួល និងអត្ថប្រយោជន៍នានាដល់ប្រពន្ធរបស់គាត់ក្នុងឋានៈជាកម្មករមួយរូប។ អាស្រ័យទៅតាមការកំណត់ដោយច្បាប់ សហព័ទ្ធជាប្តីត្រូវតែធ្វើការបើកប្រាក់ឈ្នួលទៅឱ្យប្រពន្ធរបស់គាត់តាមទំហំការងារដែលបានធ្វើ។ ស្ត្រីត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកលំហែរមាតុភាពផងដែរដោយទទួលបានប្រាក់បៀវត្សពាក់កណ្តាល បូករួមទាំងប្រាក់បន្ទាប់បន្សំ[34] ជាពិសេសទទួលបាននូវការផ្គត់ផ្គង់ផ្នែកសង្គមកិច្ច និងសេវាធានារ៉ាប់រង។ យ៉ាងណាមិញ ប្តីប្រាកដជាយល់ច្បាស់ពីការអនុញ្ញាតឱ្យឈប់លំហែរមាតុភាព ព្រោះគភ៌ក្នុងផ្ទៃគឺជាកូនរបស់គាត់។ រីឯប្រាក់លាភការនានាដែលកើតចេញពីប្រាក់ចំណេញរបស់សហគ្រាស ប្តីក៏ត្រូវផ្តល់ចំណែកដែលប្រពន្ធត្រូវទទួលបានផងដែរ។

សមត្ថកម្មទីបួនៈ ប្រសិនបើស្ត្រីជាសិប្បករ គាត់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងចុះបញ្ជីនៅក្នុងនៅមន្ទីឧស្សាហកម្ម រ៉ែ និងថាមពលដែលខ្លួនបោះទីតាំងក្នុងរយៈ ០៧ថ្ងៃក្រោយថ្ងៃធ្វើដំណើរការ លើកលែងតែប្រភេទសិប្បកម្មដែលកំណត់ដោយប្រកាស

[34] មាត្រា១៨៣ ច្បាប់ការងារ (១៩៩៧)

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល[35] ដើម្បីក្លាយទៅជាសិប្បករពេញច្បាប់។ គាត់មានកាតព្វកិច្ចដូចគ្នានឹងពាណិជ្ជករដែរ ខុសត្រង់ទីកន្លែងចុះបញ្ជីតែប៉ុណ្ណោះ។ កាលណាគាត់មានលក្ខណៈសម្បត្តិជាសិប្បករហើយ គាត់ត្រូវចូលរួមជួយធ្វើការជាមួយប្ដីរបស់គាត់ដែលជាម្ចាស់សិប្បកម្មដោយមិនគិតប្រាក់អ្វីឡើយ។ លើសពីនេះ ស្ត្រីដែលមានលក្ខណៈសម្បត្តិជាសិប្បករមិនត្រូវបានអនុញ្ញាតឱ្យទៅធ្វើការអ្វីផ្សេងទៀតទេ។ សិប្បករក៏មានឋានៈជាអាណត្តិគាហកៈដែរ ព្រោះគាត់ទទួលការងារពីម្ចាស់សិប្បកម្មដើម្បីបំពេញ ក្រោយពីគាត់បានធ្វើកិច្ចសន្យាអាណត្តិជាមួយប្ដីដែលជាអាណត្តិទាយក។ ដូចគ្នាទៅនឹងអាណត្តិគាហកៈជាពាណិជ្ជករដែរ គឺត្រូវធ្វើរហូតដល់ពេលចប់ដូចដែលមានចែងក្នុងកិច្ចសន្យាអាណត្តិ។ កិច្ចសន្យាអាណត្តិនេះ ត្រូវចុះបញ្ជី និងផ្សព្វផ្សាយជាសាធារណៈដើម្បីឱ្យតតិយជនបានជ្រាប ហើយងាយស្រួលនឹងធ្វើការប្ដឹងទាស់ចំពោះកិច្ចសន្យានេះ។

### ក.២ ផលប្រយោជន៍នៃសង្គមកិច្ច

ការធានាបានខាងផ្នែកសុខភាព សោធននិវត្តន៍សម្រាប់ពេលចាស់ជរា និងប្រាក់សោធនកាលាទិករណ៍ ត្រូវបានផ្ដល់ទៅដល់សហព័ទ្ធជាសហការិនី ព្រោះវាជាផលខាងសង្គមកិច្ច។ ផលខាងសង្គមកិច្ចគឺជាការធ្វើឱ្យល្អប្រសើរខាងផ្នែកសង្គមកិច្ច ដែលវាត្រូវមានការព្រមព្រៀងដោយសហព័ទ្ធជាម្ចាស់សហគ្រាស។ យោងតាមមាត្រា៦ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ បានកំណត់ថាដើម្បីទទួលបានផលប្រយោជន៍ផ្នែកសង្គមកិច្ច សហព័ទ្ធត្រូវធ្វើការបង់វិភាគទានខាងផ្នែកសន្តិសុខសង្គម។ ឯការកំណត់អត្រានៃការបង់វិភាគទាននេះត្រូវបានកំណត់ដោយមាត្រា១ នៃប្រកាសស្ដីអំពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារឆ្នាំ២០០៨។ ប្រយោជន៍នានាខាងលើដែលគាត់ត្រូវទទួលបាន គឺមានប្រសិទ្ធិភាពនៅថ្ងៃទីមួយនៃខែតាមប្រតិទិនបន្ទាប់ពីសហការិនីបានបំពេញបែបបទរួចហើយដោយត្រឹមត្រូវ។ សាមីខ្លួនអាចដាក់ពាក្យស្នើសុំទៅកាន់បេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលដប់ពីរខែ រួចគាត់អាចទទួលបានផលប្រយោជន៍ខាងសុខភាពមួយចំនួនទៀតដូចជាការផ្គត់ផ្គង់ឱសថ ការព្យាបាល ការថែរក្សាជាដើម[36]។ ចំណែកឯស្ត្រីដែលមានលក្ខណៈសម្បត្តិជាកម្មករវិញ ដើម្បីទទួលបានផលប្រយោជន៍នៅពេលមានហានិភ័យខាងផ្នែកសុខភាព និងគ្រោះថ្នាក់ដែលកើតឡើងដោយយថាហេតុពេលកំពុងបំពេញការងារ

---

[35] មាត្រា ២៣ ច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម (២០០៦)

[36] មាត្រា៨ និង១៦ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ (២០០២)

ទោះបណ្តាលមកពីកំហុសរបស់ខ្លួន ឬមិនមែនក៏ដោយ ក៏ត្រូវបង់វិភាគទានឱ្យផ្នែកសន្តិសុខសង្គមដែរ។ នេះបើយោងតាមមាត្រា១២ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារឆ្នាំ២០០២។

### ក.៣ ការដកខ្លួនចេញរបស់សហព័ទ្ធដែលនៅរស់ជាសហការិនី

ដោយសារនៅប្រទេសយើងពុំទាន់មានលិខិតបទដ្ឋាន ច្បាប់ ឬយុត្តិសាស្ត្រណាដែលបានកំណត់អំពីបញ្ហានេះនៅឡើយទេ វាហាក់បីដូចជាពិបាកក្នុងការសិក្សាបន្តិច។ ថ្វីបើយ៉ាងនេះក៏ដោយ ក៏យើងអាចធ្វើការពិចារណាតាមរយៈការអនុវត្តជាក់ស្តែង និងតាមសៀវភៅមួយរបស់បារាំង[37]បានផងដែរ។

ការដកខ្លួនចេញរបស់សហព័ទ្ធដែលនៅរស់ជាសហការិនី អាចចេញដោយមូលហេតុមួយចំនួនដូចខាងក្រោម៖

- ✓ ស្ត្រីជាសហការិនី អាចចេញដោយសារតែសហព័ទ្ធរបស់ខ្លួនដកចេញពីសហគ្រាស
- ✓ សហព័ទ្ធជាស្ត្រី នៅពេលដែលគាត់គិតថា គាត់ខិតខំធ្វើការយ៉ាងសកម្មដោយផ្ទាល់ក្នុងរយៈពេលជាច្រើនឆ្នាំ ហើយពុំទទួលបានប្រាក់បៀវត្ស ប្រាក់ចំណេញ ឬសូម្បីតែចូលរួមខាតបង់នានា គាត់អាចដកខ្លួនចេញបាន

ក្រៅពីសិទ្ធិលើបំណុលក្រុមហ៊ុន សហការិនីមានសិទ្ធិជាម្ចាស់បំណុលលើក្រុមហ៊ុន ដែលនាំឱ្យគាត់ទទួលបាន២៥% នៃប្រាក់ចំណេញប្រចាំឆ្នាំ។ បន្ថែមលើនេះ ស្ត្រីអាចទទួលបានប្រាក់បៀវត្សបីដងនៃប្រាក់ខែអប្បរមាដោយគិតចាប់ពីថ្ងៃធ្វើការដល់ថ្ងៃស្លាប់ គឺត្រូវបន្ថែមទៅដល់សហព័ទ្ធដែលនៅរស់ ឬទៅកាន់សន្តតិកម្ម។ ដោយឡែក សហការិនីជាកម្មករវិញ ត្រូវទទួលបានប្រាក់បៀវត្សបីដងនៃប្រាក់ខែអប្បរមា ព្រមទាំងសិទ្ធិលើបំណុល ហើយទ្រព្យសកម្មត្រូវថែម២៥% នៃទ្រព្យសកម្មទៅក្នុងសន្តតិកម្ម ដោយចាប់គិតពីថ្ងៃធ្វើការ ដល់ថ្ងៃគ្រោះថ្នាក់ ឬថ្ងៃទទួលមរណភាព។

## ខ លក្ខន្តិកៈរបស់សហព័ទ្ធជាកម្មករ

### ខ.១ លក្ខខណ្ឌអនុវត្ត

ក្នុងនាមជាកម្មករម្នាក់ សហការិនីត្រូវធ្វើការយ៉ាងម៉ត់ចត់បំផុត ដោយត្រូវមានកិច្ចសន្យាការងាររវាងស្វាមីនិងភរិយាដើម្បីចៀសវាងឱ្យបាននូវកំហុសដែលកើតឡើង។ កិច្ចសន្យាការងារនេះ ត្រូវតែមានកំណត់ពីចំណងទាក់ទងអាណត្តិ ដែលនាំឱ្យម្ចាស់គ្រប់គ្រងបញ្ជា និងត្រួតពិនិត្យលើ

[37] Michel de JUGLART និង Benamin IPPOLITO, *Cours de droit commercial*, Editor: MONTCHRESTIEN (1992), ទំព័រ២៦៨

កម្មករ។ ឯការចូលរួមការងារក្នុងសហគ្រាសរបស់កម្មករ ត្រូវធ្វើទៅតាមអ្វីដែលសហគ្រាសបានកំណត់ ពោលគឺត្រូវធ្វើទៅតាមវិជ្ជាជីវៈជំនាញ ព្រមទាំងធ្វើជាប្រចាំ។ ជាមួយគ្នានេះដែរ មិនខុសពីកម្មករដទៃទៀត កម្មករត្រូវតែទទួលបានកម្រៃទៅតាមសមត្ថភាពជំនាញរបស់គាត់ បូករួមទាំងប្រាក់ឧបត្ថមផ្សេងៗទៀត ដែលទាំងនេះជាការឆ្លើយតបចំពោះការងារដែលគាត់បានធ្វើឱ្យម្ចាស់សហគ្រាស។

## ខ.២ ផលប្រយោជន៍ផ្នែកសង្គមកិច្ច និងសារពើពន្ធ

យោងតាមច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារឆ្នាំ២០០២ បានកំណត់ពីផលវិបាកផ្នែកសង្គមកិច្ចរបស់កម្មករដូចខាងក្រោម។

ត្រង់មាត្រា៤ នៃច្បាប់នេះបានចែងថា ជនទាំងឡាយដែលត្រូវដាក់បញ្ចូលឱ្យនៅក្នុងរបបសន្តិសុខសង្គមតាមច្បាប់នេះមានដូចជា កម្មករនិយោជិកទាំងអស់ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ ប្រសិនបើជនទាំងនោះធ្វើការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍សម្រាប់និយោជិកម្នាក់ ឬច្រើននាក់ដោយមិនគិតដល់ប្រភេទ ទម្រង់ និងសុពលភាពនៃកិច្ចសន្យា ឬប្រភេទ និងចំនួននៃប្រាក់ឈ្នួលដែលជននោះបានធ្វើ ឬបានទទួលឡើយ។ អាស្រ័យតាមបញ្ញត្តិនេះ នាំឱ្យសហព័ទ្ធជាកម្មករទទួលបានផលប្រយោជន៍នានាដូចតទៅៈ

- ✓ សោធនជរាភាព វិភាជន៍ជរាភាព សោធនទុព្វលភាព សោធនចំពោះអ្នកនៅក្នុងបន្ទុក និងវិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក
- ✓ ប្រាក់ផ្នែកហានិភ័យការងារចំនួនបីប្រភេទដូចជា គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងការធ្វើដំណើរ និងជម្ងឺវិជ្ជាជីវៈ។

បន្ថែមពីនេះ ម្ចាស់សហគ្រាសជាអ្នកដែលមានបន្ទុករ៉ាប់រងដល់សហព័ទ្ធជាកម្មករនៅពេលសម្រាកមាតុភាព ដោយផ្តល់ប្រាក់ខែតាមច្បាប់កំណត់។

កម្មករត្រូវបង់ពន្ធជូនរដ្ឋតាមចំនួនប្រាក់បៀវត្ស និងតាមការកំណត់របស់ច្បាប់ ដែលការបង់ពន្ធនេះសហគ្រាសត្រូវធ្វើការចាត់ចែង។

# គ លក្ខន្តិកៈរបស់សហព័ទ្ធជាសមាជិកហ៊ុន

## គ.១ លក្ខខណ្ឌអនុវត្ត

ជាករណីដែលប្តីប្រពន្ធធ្វើការស្មើដៃស្មើជើងនៅក្នុងអាជីវកម្មមួយ។ សហព័ទ្ធទាំងពីរចូលរួមធ្វើការដោយផ្ទាល់យ៉ាងសកម្ម ហាក់បីដូចជាសហគ្រាសមួយដែលមានសមាជិកតែពីររូប។ ម៉្យាង

ទៀត វាដូចជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលនាំឱ្យសមាជិកហ៊ុនមានលក្ខណៈសម្បត្តិជាកម្មសិទ្ធិករទូទៅ (ឋានៈជាពាណិជ្ជករ)។ យោងតាមមាត្រា៦ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥ បានចាត់ទុកសហព័ទ្ធរបស់ពាណិជ្ជករជាពាណិជ្ជករផងដែរ ប្រសិនបើមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ក្នុងករណីដែលសហព័ទ្ធនោះប្រកបរបរពាណិជ្ជកម្មដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្ម។ វាសម្តែងឱ្យឃើញថា បើបានចុះបញ្ជីពាណិជ្ជកម្ម ហើយប្រកបមុខរបរមួយជាក់លាក់ និងជាប្រចាំ និងមានការចុះបញ្ជី នាំឱ្យសហព័ទ្ធរបស់ពាណិជ្ជករ អាចក្លាយជាពាណិជ្ជករ។ ស្ត្រីជាសហព័ទ្ធត្រូវជូនដំណឹងដល់សហព័ទ្ធម្ខាងទៀតជាប្តីពីការប្រកបមុខរបររបស់គាត់ ខណៈពេលដែលគាត់ត្រូវធ្វើការចុះបញ្ជីដោយឡែក។ មានករណីពីរដែលអាចកំណត់ពីប្រភេទជាពាណិជ្ជកររបស់សហព័ទ្ធជាស្ត្រី។ ករណីទីមួយ គឺស្ត្រីអាចក្លាយជាពាណិជ្ជករតាមអំពើ ប្រសិនបើគាត់មិនបានចុះបញ្ជីពាណិជ្ជកម្ម តែគាត់បានធ្វើសកម្មភាពអាជីវកម្មជាប្រចាំ។ ឯករណីទីពីរ គឺស្ត្រីគឺជាពាណិជ្ជករតាមនីតិ នៅពេលដែលគាត់បានចុះបញ្ជីពាណិជ្ជកម្មរួចរាល់អស់តាមការកំណត់របស់ច្បាប់។ ទាំងនេះ វាអាស្រ័យទៅលើការជ្រើសរើសរបស់ស្ត្រីខ្លួនឯង ឬតាមរយៈការពិភាក្សាជាមួយស្វាមី។ ដោយឡែក ស្ត្រីជាពាណិជ្ជករដែលចុះបញ្ជីដោយឡែក ក៏ត្រូវគិតទៅលើទ្រព្យសម្បត្តិផងដែរ គឺត្រូវតែចុះបញ្ជីដោយឡែកពីសហព័ទ្ធរបស់គាត់ ក្នុងគោលបំណងចៀសវាងនូវវិវាទ ឬបញ្ហាដែលអាចនឹងកើតមានឡើងចំពោះស្ត្រីនោះនៅពេលណាមួយខាងមុខ។ សហព័ទ្ធទាំងសងខាង ត្រូវមានកាតព្វកិច្ចសាមគ្គីគ្នាទៅវិញទៅមកចំពោះ ការដោះស្រាយប្រាក់បំណុលរបស់ក្រុមហ៊ុនដោយមិនមានកម្រិត។ មិនតែប៉ុណ្ណោះ សហព័ទ្ធទាំងសងខាងក៏មានសិទ្ធិលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទាំងចលនទ្រព្យ និងអចលនទ្រព្យ ហើយជាម្ចាស់បំណុលនៃក្រុមហ៊ុនផងដែរ។

### គ.២ ផលប្រយោជន៍ផ្នែកសង្គមកិច្ច និងសារពើពន្ធ

មុននឹងធ្វើការសិក្សាទៅលើចំណុចចំនួនពីរផ្សេងគ្នា គឺទៅលើសហព័ទ្ធជាសមាជិកហ៊ុនជាកម្មករ និងសហព័ទ្ធជាសមាជិកហ៊ុនមិនមែនជាកម្មករ។ វាមានភាពផ្សេងគ្នា រវាងស្ត្រីដែលមានលក្ខណៈពីរប្រភេទផ្សេងគ្នានេះ ចំពោះកាតព្វកិច្ចផ្នែកពន្ធ និងផលប្រយោជន៍សង្គមកិច្ច។

ស្ត្រីដែលមានលក្ខណៈជាសមាជិកហ៊ុនជាកម្មករ ទទួលបានឋានៈជាកម្មករដែរ។ ការដែលមានឋានៈជាកម្មករនេះ វាបានបណ្តាលឱ្យកើតនូវចំណងទាក់ទងអាណត្តិរវាងក្រុមហ៊ុន និងកម្មករ ដែលករណីនេះ ធ្វើឱ្យសហព័ទ្ធជាស្ត្រី និងជាសមាជិកហ៊ុនជាកម្មករត្រូវតែទទួលបានប្រាក់បៀវត្សប្រាក់បន្ថែមនានា ព្រមទាំងទទួលបានរបបផ្នែកសង្គមកិច្ចសម្រាប់ហានិភ័យដែលអាចនឹងកើតមាននាពេលអនាគត។ ដោយឡែក សហព័ទ្ធជាសមាជិកហ៊ុនដែលមិនមែនជាកម្មករអាចទទួលបាន

ធានារ៉ាប់រងនៅពេលចាស់ជរា ធានារ៉ាប់រងខាងជម្ងឺ ការលំហែរមាតុភាព និងរបបវិភាជន៍គ្រួសាររបស់ពលករឯករាជ្យ។ នេះសំដៅទៅដល់សមាជិកហ៊ុនដែលទាក់ទងនឹងរបបពលករមិនមែនជាកម្មករ ហើយមានមុខរបរមិនមែនជាកសិកម្ម។ ចំណែកឯរបបសារពើពន្ធវិញ សហាព័ទ្ធមិនមែនជាកម្មករត្រូវបង់ដូចគ្នានឹងសហកម្មសិទ្ធិករទូទៅដែរដោយឈរក្នុងនាមជាពាណិជ្ជករ។ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ជាអ្នកកំណត់អំពីការបង់នេះ។

ប្រសិនបើមានបញ្ហា ក្រុមហ៊ុន ឬសហគ្រាសត្រូវស្ថិតនៅក្រោមក្រុមហ៊ុនជម្រះបញ្ជីទ្រព្យសម្បត្តិ ដែលអាចធ្វើទៅលើសហាព័ទ្ធទាំងសងខាងដូចជាធ្វើទៅលើពាណិជ្ជករដទៃដែរ។ នេះគឺធ្វើក្នុងករណីដែលក្រុមហ៊ុន ឬសហគ្រាសដែលបង្កើតឡើងដោយសហាព័ទ្ធទាំងពីរមិនបានសងប្រាក់បំណុលរបស់ខ្លួន។

## ២.២ ករណីលែងលះ

នៅក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ហើយប្រកបមុខរបរពាណិជ្ជកម្ម ប្តីប្រពន្ធអាចសហការគ្នាបានយ៉ាងល្អក្នុងការធ្វើប្រតិបត្តិការក៏ថាបាន ដោយអាស្រ័យទៅលើការចេះគ្រប់គ្រងដឹកនាំសកម្មភាព បូករួមនឹងសមត្ថភាពបង្កើត និងថែរក្សាសុភមង្គលក្នុងគ្រួសាររបស់សហាព័ទ្ធទាំងពីរ។ ទោះបីយ៉ាងណាក៏ដោយ ក៏ស្ត្រីជាពាណិជ្ជករមួយចំនួននៅតែឈានដល់ការលែងលះគ្នាជាមួយស្វាមី បន្ទាប់ពីមានបញ្ហានៅក្នុងដំណើរការអាជីវកម្មផ្ទាល់ ឬមានបញ្ហាអ្វីមួយនៅក្នុងក្រុមគ្រួសារដែលអាចកើតឡើងដោយសារតែមូលហេតុមួយចំនួន។ មូលហេតុមួយចំនួនដែលធ្វើឱ្យស្ត្រីជាពាណិជ្ជករ ឬគ្រាន់តែជាសហការិនី ឬមិនមែនឈានទៅដល់ការលែងលះជាមួយស្វាមីជាពាណិជ្ជករ ឬមិនមែនមានដូចតទៅ៖

- ✓ បើបានប្រព្រឹត្តិអំពើផិតទៅលើសហាព័ទ្ធម្ខាងទៀត
- ✓ បើបានបោះបង់សហាព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ
- ✓ បើមិនដឹងច្បាស់លាស់ថាសហាព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាងមួយឆ្នាំ
- ✓ បើសហាព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាងមួយឆ្នាំ ផ្ទុយនឹងគោលបំណងអាពាហ៍ពិពាហ៍
- ✓ ករណីផ្សេងទៀតដែលចំណងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថាអាចនឹងបដិទានឡើងវិញបាន។[38]

[38] មាត្រា៩៧៨ ក្រមរដ្ឋប្បវេណី (២០០៧)

តាមរយៈមូលហេតុក្នុងរឿងពាណិជ្ជកម្មផ្ទាល់ដូចជាការក្ស័យធនជាដើម ឬមូលហេតុខាងលើដែលបណ្ដាលឱ្យប្ដីប្រពន្ធឈានដល់ការប្ដឹងផ្ដល់លែងលះ ប្ដី ឬប្រពន្ធអាចដាក់ពាក្យបណ្ដឹងលែងលះគ្នាទៅកាន់តុលាការបាន។ កាលណាពាក្យបណ្ដឹងបានទៅដល់តុលាការហើយ តុលាការមានឆន្ទានុសិទ្ធិក្នុងការចាត់ការទៅលើពាក្យបណ្ដឹងនេះទៅតាមនីតិវិធី ដែលមានកំណត់ក្នុងច្បាប់ជាធរមាន ពោលគឺទៅកាន់តុលាការជំនាញរដ្ឋប្បវេណីរបស់សាលាដំបូងដែលមានទីតាំងនៅកន្លែងដែលកើតមានវិវាទ[39]។ ពេលមានការលែងលះ ស្ត្រីជាពាណិជ្ជករ និងសហព័ទ្ធត្រូវធ្វើការដោះស្រាយទាំងទ្រព្យសម្បត្តិ ទាំងបំណុល ដែលបំណុលត្រូវបានរាប់ជាទ្រព្យអកម្ម។

### ២.២.១ សាលក្រមរបស់តុលាការ

មុននឹងចេញសាលក្រមស្ដាពរឆ្លើយតបទៅកាន់បណ្ដឹងលែងលះរបស់ស្ត្រីជាពាណិជ្ជករ និងសហព័ទ្ធរបស់នាង តុលាការមានសមត្ថកិច្ចពិចារណាទៅលើស្ថានភាពមួយចំនួនសិន។ បើយោងទៅតាមមាត្រា៩៧៨ វក្សខណ្ឌ២ និង៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ពីលក្ខខណ្ឌដែលតុលាការអាចច្រានចោលបណ្ដឹងលែងលះបានដោយឆន្ទានុសិទ្ធិដូចខាងក្រោម៖

- ✓ ប្រសិនបើតុលាការយល់ឃើញថា ការលែងលះគ្នានោះនឹងបណ្ដាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូន ក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលមិនអាចទ្រាំទ្របាន
- ✓ ប្រសិនបើតុលាការយល់ឃើញថា ការទាមទារផ្ទុយនឹងភាពសុចរិត ដោយសហព័ទ្ធដែលទាមទារឱ្យលែងលះនោះមានការធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ

យ៉ាងណាមិញ តុលាការត្រូវធ្វើការពិចារណាទៅលើការព្រមព្រៀងរបស់សហព័ទ្ធជាពាណិជ្ជករ ឬមិនមែន ថាតើភាគីទាំងពីរមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងនៃអាពាហ៍ពិពាហ៍ដែរ ឬយ៉ាងណា។ សហព័ទ្ធទាំងសងខាងអាចដាក់ពាក្យបណ្ដឹងលែងលះ ក្នុងករណីដែលបានព្រមព្រៀងគ្នាសិន[40]។

សហព័ទ្ធអាចធ្វើការដាក់ពាក្យបណ្ដឹងសុំលែងលះគ្នា ទៅកាន់ក្រុមប្រឹក្សាឃុំសង្កាត់ខាងលំនៅឋាន ឬទីសំណាក់។ ក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទីធ្វើការបញ្ចូលផ្សះផ្សាឱ្យសះជាគ្នាបានក្នុងអំឡុងរយៈពេលដប់ប្រាំថ្ងៃ បន្ទាប់ពីទទួលពាក្យសុំ។ ប៉ុន្តែក្នុងករណីដែលមិនអាចផ្សះផ្សាគ្នាបាន ត្រូវចាត់ទុកថាមានបណ្ដឹងលែងលះ ហើយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យបណ្ដឹងនោះ

[39] មាត្រា១៤ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ (២០១៤)
[40] មាត្រា៩៧៩ ក្រមរដ្ឋប្បវេណី (២០០៧)

ទៅតុលាការជាបន្ទាន់។ នៅក្នុងដំណាក់កាលតុលាការនេះ ទោះបីជាមានការទាមទារយ៉ាងខ្លាំងពីសំណាក់ភាគីម្ខាងក៏ដោយ ក៏តុលាការត្រូវធ្វើការសាកល្បងផ្សះផ្សាសិនដែរ។ លុះណាតែពុំអាចសម្រេចការផ្សះផ្សាបាន ទើបតុលាការអាចយកបណ្តឹងលែងលះមកធ្វើការចាត់ការតាមនីតិវិធី។[41]

### ២.២.២ ការបែងចែកទ្រព្យសម្បត្តិ

វាអាស្រ័យលើការជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិ រួចហើយរបស់សហព័ទ្ធទាំងសងខាង ថាតើបានជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា ឬតាមប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ នៅមុនពេលដែលពួកគាត់បានឈានដល់ការលែងលះ។ ដូចនេះ ការបែងចែកទ្រព្យសម្បត្តិរបស់ពាណិជ្ជករក្រោយពេលលែងលះ គឺវាក៏អាស្រ័យទៅលើប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ពួកគេដែរ។ យើងនឹងធ្វើការសិក្សាចំពោះការបែងចែកទ្រព្យសម្បត្តិទៅលើករណីទាំងពីរនេះដូចខាងក្រោម។

#### ២.២.២.១ ការបែងចែកទ្រព្យសម្បត្តិចំពោះប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា

ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យា ប្រសិនបើប្តីប្រពន្ធបានជ្រើសរើសហើយ ប្តីប្រពន្ធត្រូវតែគោរពតាមលក្ខខណ្ឌ ឬខសន្យាដូចដែលមានចែងនៅក្នុងកិច្ចសន្យាទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ។ ការដែលប្តីប្រពន្ធត្រូវតែគោរពតាមអ្វីៗដែលបានកំណត់ក្នុងកិច្ចសន្យាចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យា ព្រោះវាមានលក្ខណៈដូចតែទៅនឹងប្រភេទកិច្ចសន្យាផ្សេងៗទៀតដែរ ដោយសារកិច្ចសន្យាកើតមានដូចជាអនុសញ្ញាមួយដែលតាមរយៈនេះ យ៉ាងហោចណាស់ត្រូវមានបុគ្គលពីរចូលរួម ដែលយើងហៅថា គូភាគីនៃកិច្ចសន្យា ហើយកិច្ចសន្យានាំឱ្យកើតនៅកាតព្វកិច្ចមួយចំនួនដូចជា ការបង្កើតសិទ្ធិ ការផ្ទេរសិទ្ធិ ឬការរំលត់សិទ្ធិ[42]។ អាស្រ័យហេតុនេះ ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធនឹងត្រូវមានការផ្ទេរសិទ្ធិ ឬរំលត់សិទ្ធិលើទ្រព្យសម្បត្តិនានានៅពេលដែលធ្វើការលែងលះដោយធ្វើការបញ្ចប់វា។ វាជាហេតុផលដែលនាំឱ្យកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវបានលុបចោល ពោលអានុភាពរបស់វាត្រូវបាត់បង់ ហើយនាំទៅដល់ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ។ ពេលខ្លះ ការបែងចែកទ្រព្យសម្បត្តិនេះមានការលំបាកដោយសារសហព័ទ្ធពុំបានព្រមព្រៀងគ្នាលើការបែងចែក និងសិទ្ធិគ្រប់គ្រងទៅលើទ្រព្យសម្បត្តិនោះ។ យើងមើលឃើញថា ទាំងសហព័ទ្ធជាពាណិជ្ជករ និងមិនមែនជាពាណិជ្ជករតែងតែចង់ទាមទារចំណែករបស់ខ្លួនឱ្យបានច្រើន

[41] មាត្រា៩៨៣ និង៩៨៤ ក្រមរដ្ឋប្បវេណី (២០០៧)

[42] ជិន វណ្ណារ៉ា, *នីតិកិច្ចសន្យា* , បោះពុម្ព ២០១៣, ទំព័រ ២៩

ជាងភាគីម្ខាងទៀត ដែលវានាំឱ្យតុលាការមានការពិបាកក្នុងការសម្រេច។ ផ្ទុយទៅវិញ វានឹងមានភាពងាយស្រួលនៅពេលដែលសហព័ទ្ធទាំងសងខាងបានព្រមព្រៀងគ្នា តាមគ្រប់លក្ខខណ្ឌទាំងអស់ដូចដែលបានចែងទុកមុននៅក្នុងកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយ តាមគោលការណ៍ សហព័ទ្ធត្រូវធ្វើការបែងចែកតាមការព្រមព្រៀងទាំងឡាយ ដែលបានកំណត់រួចនៅក្នុងកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធរបស់ខ្លួន ពោលគឺវាតែងតែបានកំណត់អំពីទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកច្បាស់លាស់រួចហើយ ដែលតុលាការគ្រាន់តែចេញសេចក្តីសម្រេចតាមអ្វីដែលមានចែងក្នុងកិច្ចសន្យាតែប៉ុណ្ណោះ។ តែអ្វីដែលជាកង្វល់នោះគឺ គ្រប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទាំងអស់មិនមែនសុទ្ធតែច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយទេ។ កិច្ចសន្យាមួយចំនួនតែងតែមានចន្លោះខ្វះខាត ដែលបង្កទៅជាវិវាទពាក់ព័ន្ធនឹងការបែងចែក។ ចំពោះករណីនេះ សហព័ទ្ធអាចប្តឹងទៅតុលាការឱ្យជួយធ្វើអន្តរាគមន៍បែងចែកជំនួសបាន ហើយចៅក្រមធ្វើការពិចារណា បែងចែកដោយគោរពឆន្ទៈរបស់គូភាគី និងខ្លឹមសារនៃកិច្ចសន្យាដែលបានព្រមព្រៀង។ សហព័ទ្ធត្រូវដាក់ពាក្យសុំលុបចោលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយលក្ខណ៍អក្សរ[43] ដោយភ្ជាប់មកជាមួយនឹងកិច្ចព្រមព្រៀង ឬការជូនដំណឹងអំពីការលែងលះ។

### ២.២.២.២ ការបែងចែកទ្រព្យសម្បត្តិចំពោះប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់

ដោយឡែក នេះគឺជាការបែងចែកទ្រព្យសម្បត្តិចំពោះសហព័ទ្ធដែលជ្រើសយកប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់កំណត់។ ដូចដែលបានដឹងរួចមកហើយថា ការលែងលះជាមូលហេតុមួយនាំការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ យើងឃើញថា សហព័ទ្ធដែលបានជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់អាចធ្វើការបែងចែកតាមរយៈរូបភាពពីរគឺ តាមរយៈការព្រមព្រៀងរបស់សហព័ទ្ធ និងតាមសេចក្តីសម្រេចរបស់តុលាការ។ តាមរយៈការព្រមព្រាងរបស់សហព័ទ្ធ ភាគីទាំងសងខាងអាចធ្វើការព្រមព្រៀងគ្នាបែងចែកដោយមិនគិតថា ភាគីណាមួយបានចំណែកច្រើនជាងខ្លួននោះឡើយ។ ការបែងចែកនេះ ត្រូវធ្វើតាមការព្រមព្រៀងទុកជាមុន ហើយតុលាការនឹងធ្វើការសម្រេចតាមការព្រមព្រៀងនោះ។ ចំណែកឯការបែងចែកទ្រព្យសម្បត្តិត្រូវធ្វើតាមរយៈសេចក្តីសម្រេចរបស់តុលាការ គឺត្រូវធ្វើដោយតុលាការដែលមានសមត្ថកិច្ច នៅពេលចេញសាលក្រមលែងលះជាស្ថាពរ។ យោងតាមមាត្រា៩៨០ បានចែងថា តុលាការត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ដោយផ្អែកតាមការពិភាក្សារបស់សហព័ទ្ធទាំងសងខាង។ នេះមានន័យថា តុលាការត្រូវធ្វើ

[43] មាត្រា ៣០ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី (២០១១)

ការពិចារណាទាំងអស់ទៅលើទ្រព្យសម្បត្តិទាំងរួម ទាំងដោយឡែករបស់សហព័ទ្ធទាំងសងខាង ព្រមទាំងទ្រព្យសម្បត្តិនានាដែលជាមូលនិធិពាណិជ្ជកម្មផងដែរ ពោលគឺការបែងចែកត្រូវតែធ្វើឡើងដោយស្មើភាពរវាងស្វាមី និងភរិយា។ ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបាន ទើបត្រូវបែងចែកទ្រព្យសម្បត្តិដោយផ្អែកតាមចំណុចខាងក្រោមដូចតទៅ៖

- ✓ សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនដែលរួមមានដូចជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងនូវទ្រព្យសម្បត្តិខាងលើនេះ[44]
- ✓ សហព័ទ្ធនីមួយៗអាចទទួលបានមួយភាគពីរ (១/២) នៃទ្រព្យសម្បត្តិរួមក្នុងករណីមិនមានការទាមទារពីភាគីណាមួយ។ ប៉ុន្តែ ប្រសិនបើសហព័ទ្ធណាម្ខាងទាមទារ តុលាការអាចបែងចែកទ្រព្យសម្បត្តិរួមដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាដើម។ លើសពីនេះ តុលាការក៏ត្រូវពិចារណាទៅលើការងារក្នុងផ្ទះរបស់សហព័ទ្ធជាស្ត្រីដែរ ព្រោះទៅតាមច្បាប់វាមានតម្លៃដូចនឹងការងារក្រៅផ្ទះផងដែរ។

### ២.២.៣ របបអាហារកិច្ច

អាហារកិច្ចគឺជាករណីយកិច្ចដែលជនម្នាក់ត្រូវផ្គត់ផ្គង់ដល់ជនម្នាក់ទៀតនូវជីវភាព ដូចជា ចំណីអាហារ កន្លែងស្នាក់នៅ និងការថែទាំជាដើម។ អាហារកិច្ចត្រូវបានបែងចែកជាពីរគឺ អាហារកិច្ចចំពោះសហព័ទ្ធ និងអាហារកិច្ចចំពោះកូន។ គួររំឭកថា កាតព្វកិច្ចផ្តល់អាហារកិច្ច ក៏ដូចជាអំណាចមេបា វាអាចជាបន្ទុករបស់អ្នកដែលទទួលបានមូលនិធិពាណិជ្ជកម្មក្រោយពេលលែងលះ។ ប៉ុន្តែពេលនេះ យើងផ្តោតសំខាន់ទៅលើរបបអាហារកិច្ចតែប៉ុណ្ណោះ។

#### ២.២.៣.១ អាហារកិច្ចចំពោះសហព័ទ្ធ

បន្ទាប់ពីមានការលែងលះ ឬរំលាយចំណងអាពាហ៍ពិពាហ៍ ការឧបត្ថម្ភសហព័ទ្ធនៅតែជាករណីយកិច្ចរបស់សហព័ទ្ធ។ តាមរយៈការសង្កេតមើលជាក់ស្តែង យើងឃើញថាភាគច្រើនប្តីមាន

[44] មាត្រា៩៧២ ក្រមរដ្ឋប្បវេណី (២០០៧)

ករណីយកិច្ចឧបត្ថម្ភចំពោះប្រពន្ធ ឯករណីយប្រពន្ធជាអ្នកឧបត្ថម្ភពុំសូវមានទេ។ តែទោះជាយ៉ាងណាក៏ដោយ ស្ថិតនៅក្រោមច្បាប់ អ្នកទាំងពីរមានករណីយកិច្ចស្មើភាពគ្នា ព្រោះថាអ្នកទាំងពីរត្រូវមានការព្រមព្រាងលើប្រាក់អាហារកិច្ចសហព័ទ្ធ។ ប៉ុន្តែ បើគ្មានការព្រមព្រៀងទេ តុលាការជាអ្នកកំណត់។ អាហារកិច្ចអាចជាប្រាក់ ឬទ្រព្យសម្បត្តិ ដែលអាចចេញជាសរុប ឬមួយពេលៗទៅតាមលទ្ធភាព។

មានមូលហេតុចំនួនបីដែលសហព័ទ្ធអាចទទួលបាន ឬមិនទទួលបានអាហារកិច្ចៈ

- ✓ សហព័ទ្ធមានការខ្វះខាតៈ ភាគីដែលខ្វះខាតអាចស្នើសុំភាគីម្ខាងទៀតឱ្យផ្តល់ការឧបត្ថម្ភ
- ✓ កំហុសដែលរារាំងមិនឱ្យមានការផ្តល់អាហារកិច្ចៈ ច្បាប់ពុំបានកំណត់ច្បាស់លាស់ថាជាកំហុសប្រភេទ និងកម្រិតណាទេ។ ប៉ុន្តែ តុលាការអាចពិចារណាទៅលើមូលហេតុនៃការលែងលះរួមមាន ការចុះចោលលំនៅសង្វាស ការធ្វើទុកបុកម្នេញខាងផ្លូវចិត្ត ឬផ្លូវកាយ និងចរិយាផ្ទុយសីលធម៌
- ✓ លទ្ធភាពរបស់សហព័ទ្ធដែលផ្តល់ការឧបត្ថម្ភៈ សហព័ទ្ធ ឬតុលាការអាចពិចារណាពីលទ្ធភាពរកចំណូលរបស់សហព័ទ្ធនោះ ព្រមទាំងចំនួនបំណុល និងការចំណាយប្រចាំថ្ងៃជាដើម ដោយគិតថាតើសហព័ទ្ធដែលធ្វើការឧបត្ថម្ភនោះមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់ដែរ ឬទេ ជាពិសេសអាចបានតាមចំនួនដែលបានស្នើសុំដែរ ឬទេ?។

យ៉ាងណាមិញ ភាគីម្ខាងអាចធ្វើការសំណូមពរតុលាការឱ្យកែប្រែ បន្ថយ ឬបង្កើនអាហារកិច្ចបានដោយឈរលើគោលការណ៍លទ្ធភាពជាក់ស្តែង។ របបអាហារកិច្ចនេះ អាចមានថេរវេលាកំណត់ ឬមិនកំណត់អាស្រ័យលើសេចក្តីបង្គាប់របស់តុលាការ។ ករណីមានថេរវេលាកំណត់ របបអាហារកិច្ចអាចបញ្ចប់ទោតាមពេលវេលាដែលបានកំណត់។ ឯករណីមានថេរវេលាមិនកំណត់វិញ យើងមិនអាចកំណត់បានថាត្រូវបញ្ចប់នៅពេលណាទេ តែអាចបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលដែលសហព័ទ្ធរៀបអាពាហ៍ពិពាហ៍ថ្មី។

### ២.២.៣.២ អាហារកិច្ចចំពោះកូន

ដូចដែលយើងគ្រប់គ្នាបានដឹងហើយថា ឪពុកម្តាយគ្រប់រូបមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន។ ដោយហេតុនេះ ទោះបីជាមានការលែងលះក៏ដោយក៏សហព័ទ្ធទាំងសងខាងត្រូវបន្តកាតព្វកិច្ចនេះរហូតដល់កូនឈានដល់នីតិភាពដែរ។ ការចិញ្ចឹមបីបាច់ ផ្គត់ផ្គង់ក្រោយពេលលែងលះ គឺជាការផ្តល់អាហារកិច្ច ដែលការផ្តល់អាហារកិច្ចនេះ អាចធ្វើឡើងដោយការព្រមព្រៀងរវាងសហព័ទ្ធទាំងពីរ ឬតាមសេចក្តីសម្រេចរបស់តុលាការក្នុងករណីមិនមានការព្រមព្រៀង។

ការព្រមព្រៀងរបស់សហព័ទ្ធទាំងសងខាង គឺអាចជាការចេញប្រាក់ ឬការផ្គត់ផ្គង់ផ្សេងៗទៀតចំពោះកូន ដូចជាការទិញសំលៀកបំពាក់ និងការរៀនសូត្រជាដើម។ ជាមួយគ្នានេះដែរ តុលាការគោរពទៅលើ ការព្រមព្រៀងរបស់ភាគីទាំងសងខាងក្នុងការទទួលបានកូនទៅរស់នៅជាមួយ តែតុលាការក៏ពិចារណាទៅលើកត្តាលទ្ធភាពផងដែរ។

ដោយឡែក ការផ្តល់អាហារកិច្ចដល់កូនតាមសេចក្តីសម្រេចរបស់តុលាការវិញ គឺធ្វើឡើងនៅពេលដែលភាគីទាំងពីរមិនមានការព្រមព្រៀងគ្នា។ ការសម្រេចរបស់តុលាការធ្វើឡើងដោយកំណត់ចំនួនទឹកប្រាក់ទៅតាមលទ្ធភាពរបស់សហព័ទ្ធម្នាក់ៗ។ នេះមានន័យថា ទោះបីជាសហព័ទ្ធដែលមានកាតព្វកិច្ចផ្តល់អាហារកិច្ចដល់កូនត្រូវទៅរស់នៅឆ្ងាយយ៉ាងណា ក៏ត្រូវតែបំពេញដែរ។ តុលាការមានសិទ្ធិកែប្រែកាតព្វកិច្ចនេះបាន បើស្ថានភាពជាក់ស្តែងតម្រូវ។ ប៉ុន្តែ ប្រសិនបើភាគីណាមួយមិនព្រមបង់អាហារកិច្ចដោយមិនស្មោះត្រង់ និងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ព្រោះមិនបានគោរពតាមសេចក្តីបង្គាប់របស់តុលាការ។

### ២.២.៤ ការចុះបញ្ជីកែប្រែ

ក្រោយពេលមានការលែងលះ ជានិច្ចកាល វាតែងតែមានការប្រែប្រួលនូវការគ្រប់គ្រងទ្រព្យសម្បត្តិរវាងពាណិជ្ជករ និងសហព័ទ្ធ ដូចដែលបានរៀបរាប់នៅខាងលើរួចមកហើយ។ វាក៏មានការទាក់ទងផងដែរចំពោះមូលនិធិពាណិជ្ជកម្មរបស់ពាណិជ្ជករ ដែលបណ្តាលឱ្យមានការចុះបញ្ជីកែប្រែជាដាច់ខាត ជាពិសេសករណីទាំងស្ត្រី និងស្វាមីជាពាណិជ្ជករទាំងពីរនាក់។ ចំពោះការកែប្រែ ប្តីប្រពន្ធត្រូវធ្វើការឯកភាពគ្នានូវចំណុចដែលខ្លួនព្រមព្រៀងកែប្រែស្ថានភាពពាណិជ្ជកម្មពេលធ្វើការលែងលះដោយធ្វើជាកំណត់ហេតុ ដូចដាក់ពាក្យសុំទៅក្រសួងពាណិជ្ជកម្ម។

ទាំងនេះគឺជាចំណុចដែលកំណត់ដោយច្បាប់។ ដោយឡែក ប្រសិនបើក្រោយការលែងលះពាណិជ្ជករ និងសហព័ទ្ធមានចំណុចមួយចំនួន ឬទាំងអស់ដែលត្រូវធ្វើការកែប្រែ ហើយស្ថិតនៅក្នុងការកំណត់ខាងលើ ពួកគេត្រូវតែអនុលោមតាម។ ករណីនេះ មានន័យថាក្រោយការចុះបញ្ជីកែប្រែសហព័ទ្ធណាម្ខាងជាពាណិជ្ជករអាចបន្តសកម្មភាពពាណិជ្ជកម្មរបស់ខ្លួនបាន។ យ៉ាងណាមិញ វាក៏ជាអាញ្ញត្តិកម្មនៅពេលដែលពាណិជ្ជករចង់បញ្ឈប់ប្រតិបត្តិការពាណិជ្ជកម្ម។

ក្នុងករណីដែលក្រោយពេលលែងលះ ពាណិជ្ជករឈប់ប្រកបរបរពាណិជ្ជកម្ម ហើយពុំបានធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្មរបស់ខ្លួនទេ ឬរំលាយក្រុមហ៊ុនរបស់ខ្លួន ត្រូវលុបឈ្មោះពាណិជ្ជករ ឬក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម។ ប្រសិនបើគ្មានការសុំលុបឈ្មោះដោយពាណិជ្ជករ ការលុមឈ្មោះចេញពីបញ្ជីនេះ ត្រូវធ្វើតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ

រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវចម្លងជូនដល់តុលាការពាណិជ្ជកម្មដើម្បីទុកជាឯកសារសម្រាប់ប្រើប្រាស់នៅពេលក្រោយ។[45]

បន្ថែមពីលើនេះ ពាណិជ្ជករក៏ត្រូវធ្វើការកែប្រែស្ថានភាពផ្ទាល់ខ្លួនផងដែរ។

រាល់ការកែប្រែទាំងអស់ ត្រូវធ្វើការចុះផ្សាយឱ្យសាធារណជនបានដឹងឮ។

## ២.៣ ករណីមរណភាពរបស់សហព័ទ្ធជាពាណិជ្ជករម្នាក់ណាមួយ

មិនអាចកំណត់បានទេនូវអាយុជីវិតរបស់បុគ្គលម្នាក់ៗ។ មិនប្រាកដថាស្ត្រីជាពាណិជ្ជករ និងសហព័ទ្ធ មួយណាទទួលមរណភាពមុនមួយណាទេ។ កាលណាភាគីណាមួយស្លាប់ វាតែងតែមានបន្សល់នូវទ្រព្យដល់បុគ្គលដែលនៅរស់ ទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។ ចំពោះស្ត្រីជាពាណិជ្ជករ ឬសហព័ទ្ធដែលជាពាណិជ្ជករ ប្រសិនបើស្លាប់ទៅ គឺតែងតែបន្សល់ទុកនូវទ្រព្យទាំងពីរប្រភេទនេះ ដែលអាចមានដូចជាមូលនិធិពាណិជ្ជកម្ម ឬបំណុលចំពោះតតិយជន ដែលនេះមិនអាចមិនរាប់ចូលបានទេ ព្រោះជីវិតជាពាណិជ្ជករតែងតែមាន។ យ៉ាងណាមិញ យើងដឹងហើយថា បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សន្តតិកម្មគឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់តាមឆន្ទៈ ឬតាមច្បាប់។ ដូច្នេះ ដើម្បីថាការបន្សល់ទុកនេះត្រូវធ្វើឡើងដោយរបៀបណា ហើយត្រូវកំណត់ដូចម្តេច យើងត្រូវធ្វើការសិក្សាទៅលើប្រភេទនៃសន្តតិកម្ម ការដោះស្រាយបំណុលចំពោះតតិយជន និងការប្រកាសផ្សាយជាសាធារណៈពីមរណភាពដូចខាងក្រោម។ ចំពោះប្រភេទនៃសន្តតិកម្ម យើងអាចយល់ច្បាស់ដោយផ្អែកលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ សន្តតិកម្មមានពីរប្រភេទគឺ សន្តតិកម្មមានបណ្តាំ និងសន្តតិកម្មតាមច្បាប់។ តាមច្បាប់ សន្តតិកម្មត្រូវធ្វើឡើងនៅលំនៅឋានរបស់មតកជន នៅពេលទទួលមរណភាព។ សន្តតិកម្មនេះដែរ ត្រូវបានកំណត់ថាមានអានុភាពឱ្យសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជនពេលចាប់ផ្តើមសន្តតិកម្ម[46]។ សន្តតិកម្ម ក៏បានបញ្ញត្តិអំពីការដោះស្រាយបំណុលចំពោះតតិយជនដែរ គឺត្រង់ចំណុចទ្រព្យអកម្ម។ ទាំងអស់នេះ នឹងបង្ហាញអំពីរៀបចាត់ចែងទ្រព្យសម្បត្តិរបស់មរណជនទៅដល់អ្នកដែលនៅរស់ជាសាច់ញាតិលោហិត ឬបុគ្គលដែលពាក់ព័ន្ធនានាជាមួយប្រតិបត្តិការពាណិជ្ជកម្មរបស់មរណជនដែលជាមតកជននោះ។ អ្វីដែលសំខាន់ គឺត្រូវប្រាដថាបានផ្សព្វផ្សាយជាសាធារណៈពីមរណភាព។

---

[45] មាត្រា២៨ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (១៩៩៥)

[46] មាត្រា១១៨៧ វក្យខណ្ឌ១ ក្រមរដ្ឋប្បវេណី (២០០៧)

### ២.៣.១ សន្តតិកម្មមានបណ្តាំ

សន្តតិកម្មមានបណ្តាំ ឬអាចហៅម្យ៉ាងទៀតបានថា សន្តតិកម្មតាមមតកសាសន៍ គឺជាសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន[47] មានន័យថាមតកជនបង្ហាញឆន្ទៈផ្ទាល់ក្នុងការផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទៅឱ្យសន្តតិជន។ មតកជនជនខ្លួនឯងត្រូវតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតមតកសាសន៍តាមទម្រង់នានាដែលច្បាប់បានកំណត់អំពីអ្វីៗដែលខ្លួនចង់បង្កើត ឬនៅក្នុងមតកសាន៍នោះ ក៏អាចធ្វើអច្ច័យទានបានដែរ។

#### ២.៣.១.១ សមត្ថភាពរបស់មតកជន

បុគ្គលដែលមានសមត្ថភាពតាមផ្លូវច្បាប់ ដែលអាចធ្វើមតកសាសន៍បានគឺជានីតិជន។ នីតិជន ត្រូវតែមានសមត្ថភាពខាងឆន្ទៈផងដែរ នៅពេលដែលធ្វើមតកសាន៍។ នេះមានន័យថា មិនថានីតិជនដែលកើតឡើងតាមរបៀបណានោះទេ គឺត្រូវតាត់ទុកថាមានសមត្ថភាព។ តែទោះជាយ៉ាងណា ការមានសមត្ថភាពនេះ ក៏ទាមទារឱ្យមានសមត្ថភាពក្នុងការសម្រេចចិត្តជាកំហិតនៅពេលធ្វើមតកសាសន៍ គឺមិនត្រូវឱ្យមានបញ្ហាស្មារតីនោះទេ ដូចជាស្រវឹងជាដើម។

#### ២.៣.១.២ ទម្រង់មតកសាសន៍

ការធ្វើមតកសាសន៍ អាចធ្វើបានតាមរយៈទម្រង់ចំនួនបីដូចជា ទម្រង់ជាលិខិតយថាភូតទម្រង់ជាលិខិតឯកជន និងទម្រង់ជាលិខិតសម្ងាត់។ ទម្រង់ទាំងបីនេះជាកត្តាដែលនាំឱ្យមានសុពលភាពនៃមតកសាសន៍។

យោងតាមមាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ថា មតកសាសន៍តាមទម្រង់លិខិតយថាភូត គឺជាមតកសាសន៍ដែលបានបង្កើតឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសាការី ស្របតាមលក្ខខណ្ឌដូចតទៅៈ

- ✓ ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២នាក់
- ✓ ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសាការី
- ✓ សាការីត្រូវសរសេរនូវអត្ថន័យ នៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយលក្ខណ៍អក្សរហើយសូត្រឱ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់

[47] មាត្រា១៤៨៥ វក្យខណ្ឌ២ ក្រមរដ្ឋប្បវេណី (២០០៧)

- ✓ ក្រោយពេលម្ចាស់បណ្តាំ និងសាក្សីទទួលស្គាល់ការកំណត់លាយលក្ខអក្សរនោះហើយ ជននីមួយៗត្រូវចុះហត្ថលេខារៀងៗខ្លួន ឬក៏សាការីអាចសរសេរនូវហេតុដែលបុគ្គលណាម្នាក់មិនចេះចុះហត្ថលេខា ដើម្បីបញ្ជាក់ពីឈ្មោះ និងលំនៅឋាន
- ✓ សាការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ហើយត្រូវចុះហត្ថលេខា។

ក្រៅពីនេះ មតកជន អាចធ្វើមតកសាសន៍តាមរយៈលិខិតឯកជនក៏បាន។ មាត្រា១១៧៤ នៃក្រមដដែលបានបញ្ជាក់ថា មតកសាសន៍តាមទម្រង់លិខិតឯកជន គឺជាមតកសាសន៍ដែលត្រូវបានធ្វើឡើងដោយម្ចាស់មានបណ្តាំ ពោលគឺបានសរសេរនូវពាក្យទាំងអស់ និងចុះថ្ងៃខែឆ្នាំដោយផ្ទាល់ដៃខ្លួនឯង ហើយចុះហត្ថលេខាលើលិខិតនោះ។ លិខិតនោះមានសុពលភាព លុះណាតែគ្មានអ្នកសរសេរជំនួស ហើយបើមាននឹងចាត់ទុកជាមោឃៈ។ ប្រសិនបើមានការបន្ថែម ឬការលុប ឬការកែប្រែផ្សេងៗ ម្ចាស់បណ្តាំត្រូវបង្ហាញនៅកន្លែងទាំងនោះ ដោយសរសេរពីមូលហេតុ ព្រមទាំងចុះហត្ថលេខាផង។

មតកជនក៏អាចធ្វើមតកសាន៍តាមរយៈលិខិតម្យ៉ាងទៀតគឺ លិខិតសម្ងាត់។ មាត្រា១១៧៥ នៃក្រមដដែល បានកំណត់ថាវាគឺជាមតកសាសន៍ដែលបានបង្កើតឡើងដោយម្ចាស់បណ្តាំខ្លួនឯងដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

- ✓ ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ
- ✓ ត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសម្គាល់ ឬមធ្យោបាយណាមួយដែលអាចកំណត់បានអំពីការបើក ឬមិនបានបើកនៃស្រោមលិខិតនោះនៅមាត់ស្រោមលិខិត
- ✓ ម្ចាស់បណ្តាំត្រូវយកទៅដាក់នៅចំពោះមុខសាការី និងសាក្សីពីរនាក់ ហើយធ្វើសេចក្តីថ្លែងការណ៍ថាលិខិតនោះជាលិខិតមតកសាសន៍របស់ខ្លួន។ ប៉ុន្តែ បើមានអ្នកដទៃសរសេរឱ្យត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជននោះ
- ✓ សាការីត្រូវចុះថ្ងៃ ខែ ឆ្នាំ ដែលម្ចាស់បណ្តាំបានដាក់ ហើយសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើលិខិតបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយសាក្សី និងម្ចាស់បណ្តាំ។

#### ២.៣.១.៣ ការចែងនៅក្នុងមតកសាសន៍

គួររំឭកផងដែរថា មតកជនត្រូវកំណត់នូវចំណុចមួយចំនួនក្នុងមតកសាសន៍របស់ខ្លួនដូចជាការកំណត់ចំណែកមរតក ការកំណត់វិធីបែងចែកមរតក ការធ្វើអនុប្បទាន ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ និងការកំណត់ផ្សេងៗទៀតទាក់ទងនឹងទ្រព្យ។

ទាក់ទងនឹងការកំណត់ចំណែកមរតក មតកជនអាចធ្វើការកំណត់ដោយឆន្ទៈរបស់ខ្លួន ដោយមិនត្រូវបំពានលើភាគបម្រុងដែលច្បាប់បានកំណត់ចំពោះសន្តតិជនដទៃទៀតឡើយ។ ចំណែករបស់សហសន្តតិជនផ្សេងទៀតត្រូវកំណត់តាមការសម្រួលចំណែកមរតក[48] ប្រសិនបើមតកជនបានកំណត់ចំណែកមរតកត្រឹមតែចំពោះសន្តតិជនម្នាក់ ឬច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់។

មាត្រា១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ពីវិធីបែងចែកមរតក ដោយមតកជនអាចធ្វើការជ្រើសរើសការកំណត់នូវវិធីបែងចែកមរតកចំពោះសន្តតិជន ឬអាចប្រគល់អណត្តិឱ្យតតិយជនកំណត់វិធី ឬអាចហាមឃាត់មិនឱ្យបែងចែកក្នុងអំឡុងពេលមិនលើសពីប្រាំឆ្នាំ ដោយគិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្មនៅក្នុងមតកសាសន៍របស់ខ្លួន។

មតកជនអាចធ្វើអនុប្បទានចំពោះសន្តតិជនរបស់ខ្លួន ឬតតិយជនតាមមតកសាសន៍ ឬក្រោមរូបភាពអច្ច័យទានទៅសន្តតិជន ឬតតិយជនបាន តែត្រូវគោរពលើភាគបម្រុងរបស់សហសន្តតិជន។ ការធ្វើអនុប្បទានទ្រព្យសម្បត្តិ ឬអច្ច័យទានចំពោះសហសន្តតិជនគឺជាការកំណត់នូវមរតក ឬវិធីបែងចែកមរតកដោយយោងតាមឆន្ទៈរបស់មតកជន ដែលវាមិនដូចជាប្រទានកម្ម ឬការធ្វើអនុប្បទាន ឬអច្ច័យទានទ្រព្យសម្បត្តិទៅឱ្យតតិយជនទេ។

ក្រៅពីនេះដើម្បីមានភាពងាយស្រួលក្នុងការប្រតិបត្តិនូវមតកសាសន៍ មតកជនអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ជាមុនបាន។ អ្នកប្រតិបត្តិមតកសាសន៍អាចជាតតិយជន ឬសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនទាំងអស់របស់មតកជន ឬតតិយជនដែលទទួលសិទ្ធិជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍បាន។ នេះ បើយោងតាមមាត្រា១១៨៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលអាចមានចំនួនច្រើន ឬតិចអាស្រ័យលើមតកជនផ្ទាល់។

ជាមួយគ្នានេះដែរ មតកជនអាចធ្វើការកំណត់ចាំបាច់ផ្សេងៗទៀតដែលគិតថាមានប្រយោជន៍ដល់សហសន្តតិជន ដូចជាការផ្ដល់ជំបូន្មានជាដើម។

### ២.៣.១.៤ អច្ច័យទាន

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ថា អច្ច័យទានគឺជាប្រទានកម្មដែលម្ចាស់បណ្ដាំឱ្យទ្រព្យរបស់ខ្លួនទៅកាន់មនុស្សម្នាក់ ឬច្រើននាក់ ដែលមានពីរប្រភេទគឺ អច្ច័យទានសាកល និង អច្ច័យទានមានកំណត់។ អច្ច័យទានសាកល គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដោយកំណត់តាមភាគ។ ឯអច្ច័យទានមានកំណត់ គឺ

[48] មាត្រា១១៨២ ក្រមរដ្ឋប្បវេណី (២០០៧)

ជាប្រទានកម្មនូវទ្រព្យសម្បត្តិជាក់លាក់ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់។ នេះ ដោយយោងតាមមាត្រា១១៩៩ នៃក្រមដដែល។ នៅពេលដែលអច្ច័យលាភីបំពេញគ្រប់លក្ខខណ្ឌដែលកំណត់ដោយច្បាប់ អច្ច័យទាននឹងមានអានុភាព។

### ២.៣.២ សន្តតិកម្មតាមច្បាប់

សន្តតិកម្មមានបណ្តាំ គឺជាសន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់។[49] នេះមានន័យថាជាការបែងចែកនូវមរតករបស់មតកជនក្នុងករណីដែល មតកជនមិនបានបង្ហាញឆន្ទៈក្នុងការបែងចែក ឬកំណត់ឱ្យសន្តតិជន ឬសហសន្តិជនតាមមរតកសាសន៍ (សន្តតិកម្មមានបណ្តាំ)។ ចំពោះករណីនេះ សន្តតិជន ជាជនដែលនឹងត្រូវទទួលបានចំណែកមរតកតាមច្បាប់កំណត់។ តាមច្បាប់នឹងត្រូវធ្វើការសម្រួលចំណែកមរតក ចំពោះករណីដែលសន្តតិជនមួយចំនួនទទួលបានផលប្រយោជន៍ពិសេស ឬបានធ្វើវិភាគទានចំពោះមតកជន។ លើសពីនេះ ច្បាប់នឹងការពារនូវបុគ្គលដែលជាសន្តតិជនតាមច្បាប់នូវសិទ្ធិទទួលបានភាគបម្រុង ទោះមិនមានឆន្ទៈរបស់មតកជនក៏ដោយ។

#### ២.៣.២.១ ប្រភេទសន្តតិជន

សន្តតិជនតាមច្បាប់កំណត់រួមមានដូចជាសន្តតិជនជាសហព័ទ្ធ និងសន្តតិជនតាមលោហិត។

សហព័ទ្ធគឺជាសន្តតិជនជានិច្ច ដែលនេះមានន័យថាទោះមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ សហព័ទ្ធរបស់មតកជនត្រូវទទួលបាននូចចំណែកមរតកនៃទ្រព្យដោយឡែក និងទ្រព្យរួមរបស់មតកជន។ ប្រសិនបើមានសន្តតិជនផ្សេងទៀត ត្រូវមានលំដាប់ស្មើគ្នាជាមួយសន្តតិជននោះដូចជាករណីសន្តតិជនផ្សេងទៀតជាសន្តតិជនលំដាប់ទីមួយ សហព័ទ្ធត្រូវជាសន្តតិជនលំដាប់ទីមួយដែរ ហើយបើលំដាប់ទីពីរ ត្រូវតែជាលំដាប់ទីពីរដូចគ្នា[50]។ ចំពោះចំណែកមរតកនេះ សន្តតិជនទាំងឡាយក្នុងករណីមានសហព័ទ្ធជាសន្តតិជនដែរ ត្រូវអនុវត្តតាមរូបមន្តក្នុងមាត្រា១១៦២ នៃក្រមរដ្ឋប្បវេណី។ យ៉ាងណាមិញ ចំពោះករណីនេះ គេអាចអនុវត្តបានតែក្នុងករណីនៃការបែងចែកចំណែកមរតកធម្មតាដោយច្បាប់ក្នុងករណី ដែលមិនបានបន្សល់ទុកមរតកសាសន៍របស់មតកជនទេ។ ប៉ុន្តែ ប្រសិនបើមុនពេលចាប់ផ្តើមសន្តតិកម្ម ទ្រព្យខ្លះរបស់មតកជនត្រូវបានចាត់ចែងដោយមតកជន ហើយមិនបានកំណត់នូវមរតកសាសន៍ របបនៃការសម្រួលចំណែកមរតក ត្រូវបានច្បាប់

[49] មាត្រា១៨៩៥ វក្យខណ្ឌ២ ក្រមរដ្ឋប្បវេណី (២០០៧)

កំណត់ឱ្យដោយធ្វើឡើងដោយស្មើភាពចំពោះការបែងចែកចំណែកមរតកទៅសន្តតិជន នៅពេលចាប់ផ្តើមសន្តតិកម្មចំពោះជនទាំងអស់។

សន្តតិជនតាមលោហិត មិនអាចទទួលបានចំណែកមរតកស្មើៗគ្នានោះទេ។ វាត្រូវបានបែងចែកអទិភាពទៅឱ្យគ្រប់ញាតិលោហិតទាំងអស់ក្នុងការទទួលទៅតាមថ្នាក់របស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ មុននឹងធ្វើការផ្ទេរទៅឱ្យលំដាប់បន្ទាប់ ត្រូវតែមានការឆ្លងកាត់សន្តតិជនជំនួសរបស់សន្តតិជនលំដាប់ជាមុនសិន។ សន្តតិជនលំដាប់មានដូចជា សន្តតិជនលំដាប់ទីមួយគឺជាកូនរបស់មតកជន, សន្តតិជនលំដាប់ទីពីរគឺជាបុព្វញាត់របស់មតកជន មានដូចជាឪពុកម្តាយ ជីដូនជីតារបស់មតកជន, សន្តតិជនលំដាប់ទីបីគឺជាបងប្អូនបង្កើតរបស់មតកជន[51]។ យោងតាមមាត្រា១១៥៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សន្តតិជនដែលជាកូនមានសិទ្ធិទទួលសន្តតិកម្មជំនួស ក្នុងករណីដែលសន្តតិជនបានទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបាត់បង់នូវលក្ខណៈជាសន្តតិជនមុនពេលចាប់ផ្តើមសន្តតិកម្ម។ ដោយឡែក ចំពោះកូនសុំមិនមានសិទ្ធិជាសន្តតិជនជំនួសទេ ប្រសិនបើបានកើតមុនពេលមានការសុំកូនដោយមតកជន[52]។ ប៉ុន្តែបើកូននោះកើតក្រោយពេលមានការសុំកូនដោយមតកជន នោះអាចមានសិទ្ធិទទួលសន្តតិកម្មជំនួសបាន។ អ្វីដែលគួរឱ្យកត់សម្គាល់ជាងនេះគឺ ប្រសិនបើសន្តតិជនជំនួសបានទទួលមរណភាព ឬបាត់បង់នូវលក្ខណៈសម្បត្តិជាសន្តតិជនជំនួសទៀត នោះគេត្រូវធ្វើការផ្តល់ចំណែកនោះទៅឱ្យសន្តតិជនបន្តបន្ទាប់គ្នាតាមលំលំដាប់។

### ២.៣.២.២ ការសម្រួលចំណែកមរតក

គេអាចធ្វើការសម្រួលចំណែកមរតកបានក្នុងករណីចំនួនពីរគឺ ក្នុងករណីដែលមានការទទួលបានផលប្រយោជន៍ពិសេស និងករណីដែលមានការធ្វើវិភាគទានដើម្បីផលប្រយោជន៍មតកជន នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។ យើងនឹងធ្វើការសិក្សាលើចំណុចទាំងពីរនេះដូចខាងក្រោម។

ដូចមានកំណត់នៅក្នុងមាត្រា១១៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អំពីករណីដែលទទួលបានផលប្រយោជន៍ពិសេស ថាក្នុងចំណោមសហសន្តតិជនទាំងអស់ ប្រសិនបើមានជនណាម្នាក់បានទទួលនូវប្រទានកម្មក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងៗ ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬបានទទួលអច្ច័យទានពីមតកជននោះ ការសម្រួលចំណែកមរតកត្រូវធ្វើឡើងដោយសម្រួលចំណែកមរតកសម្រាប់អ្នកទទួលផលប្រយោជន៍ពិសេសនោះ ដោយយកតម្លៃទ្រព្យ

---

[50] មាត្រា១១៦១ ក្រមរដ្ឋប្បវេណី (២០០៧)

[51] មាត្រា១១៥៦, ១១៥៩ និង១១៦០ ក្រមរដ្ឋប្បវេណី (២០០៧)

[52] ទំព័រ១៦ សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីភាគ៦ (២០១០)

ដែលទទួលបាននោះ ទៅបូកជាមួយទ្រព្យដែលមានពេលចាប់ផ្តើមសន្តតិកម្ម។ គេត្រូវចាត់ទុកជាមរតកទាំងអស់ ហើយធ្វើការបែងចែកឡើងវិញ ដោយគណនាតាមតាមចំនួនសន្តតិជន ដើម្បីស្វែងរកចំណែកមរតកម្នាក់ៗ ហើយយកចំណែកមរតកម្នាក់ៗនោះដកនឹងតម្លៃនៃទ្រព្យដែលជាផលប្រយោជន៍ពិសេសនោះ ទើបរកឃើញនូវចំណែកមរតករបស់សន្តិជនដែលបានទទួលនូវផលប្រយោជន៍មុនពេលចាប់ផ្តើមសន្តតិកម្ម។ គួរចំណាំថា ប្រសិនបើតម្លៃនៃផលប្រយោជន៍ពិសេសនោះស្មើ ឬលើសពីតម្លៃនៃចំណែកមរតកម្នាក់ៗ នាំឱ្យសន្តតិជនដែលទទួលបានផលប្រយោជន៍ពិសេសនោះមិនទទួលបានចំណែកមរតកទៀតទេ។

រីឯមាត្រា១១៦៦ នៃក្រមដដែលបានកំណត់អំពីករណីដែលមានការធ្វើវិភាគទានពិសេស។ ការធ្វើវិភាគទានពិសេសគឺជាការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិកនៃទ្រព្យសម្បត្តិ ឬដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងៗទៀត ដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន។ ដើម្បីសម្រួលចំណែកមរតកនៅក្នុងករណីនេះ គេត្រូវយកមរតកដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដកតម្លៃនៃវិភាគទាននោះចេញ ទើបរាប់ថាជាមរតកសរុប ហើយធ្វើការបែងចែកទៅតាមសមាមាត្រនៃចំនួនសន្តតិកម្ម ជាចំណែកមរតករបស់សន្តតិជនផ្សេងទៀត។ ដោយឡែក ចំណែករបស់សន្តតិជនដែលបានធ្វើវិភាគទានគឺជាចំណែកមរតកនោះ បូកជាមួយនឹងតម្លៃវិភាគទាន។ គួរបញ្ជាក់ផងដែរថា ភាគនៃវិភាគទាន មិនអាចលើសចំនួនទឹកប្រាក់នៃមរតកដែលបានដកចេញនូវតម្លៃអច្ច័យទាន និងតម្លៃទ្រព្យដែលមតកជនបានកំណត់ក្នុងមតកសាសន៍ជាចំណែករបស់សហសន្តតិជន ឬតម្លៃទ្រព្យដែលជាការកំណត់វិធីបែងចែក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មទេ។ មួយវិញទៀត ការកំណត់នូវតម្លៃវិភាគទាន គឺចេញពីការពិភាក្សារបស់សហសន្តតិជនទាំងអស់ ឬតាមការកំណត់របស់តុលាការបើគ្មានការពិភាក្សា។

### ២.៣.២.៣ ភាគបម្រុង

ភាគបម្រុង គឺជាចំណែកមរតកដែលច្បាប់បានកំណត់ឱ្យចំពោះសន្តតិជនណាមួយដោយស្វ័យប្រវត្តិ ជាពិសេសករណីដែលមានសន្តតិជនណាម្នាក់ ឬច្រើនមិនបានទទួលមរតកទាល់តែសោះ ឬទទួលបានតិចពេក។ អ្នកទាំងអស់នោះ អាចធ្វើការទាមទារយកនូវភាគបម្រុង ដែលសន្តតិជន ឬអច្ច័យលាភីផ្សេងទៀតបានបំពាន ។ អ្នកដែលមានសិទ្ធិលើភាគបម្រុងមានដូចជា បច្ឆាញាតិផ្ទាល់ សហព័ទ្ធ ឪពុកម្តាយ ជីដូនជីតា ។ ភាគបម្រុងនេះ ត្រូវបានកំណត់នៅក្នុងមាត្រា១២៣០ ១២៣១ ១១៦៣ ១២៣២ និង១២៣៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

### ២.៣.៣ ការប្រកាសផ្សាយជាសាធារណៈពីមរណភាព និងការដោះស្រាយបំណុលចំពោះតតិយជន

ក្រោយពីទទួលមរណភាព ក្រៅពីធ្វើពិធីបុណ្យតាមប្រពៃណីដើម្បីប្រកាសឱ្យញាតិផងទាំងពួងបានដឹងឮ សហព័ទ្ធជាពាណិជ្ជករ ឬមិនមែនដែលនៅរស់ ឬសាច់ញាតិ ឬអ្នកដែលពាក់ព័ន្ធនានាត្រូវធ្វើការជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋាននៃសាលាឃុំ សង្កាត់ នៅទីកន្លែងរបស់សហព័ទ្ធដែលទទួលមរណភាព។ ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាពជាវិធីមួយដែលអាចប្រកាសជាសាធាណៈអំពីមរណភាពរបស់សហព័ទ្ធបាន ដែលត្រូវធ្វើឡើងយ៉ាងយូរ១៥ថ្ងៃក្រោយថ្ងៃទទួលមរណភាព។ ជាមួយគ្នានេះដែរ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាណរួចប្រគល់ឱ្យអ្នកនូវសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំ។[53]

ជាពិសេស ប្រសិនបើសហព័ទ្ធស្ត្រីជាពាណិជ្ជករ ឬស្វាមី ម្នាក់ណាក៏ដោយឱ្យតែជាពាណិជ្ជករហើយបានទទួលមរណភាព ការប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មានជារឿងដែលសំខាន់បំផុត។ យើងនិយាយថាវាសំខាន់ព្រោះ ក្រោយពីផ្សព្វផ្សាយទៅកាន់សាធារណៈជនតាមរយៈកាសែត ទស្សនាវដ្តី ទូរទស្សន៍ ឬបណ្តាញសាព័ត៌មានផ្សេងៗទៀតនៅក្នុងតំបន់ ជនទូទៅនឹងបានដឹងឮទូលំទូលាយ។ អ្វីដែលសំខាន់ជាងនេះទៅទៀតគឺតតិយជន ជាពិសេសម្ចាស់បំណុលនឹងមានភាពងាយស្រួលក្នុងការចាត់ចែងទៅលើបំណុលនានាជាមួយសហព័ទ្ធ ឬសាច់ញាតិដែលនៅរស់។

ដោយឡែក ក្នុងករណីពាណិជ្ជករឈប់ប្រកបរបរពាណិជ្ជកម្មដោយសារទទួលមរណភាពហើយពុំបានធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្មរបស់ខ្លួនទេ ត្រូវលុបឈ្មោះពាណិជ្ជករចេញពីបញ្ជីពាណិជ្ជកម្ម។ សន្តតិជនជាអ្នកសុំលុបឈ្មោះចេញ ប៉ុន្តែប្រសិនបើគ្មានការសុំលុបឈ្មោះនេះទេ ត្រូវធ្វើតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ មួយវិញទៀត រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវចម្លងជូនដល់តុលាការពាណិជ្ជកម្មដើម្បីទុកជាឯកសារសម្រាប់ប្រើប្រាស់នៅពេលក្រោយ។ ជារួម វាស្រដៀងគ្នាទៅនឹងករណីលែងលះដែរ។

បន្ថែមលើការប្រកាសផ្សាយពីមរណភាព ការលុបឈ្មោះពាណិជ្ជករដែលទទួលមរណភាពចេញពីបញ្ជីពាណិជ្ជកម្មក៏ត្រូវមានការចុះផ្សាយផងដែរ។ ការចុះផ្សាយនេះត្រូវធ្វើដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្មនៅក្នុងរាជកិច្ច ដែលការចុះផ្សាយនោះមានដូចជា លេខចុះបញ្ជី នាមត្រកូល នាមខ្លួន រហស្សនាម ព្រមទាំងនាមសហព័ទ្ធ សកម្មភាព ទីកន្លែង ថ្ងៃខែឆ្នាំចាប់ផ្តើមសកកម្មភាព និងផ្លាក

[53] មាត្រា៣៥ និង៣៩ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន (២០០០)

សញ្ញា។ ប៉ុន្តែបើមូលនិធិពាណិជ្ជកម្មត្រូវបានធ្វើសន្តតិកម្មទៅឱ្យសន្តតិជន ឬធ្វើអច្ច័យទានឱ្យតតិយជនណាម្នាក់ ដែលមានន័យថាសកម្មភាពពាណិជ្ជកម្មនៅតែបន្ត ក៏ការប្រកាសផ្សាយជាសាធារណៈកាន់តែចាំបាច់ណាស់ដែរ។

ចំពោះម្ចាស់បំណុលទាំងឡាយអាចធ្វើការទាមទារ ឬទូទាត់ជាមួយសន្តតិជនរបស់ពាណិជ្ជករ (ក៏មានសហាព័ទ្ធរបស់ពាណិជ្ជករផងដែរ) ឬអច្ច័យលាភី ព្រោះថាទាំងទ្រព្យអកម្ម និងទ្រព្យសកម្មរបស់ពាណិជ្ជករបានធ្លាក់ទៅលើសន្តតិជន ឬអច្ច័យលាភីរួចហើយ។ ករណីមរណភាពនេះ វាប្រៀបបានទៅនឹងការផ្ទេរ ឬដូរអ្នកគ្រប់គ្រងមូលនិធិពាណិជ្ជកម្ម ហើយបន្តសកម្មភាពពាណិជ្ជកម្មដូចគ្នាដែរ។ ប៉ុន្តែ ចំពោះករណីដែលមិនមានអ្នកបន្តសកម្មភាពពាណិជ្ជម្ម ពោលប្រតិបត្តិការពាណិជ្ជកម្មត្រូវបានបញ្ចប់ក្រោយមរណភាពរបស់ពាណិជ្ជករ តតិយជនដែលជាម្ចាស់បំណុលក៏អាចធ្វើការទូទាត់ជាមួយអ្នកទទួលមរតកបានដែរ ដោយសារសន្តតិជនបានយកមូលនិធិពាណិជ្ជកម្មនោះជាទ្រព្យរបស់ខ្លួនហើយ។ តុលាការអាចធ្វើអន្តរាគមន៍បាន ប្រសិនបើមានកើតមានវិវាទរវាងម្ចាស់បំណុល និងសន្តតិជនរបស់ពាណិជ្ជករដែលជាកូនបំណុលរបស់ខ្លួន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយវិភាគទៅលើប្រធានបទ "ស្ត្រីជាពាណិជ្ជករ" រួចមក ក្រុមយើងខ្ញុំសង្កេតឃើញថាស្ត្រីជាពាណិជ្ជករគឺជារូបវន្តបុគ្គលដូចជាបុគ្គលទូទៅដែរ ប្លែកត្រង់ថាពួកគាត់អនុវត្តសកម្មភាពពាណិជ្ជកម្មបន្ថែមពីលើសកម្មភាពស៊ីវិលប៉ុណ្ណោះ។ ដូចនេះ ចំណុចដែលគួរឱ្យចាប់អារម្មណ៍ចំពោះស្ត្រីមិនទាន់រៀបការ និងស្ត្រីដែលរៀបការរួចជាពាណិជ្ជករ គឺពួកគាត់ត្រូវទទួលខុសត្រូវផ្ទួនៗទាំងរឿងស៊ីវិល និងរឿងពាណិជ្ជកម្ម ខណៈដែលនារីដទៃទៀតខ្វាយខ្វល់តែរឿងស៊ីវិល។ ចំពោះការក្លាយខ្លួនទៅជាពាណិជ្ជកររបស់ស្ត្រីទាំងពីរប្រភេទនេះ ត្រូវតែស្របទៅតាមការកំណត់របស់ច្បាប់ ដោយស្ត្រីត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើពាណិជ្ជកិច្ច ហើយយកពាណិជ្ជកិច្ចជាមុខរបរប្រចាំ និងអនុវត្តសកម្មភាពក្នុងនាមខ្លួន និងដើម្បីប្រយោជន៍ខ្លួនឯង។ ការប្រកបរបរពាណិជ្ជកិច្ចរបស់ស្ត្រីមិនមែនគ្រាន់តែជាការធ្វើសកម្មភាពជាប្រចាំសម្រាប់តែផ្គត់ផ្គង់តម្រូវការជីវភាពគ្រួសារនោះទេ តែវាគិតអំពីប្រាក់ចំណេញ។ សមត្ថភាពក្នុងការក្លាយជាពាណិជ្ជករដែលសំខាន់មួយទៀតនោះគឺ ស្ត្រីត្រូវតែជានីតិជនដែលមិនមានបញ្ញាស្មារតី ហើយបើជាអនីតិជនដែលទទួលបានអត្តាធីនភាពវិញ គួរតែមានបទពិសោធន៍ផ្នែកពាណិជ្ជកិច្ចខ្លះៗ ឬក៏មានចំណង់ចំណូលចិត្តជាមួយវិស័យពាណិជ្ជកម្ម។ លើសពីនេះ នៅពេលដែលស្ត្រីក្លាយខ្លួនជាពាណិជ្ជករ ស្ត្រីក៏ត្រូវតែអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយដែលពាណិជ្ជករមានដូចជា សិទ្ធិគ្រប់គ្រងអាជីវកម្ម សិទ្ធិចំពោះតតិយជន និងអ្នកប្រើប្រាស់ និងសិទ្ធិចំពោះមុខរបរជាដើម ព្រមទាំងកាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្ម ការផ្សព្វផ្សាយជាសាធារណៈ ការគ្រប់គ្រងបញ្ជីគណនេយ្យ ការបង់ពន្ធ និងកាតព្វកិច្ចផ្សេងៗទៀត។ គួរបន្ថែមថា ប្រសិនបើស្ត្រីជាពាណិជ្ជករទាំងពីរប្រភេទនេះមិនបានគោរព និងអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចណាមួយទេ ស្ត្រីមិនអាចមានលក្ខណៈសម្បត្តិជាពាណិជ្ជករត្រឹមត្រូវតាមច្បាប់ឡើយ ហើយអាចមានទណ្ឌកម្មពីច្បាប់ជាធរមាន។ ដោយឡែក សិទ្ធិជ្រើសរើសទ្រព្យសម្បត្តិមកប្រើប្រាស់ក្នុងសកម្មភាពអាជីវកម្មរបស់ស្ត្រីគឺជាផ្នែកមួយដែលសំខាន់ផងដែរ។ ចំណុចទាំងអស់នេះ ទាំងស្ត្រីមិនទាន់រៀបការជាពាណិជ្ជករ ឬស្ត្រីរៀបការជាពាណិជ្ជករត្រូវតែមាន។ ទោះបីជាយ៉ាងណាក៏ដោយ ឆ្លងកាត់ការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំសង្កេតឃើញថាស្ត្រីនៅក្រមុំពុំមានភាពស្មុគស្មាញច្រើនអំពីទំនាក់ទំនងពាណិជ្ជកិច្ចជាមួយរឿងស៊ីវិលដូចស្ត្រីរៀបការរួចទេ ជាពិសេសពាក់ព័ន្ធទៅនឹងប្រព័ន្ធទ្រព្យសម្បត្តិ និងចំណងគតិយុត្តផ្សេងៗទៀតក្នុងករណីរលាយចំណងអាពាហ៍ពិពាហ៍ ដោយព្រោះស្ត្រីនៅលីវមិនមានចំណងអាពាហ៍ពិពាហ៍។ យើងអាចមើលឃើញថាលក្ខណៈសម្បត្តិជាពាណិជ្ជកររបស់ស្ត្រីរៀបការរួចមានការប្រែប្រួលទៅតាមការចាប់ផ្តើម និងធ្វើ

សកម្មភាពពាណិជ្ជកម្មជាមួយស្វាមី ខណៈស្ត្រីនៅលីវធ្វើការអនុវត្តប្រតិបត្តិការពាណិជ្ជកម្មរបស់នាងតែឯកឯង។ សិទ្ធិ និងកាតព្វកិច្ចជាពាណិជ្ជកររបស់ស្ត្រីរៀបការរួចជាពាណិជ្ជករមានការប្រែប្រួលទៅតាមលក្ខណៈសម្បត្តិផងដែរ។

ចំពោះពាណិជ្ជករជាស្ត្រីដែរលមានចំណងអាពាហ៍ពិពាហ៍ ក្រៅពីសមត្ថភាព សិទ្ធិ និងកាតព្វកិច្ចជាពាណិជ្ជករមួយចំនួនដែលបានរៀបរាប់ខាងលើ ការចុះបញ្ជីពាណិជ្ជកម្មដោយឡែកពីប្តីគឺជាការដែលត្រូវតែធ្វើដោយគ្រាន់តែធ្វើការជូនដំណឹងដល់ប្តី។ នេះ ក្នុងករណីដែលប្តីជាពាណិជ្ជករ។ ប៉ុន្តែ ចំពោះស្ត្រីដែលគាត់មានមុខរបរពាណិជ្ជកិច្ចមុនពេលរៀបអាពាហ៍ពិពាហ៍ និងស្ត្រីដែលរៀបការជាមួយសហព័ទ្ធមិនមែនជាពាណិជ្ជករ ហើយទើបតែចង់ក្លាយជាពាណិជ្ជករ ការចុះបញ្ជីត្រូវធ្វើឡើងជាធម្មតាដូចពាណិជ្ជករនៅលីវដែរ។ មួយវិញទៀត ការប្រកាសពីរបបទ្រព្យសម្បត្តិដែលខ្លួនយកមកប្រើប្រាស់ក្នុងពាណិជ្ជកិច្ចរឹតតែសំខាន់ ព្រោះថាវាងាយស្រួលនឹងធ្វើការតតាំងជាមួយតតិយជន ជាពិសេសក្នុងរឿងបំណុល។ ប្រសិនបើស្ត្រីជ្រើសរើសទ្រព្យសម្បត្តិរួម វាទាមទារឱ្យមានការចូលរួមពីសហព័ទ្ធក្នុងការដោះស្រាយជាមួយម្ចាស់បំណុល។ តែបើស្ត្រីជ្រើសរើសទ្រព្យដោយឡែក ស្ត្រីត្រូវធ្វើការចាត់ចែងដោយខ្លួនឯង។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏តាមរយៈមនោសញ្ចេតនាជាប្តីប្រពន្ធ ប្តីបានជួយប្រពន្ធក្នុងរឿងនេះផងដែរ ព្រោះថាសង្គមខ្មែរបានឱ្យតម្លៃខ្លាំងទៅលើមនោសញ្ចេតនា។ ដូចបានបញ្ជាក់រួចមកហើយថា លក្ខណៈនៃការគ្រប់គ្រងអាជីវកម្មធ្វើឱ្យមានការប្រែប្រួលលក្ខណៈសម្បត្តិរបស់ស្ត្រី ថាតើស្ត្រីបានជ្រើសរើសចូលរួមជាមួយស្វាមី ឬក៏ដាច់ដោយឡែក។ ប្រសិនបើស្ត្រីចូលរួមជាមួយស្វាមី ស្ត្រីទទួលបានលក្ខណៈសម្បត្តិជាសហប្រតិបត្តិករ ឬកម្មករ ឬសមាជិកហ៊ុន ហើយបើជ្រើសរើសការគ្រប់គ្រងអាជីវកម្មដាច់ដោយឡែកពីស្វាមីវិញ ស្ត្រីមានសិទ្ធិ និងកាតព្វកិច្ចទៅតាមការអនុវត្តតាមលក្ខខណ្ឌបីយ៉ាង និងការព្រមព្រៀងចំពោះបេតិកណ្ឌ។ ការប្រតិបត្តិពាណិជ្ជកិច្ចរបស់ស្ត្រីរៀបការរួចអាចដំណើរការដោយស្របតាមច្បាប់ជាធរមាន លើកលែងតែមានឆន្ទៈបញ្ឈប់។ ផ្ទុយមកវិញ ស្ត្រីរៀបការរួចអាចមានកាតព្វកិច្ចស្មុគស្មាញជាងនេះ ប្រសិនបើមានការលោយចំណងអាពាហ៍ពិពាហ៍ឬមានមរណភាពរបស់ស្វាមី ឬក៏បន្សល់ទុកនូវកាតព្វកិច្ចទាំងពាណិជ្ជកម្ម និងស៊ីវិលដល់សហព័ទ្ធ ឬសាច់ញាតិក្នុងករណីដែលខ្លួនមរណភាព។ តាមរយៈសាលក្រមលែងលះរបស់តុលាការ ស្ត្រី និងសហព័ទ្ធត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិដែលរួមមានមូលនិធិពាណិជ្ជកម្មផង និងគិតគូរទៅលើរបបអាហារកិច្ច ហើយអ្នកដែលទទួលបានមូលនិធិពាណិជ្ជកម្មទាំងស្រុង ឬភាគច្រើន អាចមានបន្ទុកច្រើនទៅលើរបបអាហារកិច្ច។ ប៉ុន្តែរបបអាហារកិច្ចនេះ ក៏អាស្រ័យលើមូលហេតុនៃការលែងលះដែរ។ ដោយឡែក ចំពោះករណីមរណភាពរបស់ស្ត្រីជាពាណិជ្ជករ ឬសហព័ទ្ធជាពាណិជ្ជករ ការធ្វើសន្តតិកម្មត្រូវគោរពទៅតាមច្បាប់ ដែលការ

ពិចារណាល្អិតល្អន់ទៅលើមូលនិធិពាណិជ្ជកម្មជារឿងដែលសំខាន់ ព្រោះថាវាពាក់ព័ន្ធនឹងបំណុលរបស់តតិយជន។ ជារួមទាំងការលែងលះ និងមរណភាព ស្ត្រីឬសហព័ទ្ធជាពាណិជ្ជករអាចធ្វើការបន្ត ឬបញ្ចប់ជីវិតអាជីវកម្មរបស់ខ្លួន ខណៈពេលដែលវាទាមទារឱ្យមានការចុះបញ្ជីកែប្រែ និងប្រកាសផ្សាយជាសាធារណៈទាំងស្ថានភាពផ្ទាល់ខ្លួន និងស្ថានភាពពាណិជ្ជកម្ម។ យ៉ាងណាមិញក្រុមយើងខ្ញុំសង្កេតឃើញថា ពុំទាន់មានភាពទូលំទូលាយនៅឡើយទេ ចំពោះការផ្សព្វផ្សាយជាសាធារណៈជាក់ស្តែង។

ជំពូកទី១ និងទី២ បានធ្វើការបែងចែកដាច់ដោយឡែកពីគ្នារវាងស្ត្រីមិនទាន់រៀបការជាពាណិជ្ជករ និងស្ត្រីរៀបការរួចជាពាណិជ្ជករ ក៏វាពុំមានលក្ខណៈដាច់ដោយឡែកទាំងស្រុងដែរ ព្រោះថាសិទ្ធិ និងកាតព្វកិច្ចរបស់ពាណិជ្ជករគ្រប់រូបមានដូចៗគ្នា។ ប៉ុន្តែអ្វីដែលបង្ហាញនូវភាពដាច់ដោយឡែកនោះគឺត្រង់ថាស្ត្រីរៀបការរួចមានចំណងគតិយុត្តច្រើនជាងស្ត្រីមិនទាន់រៀបការ ទាំងក្នុងសកម្មភាពពាណិជ្ជកម្ម និងស៊ីវិល ជាពិសេសចំណងដែលកើតចេញពីអាពាហ៍ពិពាហ៍ និងករណីដែលអាពាហ៍ពិពាហ៍បានរំលាយ។ ចំពោះស្ត្រីរៀបការរួចជាពាណិជ្ជករ ក្នុងករណីផ្តាច់ចំណងអាពាហ៍ពិពាហ៍ កាតព្វកិច្ចទាំងរឿងពាណិជ្ជកម្ម និងរឿងស៊ីវិលគឺជាបញ្ហាដែលត្រូវតែដោះស្រាយ។

ខណៈដែលប្រធានបទនេះត្រូវបានលើកឡើងជាការវិភាគ មិនមែនប្រៀបធៀបទាំងស្រុង ការសិក្សាពីស្ត្រីជាពាណិជ្ជករបានបង្ហាញឱ្យឃើញច្បាស់ថា ក្រៅពីវិស័យផ្សេងៗជាច្រើន ស្ត្រីបាននឹងកំពុងតែត្រូវបានលើកតម្កើងសិទ្ធិតាមរយៈបទដ្ឋានច្បាប់នានាទាំងបទដ្ឋាន ជាតិ និងអន្តរជាតិ ជាពិសេសនៅក្នុងវិស័យពាណិជ្ជកម្មនេះតែម្តង។ វាសបញ្ជាក់ថាលក្ខខណ្ឌរបស់ពាណិជ្ជករដែលជារូបវន្តបុគ្គល ទោះស្ត្រីក្តី បុរសក្តីមានលក្ខណៈដូចគ្នា មានន័យថាត្រូវបំពេញលក្ខខណ្ឌគតិយុត្តផ្សេងៗទៅតាមការកំណត់របស់ច្បាប់ជាធរមាន ដែស្ថិតនៅក្នុងក្របខណ្ឌសមភាពក្នុងការជ្រើសរើសមុខរបរ។ វាជាឱកាសសម្រាប់ស្ត្រីទាំងនៅលីវ និងរៀបការចូលរួមអភិវឌ្ឍជាតិដោយផ្ទាល់។ យ៉ាងណាមិញ គេសួរថា ស្ត្រីរៀបការជាពាណិជ្ជករអាចប៉ះពាល់ដល់កាតព្វកិច្ចជាភរិយា ជាម្តាយ និងសម្ថភាពសមត្ថភាពក្នុងការសម្រេចចិត្តដែរឬទេ? ចម្លើយគឺ វាមិនមានការប៉ះពាល់ ព្រោះថាស្ត្រីអាចបង្ហាញកាតព្វកិច្ចទាំងនេះតាមរបៀបច្រើនប្រភេទ។ ជាក់ស្តែង តាមរយៈការប្រកបរបរជាពាណិជ្ជករនេះ ស្ត្រីបានជួយរកចំណូលដល់គ្រួសារមួយផ្នែក ដែលចំណូលនេះអាចយកទៅប្រើប្រាស់ក្នុងតួនាទីជាភរិយា និងម្តាយ។ វាជាការល្អទៅវិញទេ ព្រោះស្ត្រីអាចក្រោកចេញពីផ្នត់គំនិតដែលមិនមានប្រយោជន៍សម្រាប់សតវត្សទី២១ ហើយថែមទាំងបានចូលរួមចំណែកអភិវឌ្ឍជាតិ តាមរយៈការបង់ពន្ធនានាជូនរដ្ឋ ក៏ដូចជាការកសាងគ្រួសារបានល្អ ផ្តល់ឱកាសឱ្យកូនៗទទួលការអប់រំបានខ្ពស់ ពោលគឺបានជួយសម្រាលបន្ទុករបស់រដ្ឋបានមួយចំណែក។

ចុងក្រោយ អ្វីដែលក្រុមយើងខ្ញុំទទួលបានតាមរយៈការវិភាគបកស្រាយនូវប្រធានបទខាងលើនេះគឺ វាមិនត្រឹមតែធ្វើឱ្យយើងចេះអំពីនីតិពាណិជ្ជកម្មប៉ុណ្ណោះទេ តែវាក៏បានធ្វើឱ្យយើងចេះពីនីតិដែលពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃផងដែរ។

# ឧបសម្ព័ន្ធ

# អនុសាសន៍

ដើម្បីចូលរួមចំណែកក្នុងការលើស្ទួយវិស័យពាណិជ្ជកម្ម ក្រុមយើងខ្ញុំសូមចូលរួមជាអនុសាសន៍ដូចខាងក្រោម៖

**ចំពោះស្ត្រីមិនទាន់រៀបការជាពាណិជ្ជករ:** មិនសូវមានជាបញ្ហាទេរឿងក្នុងការក្លាយជាពាណិជ្ជករតាមនីតិនោះទេ។ ម្យ៉ាងវិញទៀត ដោយសារសម័យបច្ចុប្បន្នមានការអភិវឌ្ឍដែលធ្វើឲ្យចំណេះដឹងរបស់ស្ត្រីមានសមត្ថភាពគ្រប់គ្រាន់ដូចទៅនឹងបុរស ដែលគាត់អាចដំណើរការអាជីវកម្មបានយ៉ាងរលូន មានគំនិតច្នៃប្រឌិតខ្ពស់ៗ។ ដូច្នេះ អ្វីដែលជាអនុសាសន៍ពីក្រុមរបស់យើងខ្ញុំនោះគឺសូមលើកទឹកចិត្តដល់ស្ត្រីនៅលីវឯទៀតៗដែលចង់ក្លាយជាពាណិជ្ជករ សូមធ្វើការពង្រឹងសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀតដោយខិតខំសិក្សាទាំងទ្រឹស្តី និងការអនុវត្ត ជាពិសេសពាក់ព័ន្ធនឹងនីតិពាណិជ្ជកម្ម ដើម្បីក្លាយខ្លួនជាពាណិជ្ជករមួយរូបដែលអាចចូលរួមចំណែករកចំណូលអភិវឌ្ឍន៍ជាតិ។

**ចំពោះស្ត្រីរៀបការជាពាណិជ្ជករ:** ត្រូវគិតឲ្យបានច្បាស់ពីបញ្ហាប្រព័ន្ធទ្រព្យសម្បត្តិ។ ជាយោបល់គួរជ្រើសរើប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ ដោយយកទ្រព្យដោយឡែករបស់ខ្លួនធ្វើពាណិជ្ជកិច្ច ព្រោះវាមិនងាយនឹងប៉ះពាល់ដល់បញ្ហាសុភមង្គលក្នុងគ្រួសារ។ ប៉ុន្តែប្រសិនបើក្នុងករណីមានបញ្ហាគ្រង់បំណុលកើតចេញពីការធ្វើពាណិជ្ជកម្ម តាមរយៈមនោសញ្ចេតនារវាងប្តីប្រពន្ធ អាចនាំឲ្យនឹងមានការជួយសង្គ្រោះ ដោយប្រើប្រាស់ទ្រព្យរួម ឬទ្រព្យដោយឡែករបស់សហព័ទ្ធម្ខាងទៀត។ ជាមួយគ្នានេះ គេសួរថា ស្ត្រីរៀបការជាពាណិជ្ជករអាចប៉ះពាល់ដល់កាតព្វកិច្ចជាភរិយា ជាម្តាយ និងសម្ថភាពសមត្ថភាពក្នុងការសម្រេចចិត្តដែរឬទេ? ចម្លើយគឺ វាមិនមានការប៉ះពាល់ ព្រោះថាស្ត្រីអាចបង្ហាញកាតព្វកិច្ចទាំងនេះតាមរបៀបច្រើនប្រភេទ។ ក្រុមយើងខ្ញុំសូមលើកទឹកចិត្តដល់ស្ត្រីរៀបការជាពាណិជ្ជករ ថាកុំឱ្យសំណួរនេះជាឧបសគ្គរាំងដល់ការធ្វើពាណិជ្ជកិច្ចឡើយ។

**ចំពោះគ្រួសាររបស់ស្ត្រីជាពាណិជ្ជករ:** ជាការចូលរួមចំណែកដោយប្រយោលក្នុងការអភិវឌ្ឍជាតិតាមរយៈមុខរបរជាពាណិជ្ជកររបស់ស្ត្រី សមាជិកទាំងឡាយនៅក្នុងក្រុមគ្រួសារ ឬ/និងសហព័ទ្ធ គឺជាចំណែកដ៏សំខាន់ក្នុងការលើកទឹកចិត្តឱ្យស្ត្រីប្រឹងប្រែងក្នុងប្រតិបត្តិការ ដោយប្តល់ជាការប្រឹក្សាយោបល់ (បើមាន) និងជួយដោះស្រាយបញ្ហាចំពោះមុខដែលស្ត្រីជួបប្រទះក្នុងពាណិជ្ជកិច្ចជាជាងការផ្តល់នូវការស្តីបន្ទោសនានា។

**ចំពោះរដ្ឋាភិបាល:** ដោយសារកម្ពុជាមិនទាន់មានក្រមពាណិជ្ជកម្ម និងក្រមនីតិពាណិជ្ជកម្ម យើងខ្ញុំសង្ឃឹមថានឹងមានការយកចិត្តទុកដាក់ពីសំណាក់អ្នកនីតិនិពន្ធ ព្យាយាមឱ្យអស់ពីកម្លាំង

កាយចិត្តបង្កើតឱ្យបានដោយមានបញ្ចូលនូវការអនុគ្រោះពិសេសនានាសំរាប់ស្ត្រី ដូចនៅក្នុងច្បាប់ការងារដែរ ព្រោះស្ត្រីជាភេទមួយដែលទន់ខ្សោយងាយរងគ្រោះ និងទទួលការបំពានទោះបីជាស្ត្រីជាពាណិជ្ជមួយរូចដែលរឹងមាំក៏ដោយ។ មួយវិញទៀត រដ្ឋាភិបាលគួរតែពិចារណាទៅលើការបង្កើតតុលាការពាណិជ្ជកម្មឱ្យលេចចេញជារូបរាងឱ្យបានឆាប់ ព្រោះថាពាណិជ្ជករជាស្ត្រីនាពេលបច្ចុប្បន្នកំពុងតែមានកំណើន (បើរាប់ទាំងចំនួនពាណិជ្ជករជាបុរសទៀត ចំនួនមានកាន់តែច្រើន) ខណៈពេលដែលវិស័យពាណិជ្ជកម្មនៅកម្ពុជាក៏មានការរីកចម្រើនជាលំដាប់ ដែលវាអាចបណ្តាលឱ្យវិវាទពាណិជ្ជកម្មក៏នឹងមានការកើនឡើងដូចគ្នា។ មានន័យថា កាលណាមានរូបរាងតុលាការជំនាញពាណិជ្ជកម្មដាច់ដោយឡែក វាគឺជាទំនុកចិត្តដល់ស្ត្រីឯទៀតៗ (ក៏ដូចជាបុរសដែរ) ក្នុងការវិវត្តន៍ខ្លួនទៅជាពាណិជ្ជករ ព្រោះថាកំណើននៃពាណិជ្ជករគឺជាផ្នែកមួយនៃកំណើនសេដ្ឋកិច្ចជាតិផងដែរ។

**ចំពោះស្ថាប័នដែលពាក់ព័ន្ធផ្សេងៗទៀត ទាំងជាតិ និងអន្តរជាតិ:** គួរតែបង្កើតឡើងនូវកម្មវិធីប្រកួតប្រជែងនានាដល់ស្ត្រីជាពាណិជ្ជករទាំងនៅលីវ និងរៀបការរួច ដើម្បីលើកកំពស់ដល់ការ ផ្តល់ឱកាសដល់ស្ត្រីនៅក្នុងវិស័យពាណិជ្ជកម្មឱ្យកាន់តែច្រើន ក៏ដូចជាពង្រឹងវិស័យនេះផងដែរ។ ជាពិសេសនោះគឺ បន្តគាំពារស្ត្រីតាមរយៈការផ្តល់ឱកាសផ្សេងៗទៀត ដើម្បីឱ្យស្ត្រីទាំងអស់ (ជាពិសេសនៅកម្ពុជា) ក្រោកចេញពីគំនៀបនៃផ្នត់គំនិតមិនរីកចម្រើន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥
ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧
ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ១៩៩៧
ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឆ្នាំ១៩៩៩
ច្បាប់ស្តីពីធានារ៉ាប់រង ឆ្នាំ២០០០
ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២
ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឆ្នាំ២០០៦
ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១
ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ២០០០
ប្រកាសស្តីអំពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ឆ្នាំ២០០៨
ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ២០១៤
ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ឆ្នាំ២០១៥

## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨
កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឆ្នាំ១៩៦៦
អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ឆ្នាំ១៩៨១

## សៀវភៅ

គង់ សាផន, *នីតិពាណិជ្ជកម្ម* , (បោះពុម្ព ២០១២)
ជិន វណ្ណារ៉ា, *នីតិកិច្ចសន្យា*, (បោះពុម្ព ២០១៣)
សំ បូណៃល, *ច្បាប់ពាណិជ្ជកម្មកម្ពុជា*, (បោះពុម្ព ២០១៥)
សេចក្តីកំណត់មាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណីភាគ៦ ឆ្នាំ២០១០

Michel de JUGLART និង Benamin IPPOLITO, *Cours de droit commercial*, Editor: MONTCHRESTIEN (1992)

UNDP, *Sustainable Development Goals*

## គេហទំព័រ

http://pichpov.blogspot.com/2008/12/blog-post_2575.html ទស្សនាថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧
http://www.moc.gov.kh ទស្សនាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧
http://mlvt.gov.kh ទស្សនាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧
http://www.mef.gov.kh/ ទស្សនាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧
http://www.mih.gov.kh/ ទស្សនាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ Sustainable Development Goals

ឧបសម្ព័ន្ធទី២ ៖ ប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព

ឧបសម្ព័ន្ធទី៣ ៖ ប្រកាសស្តីពីតាវកាលិកថែទាំសុខភាព

ឧបសម្ព័ន្ធទី៤ ៖ ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

ឧបសម្ព័ន្ធទី៥ ៖ ប្រកាសស្តីពីការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម

ឧបសម្ព័ន្ធទី៦ ៖ ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ឧបសម្ព័ន្ធទី៧ ៖ ប្រកាសស្តីពីការរៀបចំប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

ឧបសម្ព័ន្ធទី៨ ៖ ប្រកាសស្តីពីការកែប្រែបំពេញបន្ថែមឯកសារក្នុងទម្រង់បែបបទសម្រាប់ការចុះបញ្ជីពន្ធដារ

ឧបសម្ព័ន្ធទី៩ ៖ ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ

ឧបសម្ព័ន្ធទី១០៖ ប្រកាសរួមស្តីពីការជូនដំណឹងហានិភ័យការងារ

ឧបសម្ព័ន្ធទី១១៖ ប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ហានិភ័យការងារ

ឧបសម្ព័ន្ធទី១២៖ សេចក្តីជូនដំណឹងស្តីពីនីតិវិធីទូទាត់កម្រៃសេវាចុះបញ្ជីពាណិជ្ជកម្ម

ឧបសម្ព័ន្ធទី១៣៖ សេចក្តីជូនដំណឹងអំពីការបង់កម្រៃចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច

ឧបសម្ព័ន្ធទី១៤៖ សេចក្តីជូនដំណឹងស្តីពីនីតិវិធីនៃការបង់ភាគទាន និងការដោះស្រាយហានិភ័យការងារ

ឧបសម្ព័ន្ធទី១៥៖ សេចក្តីជូនដំណឹងស្តីពីឯកសារតំរូវសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម

# ឧបសម្ព័ន្ធទី១

## Sustainable Development Goals

UNDP

Empowered lives.
Resilient nations.

# SUSTAINABLE DEVELOPMENT GOALS


1 NO POVERTY
2 ZERO HUNGER
3 GOOD HEALTH AND WELL-BEING
4 QUALITY EDUCATION
5 GENDER EQUALITY
6 CLEAN WATER AND SANITATION
7 AFFORDABLE AND CLEAN ENERGY
8 DECENT WORK AND ECONOMIC GROWTH
9 INDUSTRY, INNOVATION AND INFRASTRUCTURE
10 REDUCED INEQUALITIES
11 SUSTAINABLE CITIES AND COMMUNITIES
12 RESPONSIBLE CONSUMPTION AND PRODUCTION
13 CLIMATE ACTION
14 LIFE BELOW WATER
15 LIFE ON LAND
16 PEACE, JUSTICE AND STRONG INSTITUTIONS
17 PARTNERSHIPS FOR THE GOALS

## IN 2000, 189 COUNTRIES OF THE WORLD CAME TOGETHER TO FACE THE FUTURE.

And what they saw was daunting. Famines. Drought. Wars. Plagues. Poverty. The perennial problems of the world. Not just in some faraway place, but in their own cities and towns and villages.

They knew things didn't have to be this way. They knew we had enough food to feed the world, but that it wasn't getting shared. They knew there were medicines for HIV and other diseases, but that they cost a lot. They knew that earthquakes and floods were inevitable, but that the high death tolls were not.

They also knew that billions of people worldwide shared their hope for a better future.

So leaders from these countries created a plan called the Millennium Development Goals (MDGs). This set of 8 goals imagined a future just 15 years off that would be rid of poverty and hunger. It was an ambitious plan.

**The United Nations Development Programme (UNDP)** has been one of the leading organizations working to achieve the MDGs. Present in more than 170 countries and territories, we funded projects that helped fulfil the Goals. We championed the Goals so that people everywhere would know how to do their part. And we acted as "scorekeeper," helping countries track their progress.

And the progress in those 15 years has been tremendous. Hunger has been cut in half. Extreme poverty is down nearly by half. More kids are going to school and fewer are dying.

Now these countries want to build on the many successes of the past 15 years, and go further. The new set of goals, the Sustainable Development Goals (SDGs), aims to end poverty and hunger by 2030. World leaders, recognizing the connection between people and planet, have set goals for the land, the oceans and the waterways. The world is also better connected now than it was in 2000, and is building a consensus about the future we want.

That future is one where everybody has enough food, and can work, and where living on less than $1.25 a day is a thing of the past.

UNDP is proud to continue as a leader in this global movement.

**Introducing the new Sustainable Development Goals. What's your Goal?**

# 1 NO POVERTY

## END POVERTY IN ALL ITS FORMS EVERYWHERE

End extreme poverty in all forms by 2030. Yes, it’s an ambitious goal—but we believe it can be done. In 2000, the world committed to cutting the number of people living in extreme poverty by half in 15 years and we met this goal. However, more than 800 million people around the world still live on less than $1.25 a day—that’s about the equivalent of the entire population of Europe living in extreme poverty. Now it’s time to build on what we learned and end poverty altogether.

# 2 ZERO HUNGER

## END HUNGER, ACHIEVE FOOD SECURITY AND IMPROVED NUTRITION AND PROMOTE SUSTAINABLE AGRICULTURE

In the past 20 years, hunger has dropped by almost half. Many countries that used to suffer from famine and hunger can now meet the nutritional needs of their most vulnerable people. It's an incredible accomplishment. Now we can go further and end hunger and malnutrition once and for all. That means doing things such as promoting sustainable agriculture and supporting small farmers. It's a tall order. But for the sake of the nearly 1 out of every 9 people on earth who go to bed hungry every night, we've got to try. Imagine a world where everyone has access to sufficient and nutritious food all year round. Together, we can make that a reality by 2030.

# 3 GOOD HEALTH AND WELL-BEING

## ENSURE HEALTHY LIVES AND PROMOTE WELL-BEING FOR ALL AT ALL AGES

We all know how important it is to be in good health. Our health affects everything from how much we enjoy life to what work we can perform. That's why there's a Goal to make sure everyone has health coverage and access to safe and effective medicines and vaccines. Since 1990, we've made big strides—preventable child deaths are down by more than half, and maternal mortality is down by almost as much. And yet some other numbers remain tragically high, like the fact that every year 6 million children die before their fifth birthday, or that AIDS is the leading cause of death for adolescents in sub-Saharan Africa. We have the means to turn that around and make good health more than just a wish.

# 4 QUALITY EDUCATION

## ENSURE INCLUSIVE AND EQUITABLE QUALITY EDUCATION AND PROMOTE LIFE-LONG LEARNING OPPORTUNITIES FOR ALL

First, the bad news on education. Poverty, armed conflict and other emergencies keep many, many kids around the world out of school. In fact, in developing regions, kids from the poorest households are four times more likely to be out of school than those of the richest households. Now for some good news. Since 2000, there has been enormous progress on the goal to provide primary education to all children worldwide. The primary school enrolment rate in developing regions reached 91%. By measures in any school, that's a good grade. Now, let's get an even better grade for all kids and achieve the goal of universal primary and secondary education, affordable vocational training, access to higher education and more.

# 5 GENDER EQUALITY

## ACHIEVE GENDER EQUALITY AND EMPOWER ALL WOMEN AND GIRLS

The great progress the world has made in becoming more prosperous and fair is worth celebrating. And yet, in just about every way, women and girls lag behind. There are still gross inequalities in work and wages, lots of unpaid "women's work" such as child care and domestic work and discrimination in public decision-making. But there are grounds for hope. More girls are in school now compared to in 2000. Most regions have reached gender parity in primary education. The percentage of women getting paid for their work is on the rise. The Sustainable Development Goals aim to build on these achievements to ensure that there is an end to discrimination against women and girls everywhere. It's a basic human right.

# 6 CLEAN WATER AND SANITATION

## ENSURE AVAILABILITY AND SUSTAINABLE MANAGEMENT OF WATER AND SANITATION FOR ALL

Everyone on earth should have access to safe and affordable drinking water. That's the goal for 2030. While many people around the world take clean drinking water and sanitation for granted, many others don't. Water scarcity affects more than 40 percent of people around the world, and that number is projected to go even higher as a result of climate change. If we continue the path we're on, by 2050 at least one in four people are likely to be affected by recurring water shortages. But we can take a new path—more international cooperation, protecting wetlands and rivers, sharing water-treatment technologies and more—that leads to accomplishing this Goal.

# 7 AFFORDABLE AND CLEAN ENERGY

## ENSURE ACCESS TO AFFORDABLE, RELIABLE, SUSTAINABLE AND MODERN ENERGY FOR ALL

Between 1990 and 2010, the number of people with access to electricity increased by 1.7 billion. That's progress to be proud of. And yet, as the world's population continues to rise, still more people will need cheap energy to light their homes and streets, use phones and computers and do their everyday business. The way we get that energy is at issue; fossil fuels and greenhouse gas emissions are making drastic changes in the climate, leading to big problems on every continent. Instead, we can become more energy-efficient and invest in clean energy sources such as solar and wind. That way we'll meet electricity needs and protect the environment. How's that for a balancing act?

# 8 DECENT WORK AND ECONOMIC GROWTH

## PROMOTE SUSTAINED, INCLUSIVE AND SUSTAINABLE ECONOMIC GROWTH, FULL AND PRODUCTIVE EMPLOYMENT AND DECENT WORK FOR ALL

An important part of economic growth is that people have jobs that pay enough to support themselves and their families. The good news is that the middle class is growing worldwide—almost tripling in size in developing countries in the last 25 years, to more than a third of the population. But in 2015, we also have widening inequalities, and job growth is not keeping pace with the growing labour force—over 200 million people don't have jobs. That's the equivalent of the entire population of Brazil. Things don't have to be that way. We can promote policies that encourage entrepreneurship and job creation. We can eradicate forced labour, slavery and human trafficking. And in the end we can achieve the goal of decent work for all women and men by 2030.

# 9 INDUSTRY, INNOVATION AND INFRASTRUCTURE

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ស្ដីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចំបាច់ក្នុងទិសដៅកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្មដើម្បីសម្រួលដល់វិស័យឯកជន និងគោលបំណងកិច្ចសម្រួលពាណិជ្ជកម្មដោយកាត់បន្ថយបែបបទ។
-បានឃើញប្រកាសលេខ ២៩៩ ពណ.ចបព.ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

# សម្រេច

**ប្រការ១៖**

កំណត់ឲ្យរាល់ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយ ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ មកចុះបញ្ជីសាឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មតាមគេហទំព័រ:www.businessregistration.moc.gov.kh ដើម្បីឲ្យការផ្លាស់ប្តូរនិងប្រើប្រាស់ទិន្នន័យ ការបំពេញទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារចាំបាច់ដែលត្រូវផ្ញើជូន ឬចេញដោយក្រសួងពាណិជ្ជកម្មអាចធ្វើទៅបានតាមប្រព័ន្ធអេឡិចត្រូនិក។

**ប្រការ២៖**

អភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាស ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវ។ អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសដែលបានចុះបញ្ជីសាឡើងវិញរួចហើយនឹងទទួលបានលេខចុះបញ្ជី និងវិញ្ញាបនបត្រថ្មីដែលផ្តល់ឲ្យតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយពុំមានកំណត់សុពលភាព ។

**ប្រការ៣៖**

ការចុះបញ្ជីសាឡើងវិញដូចមានចែងក្នុងប្រការ១ ត្រូវធ្វើឡើងចាប់ពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ប្រសិនជា អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងអស់មិនទាន់បានចុះបញ្ជីសាឡើងវិញ ក្នុងចន្លោះពេលពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ត្រូវតែបម្រុងទុកនាមករណ៍ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីចៀសវាងការបាត់បង់ឈ្មោះដែលបានចុះបញ្ជីមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦។ នាមករណ៍បម្រុងទុកមានសុពលភាព០៣ (បី) ខែ និងអាចស្នើសុំពន្យារពេល០៣ (បី)ខែ បន្តទៀតបាន ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ការបម្រុងទុកនាមករណ៍តាមប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចមុន ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ ត្រូវបញ្ចូលឯកសារវិញ្ញាបនប័ត្រដែលបានចុះបញ្ជី។

ក្នុងករណីអភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាសមិនអាចបំពេញព័ត៌មាន និងបញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវដោយខ្លួនឯងបាន អាចអញ្ជើញមកក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មជួយបំពេញព័ត៌មាន និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស។

**ប្រការ៤៖**

ក្នុងករណី អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាស មិនបានចុះបញ្ជីសាឡើងវិញតាមកាលបរិច្ឆេទកំណត់ក្នុងប្រការ៣ នោះការចុះបញ្ជីសាឡើងវិញនៅតែអាចធ្វើបន្តបានរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ តែត្រូវបង់កម្រៃសេវាសាធារណៈពេញលេញដូចជាការចុះបញ្ជីថ្មីដែរ។

**ប្រការ៥៖**

ប្រសិនជា អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងឡាយមិនបានចុះបញ្ជីសាឡើងវិញមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ទេនោះ ក្រសួងពាណិជ្ជកម្មនឹងធ្វើលិខិតបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជម្រះកាតព្វកិច្ចពន្ធដារ និងបញ្ជូនទៅតុលាការដើម្បីអនុវត្តតាមនីតិវិធីច្បាប់។

**ការ៦៖**

ការទូទាត់កម្រៃសេវាដែលត្រូវបង់ចូលជាថវិកាជាតិ ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារផ្អែកតាមការកំណត់ក្នុងប្រកាសរួមលេខ ១៦៤៣ សហវ. ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។ ក្រុមហ៊ុនអាចរក្សាទុកនូវបង្កាន់ដៃបង់ប្រាក់ដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចហើយ។ ក្នុងករណី ស្ថាបនិក ឬអភិបាល ឬម្ចាស់ហ៊ុនអញ្ជើញមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីជួយបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស ការទូទាត់កម្រៃសេវាត្រូវធ្វើដោយផ្ទាល់នៅបញ្ជរបង់ប្រាក់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៧៖**

ខ្លឹមសារប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៨៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រចាំការ **គាត ឈន់**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានគាំពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា "ដើម្បីជូនជ្រាប"
- ដូចប្រការ៨ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៦
## ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**

លេខ០៤២ ព.ណ.ជបព.ប្រក

ភ្នំពេញ, ថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៥

# ប្រកាស
# ស្តីពី
# ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចំបាច់ក្នុងទិសដៅកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្មដើម្បីសម្រួលដល់វិស័យឯកជន និងគោលបំណងកិច្ចសម្រួលពាណិជ្ជកម្មដោយកាត់បន្ថយបែបបទ។

# សម្រេច

**ប្រការ១៖**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួន សាខា ការិយាល័យតំណាងបុត្រសម្ព័ន្ធឬទីភ្នាក់ងាររបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ២៖**

ស្ថាបនិក ឬ អភិបាលឬម្ចាស់ហ៊ុនត្រូវបំពេញពាក្យសុំចុះបញ្ជីពាណិជ្ជកម្មជាទំរង់ដែលមានស្រាប់របស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។ ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្មដែលបានបំពេញដោយស្ថាបនិក ឬ អភិបាល ឬម្ចាស់ហ៊ុន និងឯកសារតម្រូវសំរាប់តម្កល់ត្រូវផ្តល់មកមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នៅបញ្ជរចុះបញ្ជីពាណិជ្ជកម្ម។

**ប្រការ៣៖**

សំណុំឯកសារចុះបញ្ជីពាណិជ្ជកម្មដែលត្រូវតម្កល់នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មមានដូចខាងក្រោម:

ក) សំណុំឯកសារដែលត្រូវតម្កល់សំរាប់ការចុះបញ្ជីក្រុមហ៊ុន

១. ពាក្យស្នើសុំត្រួតពិនិត្យនាមករណ៍ ចំនួន ០១ច្បាប់

២. ពាក្យសុំចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ច្បាប់

៣.លក្ខន្តិកៈក្រុមហ៊ុន យ៉ាងតិច ចំនួន ០៣ច្បាប់

៤.រូបថត ៤x៦ ម្នាក់ ចំនួន ០៣សន្លឹក

៥. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនម្នាក់ ចំនួន ០៣សន្លឹក

៦. បង្កាន់ដៃបង់កម្រៃសេវា ច្បាប់ដើម ចំនួន ០១ច្បាប់

៧.ករណីម្ចាស់ហ៊ុនជានីតិបុគ្គល

- ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ដែលទទួលស្គាល់ដោយច្បាប់ ចំនួន ០១ច្បាប់
- លិខិតតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ហ៊ុន ច្បាប់ដើម ចំនួន ០១ច្បាប់

៨.ក្រុមហ៊ុនត្រូវផ្តល់លិខិតបញ្ជាក់ច្បាប់ដើមពីការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារណាមួយ ចំនួន ០១ច្បាប់ ទៅអោយនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពី ថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីក្រសួងពាណិជ្ជកម្ម ។

ខ) សំណុំឯកសារដែលត្រូវតម្កល់សំរាប់ការចុះបញ្ជីសាខា ឬការិយាល័យតំណាង

១. ពាក្យស្នើសុំត្រួតពិនិត្យនាមករណ៍ ចំនួន ០១ច្បាប់

២. ពាក្យសុំចុះឈ្មោះការិយាល័យតំណាងពាណិជ្ជកម្ម ឬសាខាក្រុមហ៊ុន

ក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ច្បាប់

៣.ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ ដែលទទួលស្គាល់ដោយច្បាប់ ចំនួន ០១ច្បាប់

៤. លិខិតតែងតាំងអភិបាលការិយាល័យតំណាង ឬសាខា ចំនួន ០១ច្បាប់

៥. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់នាយកការិយាល័យតំណាងឬសាខា ម្នាក់ចំនួន ០៣ច្បាប់

៦.រូបថត ៤x៦ ម្នាក់ចំនួន ០៣សន្លឹក

៧.បង្កាន់ដៃបង់កម្រៃសេវា ចំនួន ០១ច្បាប់

គ) **សំណុំឯកសារដែលត្រូវតម្កល់សំរាប់ការចុះបញ្ជីសហគ្រាសឯកបុគ្គល**

១. ពាក្យស្នើសុំត្រួតពិនិត្យនាមករណ៍ ចំនួន ០១ច្បាប់

២. ពាក្យសុំចុះឈ្មោះសហគ្រាសក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ច្បាប់

៣.ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនរបស់ឯកកម្មសិទ្ធិករ ចំនួន ០៣ច្បាប់

៤.រូបថត ៤x៦ របស់ឯកកម្មសិទ្ធិករ ចំនួន ០៣សន្លឹក

៥. បង្កាន់ដៃបង់កម្រៃសេវា ចំនួន ០១ច្បាប់

**ប្រការ៤៖**

ខ្លឹមសារនៃសេចក្ដីជូនដំណឹង និងប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

**ចម្លងជូន:**

- ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី ប្រចាំការ គាត ឈន់
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
អគ្គនាយកសេវាពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

# តារាងដំណើរការការងារចុះបញ្ជីកែប្រែក្រុមហ៊ុនមួយ

Flow Chart




ឯកភាពដាក់អោយអនុវត្ត
ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១៤
ជ. ~~ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម~~
រដ្ឋលេខាធិការទទួលបន្ទុក

ទឹក_ប្រែជា

បានឃើញ និង ឯកភាព
ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤
អគ្គនាយកសេវាពាណិជ្ជកម្ម

ស៊ុខ ស៊ុភ័ក្ត្រ

ធ្វើនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤
ប្រធានស្តីទី
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

# ឧបសម្ព័ន្ធទី៧
## ប្រកាសស្តីពីការរៀបចំប្រព្រឹត្តទៅរបស់
## នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*

លេខ ១៩០ ព.ណ. ឯ.ប.ក ប្រក

ភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤

នាយកដ្ឋានស្ថិតិនិងព័ត៌មានពាណិជ្ជកម្ម
ចូល លេខ ......
ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤
បញ្ជូន ......

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់
## នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

*******

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥) -២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*

# សម្រេច

**ប្រការ១៖**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង កាន់កាប់ការចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងតាមដានសកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និង ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ផ្តល់សេវាពិនិត្យ និងរក្សាទុកការអនុញ្ញាតឱ្យប្រើប្រាស់នាមករណ៍ក្រុមហ៊ុន សហគ្រាស
- ផ្តល់សេវាប្រឹក្សាយោបល់ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម និងផ្តល់ព័ត៌មានពាក់ព័ន្ធ
- គ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ ការរក្សាទុកព័ត៌មាន ទិន្នន័យក្រុមហ៊ុន សហគ្រាស
- រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋាននានា ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ ការរំលាយ-ការលុបឈ្មោះ ការតម្កល់ប្រតិវេទន៍ និងការគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្មរបស់ក្រុមហ៊ុន សហគ្រាស
- សម្របសម្រួល ដោះស្រាយវិវាទ ដែលទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាស
- ត្រួតពិនិត្យ តាមដាន ផ្ទៀងផ្ទាត់ព័ត៌មាន-ទិន្នន័យ ការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់របស់ក្រុមហ៊ុន សហគ្រាស និងសហការជាមួយស្ថាប័នមានសមត្ថកិច្ចនានាក្នុងការអនុវត្តភារៈកិច្ច
- គ្រប់គ្រងមណ្ឌលរក្សាទុកឯកសារចុះបញ្ជីពាណិជ្ជកម្ម
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់នាយកដ្ឋាន
- ស្រាវជ្រាវ និងផ្តល់ព័ត៌មានជូនអតិថិជនទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម
- ណែនាំ តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីវិធានពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំ។

**ប្រការ២៖**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៣៖**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានការិយាល័យចំណុះចំនួន ៥ (ប្រាំ) ដូចខាងក្រោម៖
- ការិយាល័យព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម
- ការិយាល័យចុះបញ្ជីកែប្រែពាណិជ្ជកម្ម
- ការិយាល័យប្រតិវេទន៍ និងតាមដានអាជីវកម្ម
- ការិយាល័យតម្កល់ឯកសារបញ្ជីពាណិជ្ជកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៤៖**

ការិយាល័យព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ៖
- ប្រចាំការនៅបញ្ជរជួរមុខរបស់នាយកដ្ឋាន
- ទទួលព័ត៌មាន និងប្រឹក្សាយោបល់ជាមួយអតិថិជនអំពីនីតិវិធីចុះបញ្ជីពាណិជ្ជកម្ម
- រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋាន បញ្ញត្តិច្បាប់នានារបស់នាយកដ្ឋាន
- បំពេញការងាររដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ
- ពិនិត្យ រក្សាទុកនិងបញ្ជូននាមករណ៍ទៅសុំការអនុញ្ញាតពីថ្នាក់ដឹកនាំ ដែលអតិថិជនស្នើសុំចុះបញ្ជីគ្រាដំបូង និងនាមករណ៍ស្នើសុំកែប្រែ
- ត្រួតពិនិត្យ ទទួល និងប្រគល់សំណុំឯកសារចុះបញ្ជីពាណិជ្ជកម្មជូនអតិថិជន
- កាន់កាប់បញ្ជីកាលប្បវត្តិ ( ផ្តល់អត្តលេខចុះបញ្ជី និងផ្តល់លេខរៀងកាលប្បវត្តិ ) លើគ្រប់ឯកសារទាំងអស់ដែលស្នើសុំតម្កល់ទុកក្នុងនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- ធ្វើរបាយការណ៍ និងបូកសរុបពីគ្រប់ការិយាល័យសម្រាប់នាយកដ្ឋានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៥៖**

ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖
- ផ្តល់យោបល់ជូនអតិថិជនពីនីតិវិធីក្នុងការចុះបញ្ជីពាណិជ្ជកម្មថ្មី

- ចុះបញ្ជីពាណិជ្ជកម្មថ្មី នូវរាល់សហគ្រាសពាណិជ្ជកម្ម សហគ្រាសឯកបុគ្គល សហគ្រាសសាធារណៈ គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ក្រុមហ៊ុនធានារ៉ាប់រង ។ល។
- ចូលរួមរៀបចំ និងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច
- បញ្ចូល និងគ្រប់គ្រងទិន្នន័យចុះបញ្ជីពាណិជ្ជកម្មទៅក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ (DATABASE SERVER )
- រៀបចំលិខិតបទដ្ឋានស្តីពីការចុះបញ្ជីពាណិជ្ជកម្មថ្មី
- ចូលរួមដោះស្រាយវិវាទដែលអាចកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្មថ្មី
- គ្រប់គ្រងការចុះបញ្ជីតាមបណ្តាខេត្ត-រាជធានី
- ធ្វើរបាយការណ៍ និងបូកសរុបស្ថិតិរាល់ការចុះបញ្ជីពាណិជ្ជកម្មថ្មី
- ស្រាវជ្រាវ និងផ្តល់ព័ត៌មានទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៦៖**

ការិយាល័យចុះបញ្ជីកែប្រែ មានភារកិច្ចដូចតទៅ៖

- ផ្តល់យោបល់ជូនអតិថិជនពីនីតិវិធីក្នុងការចុះបញ្ជីពាណិជ្ជកម្ម និងត្រួតពិនិត្យសំណុំឯកសារ លើរាល់ការសុំកែប្រែ ក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្ម គ្រប់ប្រភេទ
- ចុះបញ្ជីរាល់ការកែប្រែរបស់ក្រុមហ៊ុន សហគ្រាស ៖ សហគ្រាសពាណិជ្ជកម្ម សហគ្រាសឯកបុគ្គល សហគ្រាសសាធារណៈ ការិយាល័យតំណាង ឬសាខាក្រុមហ៊ុនបរទេស គ្រឹះស្ថានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ចុះបញ្ជីរាល់ការប្តូរទ្រង់ទ្រាយ ចុះបញ្ជីការបង្កើត ឬការកែប្រែសាខាក្រុមហ៊ុនក្នុងស្រុក និងរាល់ការកែប្រែផ្សេងៗទៀត
- ការចេញវិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មឡើងវិញ
- គ្រប់គ្រងការបញ្ចូលទិន្នន័យរាល់ការកែប្រែរបស់បណ្តាក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្មក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ ( DATABASE SERVER )
- រៀបចំលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការលើការកែប្រែ
- ចូលរួមដោះស្រាយបញ្ហាបណ្តឹងវិវាទទាំងឡាយដែលកើតឡើងពីរាល់ការចុះបញ្ជី-ពាណិជ្ជកម្មនិងរក្សាទុកនូវរាល់ឯកសារដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ និងផ្តល់ស្ថិតិសហគ្រាសពាណិជ្ជកម្ម ដែលបានធ្វើការកែប្រែ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៧៖**

ការិយាល័យប្រតិវេទន៍ និងតាមដានអាជីវកម្ម មានភារកិច្ចដូចតទៅ៖

- តាមដាន និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- គ្រប់គ្រងលើការងារបំពេញប្រតិវេទន៍ប្រចាំឆ្នាំ ការសុំផ្អាកឬបន្តសកម្មភាពអាជីវកម្ម ការរំលាយ-ការលុបឈ្មោះក្រុមហ៊ុន សហគ្រាស ការបញ្ចូលទិន្នន័យ ព័ត៌មាន និងវាយតម្លៃ កំណត់នូវស្ថានភាពក្រុមហ៊ុន សហគ្រាស-ក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ (DATABASE SERVER)
- ចេញលិខិតបញ្ជាក់ការបានបំពេញឬមិនបានបំពេញប្រតិវេទន៍ប្រចាំឆ្នាំតាមការចាំបាច់
- រៀបចំ និងផ្សព្វផ្សាយ លិខិតបទដ្ឋាន សេចក្តីជូនដំណឹង ប្រកាស និងចាត់វិធានការនានា ដែលពាក់ព័ន្ធទៅនឹងការមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ការផ្តល់ព័ត៌មានមិនពិត និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាសពីបញ្ជីពាណិជ្ជកម្ម
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីពិនិត្យតាមដាន និងចុះធ្វើសម្រង់ព័ត៌មានទាក់ទងនឹងការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុន សហគ្រាសតាមច្បាប់និងបទប្បញ្ញត្តិនានា
- ទទួលបន្ទុកការងារផាកពិន័យចំពោះក្រុមហ៊ុន សហគ្រាសដែលមិនគោរពច្បាប់ពាណិជ្ជកម្មជាធរមាន
- ចូលរួមដោះស្រាយវិវាទដែលកើតឡើងពីការចុះបញ្ជីពាណិជ្ជកម្ម និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាសចេញពីបញ្ជីពាណិជ្ជកម្ម
- ធ្វើរបាយការណ៍ និងផ្តល់ស្ថិតិនៃការបំពេញប្រតិវេទន៍ ការផ្អាកឬបន្តសកម្មភាពអាជីវកម្ម និងការលុបឈ្មោះសហគ្រាសពាណិជ្ជកម្ម ព្រមទាំងរៀបចំរបាយការណ៍វិវាទ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៨៖**

ការិយាល័យតម្កល់ឯកសារបញ្ជីពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង ថែរក្សា ត្រួតពិនិត្យ តាមដានសំណុំឯកសារដែលបានអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម និងតម្កល់ទុកក្នុងឃ្លាំងឯកសារ
- គ្រប់គ្រងទិន្នន័យចុះបញ្ជីពាណិជ្ជកម្មក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ(DATABASE SERVER) និងបញ្ចេញទិន្នន័យចុះបញ្ជីពាណិជ្ជកម្មលើគេហទំព័រ
- ផ្តល់ព័ត៌មានតាមរយៈឯកសារដែលបានតម្កល់ទុក ឬផ្តល់ឯកសារ ជាក់ស្តែងក្នុងករណីចាំបាច់ ដោយមានការអនុញ្ញាតពីប្រធាននាយកដ្ឋាន និងអគ្គនាយកសេវាពាណិជ្ជកម្ម

- ទទួលបញ្ជាក់លើច្បាប់ចតចម្លងសំណុំឯកសារចុះបញ្ជីពាណិជ្ជកម្ម
- បញ្ជាក់នីតិបុគ្គលិកលក្ខណៈនិងសម្រង់ព័ត៌មានអំពីការចុះបញ្ជីរបស់ក្រុមហ៊ុនសហគ្រាសពាណិជ្ជកម្ម
- ផ្តល់ព័ត៌មានជូនដល់អតិថិជន និង ចេញវិញ្ញាបនប័ត្របញ្ជាក់
- ចូលរួមដោះស្រាយវិវាទដែលអាចកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្ម
- ធ្វើរបាយការណ៍បូកសរុបការងារការិយាល័យជូននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៩៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម



# ឧបសម្ព័ន្ធទី៨

## ប្រកាសស្ដីពីការកែប្រែបំពេញបន្ថែម
## ឯកសារភ្ជាប់គម្រូវបែបបទសម្រាប់ការ
## ចុះបញ្ជីពន្ធដារ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០០៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## ការកែប្រែបំពេញបន្ថែមឯកសារក្នុងទម្រង់បែបបទសម្រាប់ការចុះបញ្ជីពន្ធដារ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទីទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុ មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃ ទី២៨ ខែមីនា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើង ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ១**: ដូចមានចែងក្នុងមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងផ្នែកទី១៣.១ នៃជំពូកទី១៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះធ្វើសកម្មភាពសេដ្ឋកិច្ច ។ បុគ្គលទាំងឡាយ ត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរ អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង សមាសភាពអ្នកទទួលបន្ទុកកិច្ចការពន្ធដារ ឬក្រោយពីមានការផ្ទេរ ឬការបញ្ឈប់អាជីវកម្ម ។

ពាក្យសុំចុះបញ្ជី និងលិខិតជូនដំណឹង ត្រូវអនុវត្តតាមទម្រង់លិខិតឯកភាព និងបែបបទកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ។ ពាក្យសុំចុះបញ្ជីត្រូវមានភ្ជាប់ឯកសារ ដូចតទៅ៖

ក- ចំពោះសហគ្រាសនីតិបុគ្គល

១.វិញ្ញាបនបត្រ និងលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ដែលបានបង់ពន្ធប្រថាប់ត្រា អមភ្ជាប់ច្បាប់ថតចម្លងនៃសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដែលជាអាទិ៍មាន៖ ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម លក្ខន្តិកៈសហគ្រាស ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម...។ល។

២.ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់អ្នកដឹកនាំសហគ្រាស ជាមួយនឹងរូបថតទំហំ ៤x៦ ចំនួន ០២សន្លឹក និងច្បាប់ថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជនជាតិខ្មែរ ។ ច្បាប់ថតចម្លងលិខិតឆ្លងដែន អមភ្ជាប់ដោយច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យ ជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលជនបរទេសនោះ ស្នាក់នៅ ។

៣.លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះ វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណផ្នែកសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនទ្រព្យ ក្រសួង ឬមន្ទីរ ទេសចរណ៍ ចំពោះសកម្មភាពអាជីវកម្ម សណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍... ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះសកម្មភាពអាជីវកម្មសាងសង់ជាដើម ។ល។

៤.វិញ្ញាបនបត្រចុះបញ្ជី របស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់) ។

៥.ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស តាមគំរូឯកភាពដែលផ្តល់ជូនដោយអគ្គនាយកដ្ឋានពន្ធដារ និងកិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម) និងលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង។

៦.ច្បាប់ថតចម្លងវិក្កយបត្រទឹក និងអគ្គិសនី (រយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ។

ខ- ចំពោះសហគ្រាសឯកបុគ្គល

១.វិញ្ញាបនបត្រ និងលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អមភ្ជាប់មកជាមួយច្បាប់ថតចម្លងសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីពាណិជ្ជកម្ម ។

២.ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់អ្នកដឹកនាំសហគ្រាស ជាមួយនឹងរូបថតទំហំ ៤x៦ ចំនួន ០២សន្លឹក និងច្បាប់ថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជនជាតិខ្មែរ ។ ច្បាប់ថត

ចម្លងលិខិតឆ្លងដែន អមភ្ជាប់ដោយច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យ ជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលជនបរទេសនោះ ស្នាក់នៅ ។

៣.លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដូចជា មន្ទីរទេសចរណ៍ ចំពោះសកម្មភាព អាជីវកម្មសណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍... មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះ សកម្មភាពអាជីវកម្មសាងសង់ ជាដើម ។ល។

៤.ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស តាមគំរូឯកភាពដែលផ្តល់ជូនដោយអគ្គនាយកដ្ឋានពន្ធដារ និងកិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម) និងលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង ។

៥.ច្បាប់ថតចម្លងវិក្កយបត្រទឹក និងអគ្គិសនី (រយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ។

**ប្រការ២**: ដូចមានចែងក្នុងមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី តែពុំបានមកចុះបញ្ជី ហើយក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី ។

**ប្រការ៣**: ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានចាត់ទុកជាអំពើរាំងស្ទះ ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (ដែលត្រូវទទួលរងទោសទណ្ឌ ដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ) ក្នុងករណីដែល បុគ្គលមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ឬមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ពីការផ្លាស់ប្តូរផ្សេងៗ ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ៤**: អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាស នេះឱ្យបានល្អប្រសើរ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

__ចម្លងជូនៈ__

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី } "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់សាលារាជធានី-ខេត្ត }
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# ពាក្យសុំចុះបញ្ជីពន្ធដារ

នាមត្រកូល និងនាមខ្លួន៖.................................................................................. សញ្ជាតិ៖..............................................
អាសយដ្ឋានបច្ចុប្បន្ន៖...............................................................................................................................................
អត្តសញ្ញាណបណ្ណ☐ លិខិតឆ្លងដែនលេខ☐..............................................................ចុះថ្ងៃទី...........ខែ...........ឆ្នាំ..............
ក្នុងនាមជា៖ ស្ថាបនិក ☐ អភិបាល ☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐
នៃ ក្រុមហ៊ុន☐ សហគ្រាស☐៖.............................................................................................................
Name of Enterprise: ...........................................................................................................

ខ្ញុំបាទ/នាងខ្ញុំ សុំចុះឈ្មោះ ក្រុមហ៊ុន សហគ្រាស ដូចមានឈ្មោះខាងលើ ក្នុងបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម៖

១. វិញ្ញាបនបត្រ បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម☐
២. លិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម☐
៣. ច្បាប់ថតចម្លងនៃសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម៖
   - ច្បាប់ថតចម្លងពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម☐
   - ច្បាប់ថតចម្លងលក្ខន្តិកៈសហគ្រាស☐
   - ច្បាប់ថតចម្លងពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម☐
   - ច្បាប់ថតចម្លងលិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ☐
   - ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណ☐ ឬ ច្បាប់ថតចម្លងលិខិតឆ្លងដែន(សម្រាប់ជនបរទេស)☐ នៃស្ថាបនិក☐ អភិបាល☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐និងរូបថត៤x៦ចំនួន០២សន្លឹក
៤. ច្បាប់ថតចម្លងសៀវភៅគ្រួសារ☐ ឬសៀវភៅស្នាក់នៅ☐ ឬច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ(សម្រាប់ជនបរទេស)ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត☐ នៃស្ថាបនិក☐ អភិបាល☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐
៥. លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម ចេញដោយស្ថាប័នមានសមត្ថកិច្ច☐
៦. វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា☐
៧. កិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម)☐ ភ្ជាប់ដោយលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង☐
៨. វិក្កយបត្រទឹក និងអគ្គិសនី (ច្បាប់ថតចម្លងរយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស☐
៩. ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ☐
១០. សលាកបត្រព័ត៌មានសហគ្រាស/ក្រុមហ៊ុន☐
១១. ពាក្យស្នើសុំចុះបញ្ជីអាករលើតម្លៃបន្ថែម (សម្រាប់របបស្វ័យប្រកាស)☐
១២. លិខិតប្រកាសអាករលើផលរបរ និងពន្ធលើប្រាក់ចំណេញ "របបមៅការ"☐
១៣. លិខិតប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំសម្រាប់របបមៅការ☐ ឬរបបស្វ័យប្រកាស☐

ពាក្យសុំចុះបញ្ជីពន្ធដារនេះមានចំនួន..............ច្បាប់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................................ឋានៈ/តួនាទី.....................................................នៃសហគ្រាស/ក្រុមហ៊ុនខាងលើសូមធានាថា ឯកសារ និងព័ត៌មានទាំងអស់ភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជីពន្ធដារនេះ ពិតជាត្រឹមត្រូវ ។ ខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

ធ្វើនៅ........................, ថ្ងៃទី............ខែ............ឆ្នាំ............

បានទទួលពាក្យសុំចុះបញ្ជី
ថ្ងៃទី............ខែ............ឆ្នាំ............
មន្ត្រីពន្ធដារ

*កំណត់សម្គាល់៖ សូមគូសសញ្ញា ✓ នៅក្នុងប្រអប់ចំពោះឯកសារដែលមានភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជីពន្ធដារ ។*

# ឧបសម្ព័ន្ធទី៩

## ប្រកាសស្ដីពី

## តារាងកាលិកហានិភ័យការងារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ......១០៥........កប/ប្រ.ក

# ប្រកាស
# ស្តីពី
# ឆាកភាលិកមានិតំយការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

### ប្រការ ១.- សិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ

១.១ កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជនទទួលរងនូវហានិភ័យការងារ ។

១.២ ហានិភ័យការងារ រួមមាន គ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជំងឺវិជ្ជាជីវៈ ។

១.៣ តាវកាលិកដែលកំណត់ក្នុងប្រកាសនេះត្រូវនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

១.៤ មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ឬគ្រូពេទ្យព្យាបាល ត្រូវមានការទទួលស្គាល់ពីបេឡាជាតិរបបសន្តិសុខសង្គម ។

### ប្រការ ២.- ការជូនដំណឹងហានិភ័យការងារ

២.១ បន្ទាប់ពីបានទទួលដំណឹងពីកម្មករនិយោជិតដែលជាអ្នករងនូវហានិភ័យការងារ ឬអ្នកតំណាងអ្នករងគ្រោះ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានចុះបញ្ជីកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុនោះទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ ។

២.២ ការជូនដំណឹងហានិភ័យការងារត្រូវធ្វើតាមទម្រង់បែបបទដែលមានកំណត់នៅក្នុងប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ។

### ប្រការ ៣.- ការអង្កេតហានិភ័យការងារ

៣.១ បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្តក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម ។

អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យ តាវកាលិកឱ្យបានយ៉ាងឆាប់បំផុត ។

៣.២ ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ ។ ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

៣.៣ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅទីកន្លែងកើតហេតុ ។

## ប្រការ ៤.- ការផ្តល់សេវាសង្គ្រោះបន្ទាន់

ក្នុងករណីដែលគ្រោះថ្នាក់កើតនៅទីកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សង លើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម ។

## ប្រការ ៥.- ការផ្តល់សេវាថែទាំ និងព្យាបាល

៥.១ ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។

៥.២ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបាន ការពិនិត្យព្យាបាល ការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ផ្អែកលើកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី ។

៥.៣ ក្នុងករណីដែល គ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬ សំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀង បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ ។

៥.៤ នាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំបញ្ជីមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលមានលក្ខណៈសម្បត្តិសមស្របតាមបទដ្ឋានបច្ចេកទេសវេជ្ជសាស្ត្រ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃបេឡា

ជាតិរបបសន្តិសុខសង្គមអនុម័តយល់ព្រម ។

## **ប្រការ ៦.- ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនកាលបរិច្ឆេទនៃគ្រោះថ្នាក់ ។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុង**ឧបសម្ព័ន្ធ ១** នៃប្រកាសនេះ ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង ៣០ (សាមសិប) ថ្ងៃ ។ = ប្រាក់ឈ្នួលមធ្យម / ៣០

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវិកាលិកសន្តិសុខសង្គមប៉ុណ្ណោះ ។

## **ប្រការ ៧.- ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន**

៧.១ រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ:

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ។

៧.២ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ៧.១ ខាងលើ កម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវិកាលិកពីបេឡាជាតិរបបសន្តិសុខសង្គម ដូចតទៅ:

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ក្នុងករណី ដែលស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរតម្រូវឱ្យមានអ្នកនៅចាំថែទាំ តាមសំណើសុំរបស់គ្រូពេទ្យព្យាបាល ។

៧.៣ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវផ្តល់ចំពោះតែហានិភ័យការងារ ដែលតម្រូវឱ្យមានការសម្រាកព្យាបាលលើសពី ០៤ (បួន) ថ្ងៃឡើងទៅ ។

៧.៤ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ។

៧.៥ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន អាចផ្ដល់ជូនជនរងគ្រោះដោយហានិភ័យការងារ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ (មួយរយប៉ែតសិប) ថ្ងៃ។

**ប្រការ ៨.- អត្ថប្រយោជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

៨.១ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្ដល់ជូនអ្នករងគ្រោះតែម្ដងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម:

**វបក = បឈម x ៧០% x កបក x ២០%មតប**

- **វបក:** វិភាជន៍បាត់បង់សមត្ថភាពការងារ
- **បឈម:** ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- **កបក:** កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- **មតប:** មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ។ប្រាក់ធនលាភសរុបសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម:

**ធល = បឈម x ៧០ % x [កបក − ១/៥ កបក] x មតប**

- **ធល:** ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្ដោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញក្នុងរយៈពេល ១ (មួយ) ឆ្នាំយ៉ាងយូរ។ ជនរងគ្រោះដែលទទួលបានប្រាក់ធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

៨.៤ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ៣**។

**ប្រការ ៩.- ប្រាក់បន្ថែមសម្រាប់អ្នកថែរក្សាជនរងគ្រោះ**

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ ភាគរយ មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកថែរក្សាផ្ទាល់ខ្លួន។ ប្រាក់បន្ថែម

សម្រាប់អ្នកចាំថែរក្សាត្រូវស្មើ ៥០ ( ហាសិប ) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ ។

**ប្រការ ១០.- ប្រាក់វិភាគទានជាសោហ៊ុយបូជាសព**

ក្នុងករណីដែលមានការទទួលរងនូវហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រង ក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ១.០០០.០០០ ( មួយលាន ) រៀល ។ ប្រាក់វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជន ដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

**ប្រការ ១១.- តាវកាលិកឧត្តរជីវិ**

១១.១ ឧត្តរជីវីនៃជនរងគ្រោះដោយហានិភ័យការងារដូចមានចែងនៅក្នុងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី ។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ តាមអត្រាដូចខាងក្រោម៖

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក= ២/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បឈម

ខ. ក្នុងករណីសិទ្ធិវន្ត មានតែប្រពន្ធ ឬប្តី និង/ឬ កូន

- ប្រពន្ធ ឬប្តី = ៣/៥ x ៧០%បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%បឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ឃ. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

១១.៣ សិទ្ធិវន្ត ជាប្រពន្ធ ឬប្ដីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះសិទ្ធិវន្តដែលជាប្រពន្ធ ឬប្ដី ត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។

១១.៤ សិទ្ធិវន្តជា កូនត្រូវមានស្ថានភាពស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច ៣៤.១ ខ មាត្រា ៣៤ នៃអនុក្រឹត្យលេខ១៦ អនក្រ/បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។

១១.៥ សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

**ប្រការ ១២.- សេវាមុខងារនិងសម្ភារ**

១២.១កម្មករនិយោជិតដែលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

១២.២កម្មករនិយោជិតដែលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**ប្រការ ១៣.- ការទាមទារពាក្យកាលិក**

១៣.១ ការទាមទារពាក្យកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់ តាមទម្រង់ "**ពាក្យកាលិកថែទាំ និងព្យាបាល** " ឬហៅថាទម្រង់ " **៣.០២** "ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៤** នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្នត្រូវធ្វើដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**ពាក្យកាលិកបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន** " ឬហៅថាទម្រង់ "**៣.០៣** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៥** នៃប្រកាសនេះ។ បែបបទ នៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារពាក្យកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**ពាក្យកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍** " ឬហៅថាទម្រង់

"៣.០៤ " ដូចមានចែងក្នុង**ឧបសម្ព័ន្ធ ៦** នៃប្រកាសនេះ។ ក្នុងករណីដែល ជនរងគ្រោះមិនអាចមានសមត្ថភាព ក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្តី ប្រពន្ធ កូន ឬជន ដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាង តាមទម្រង់ "**តាវកាលិកឧត្តរជីវី** " ឬហៅថាទម្រង់ " **៣.០៥** " និងទម្រង់ " **វិភាជន៍បូជាសព**" " ឬហៅថា ទម្រង់ "**៣.០៦** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៧ និង ៨** នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល ១ (មួយ) ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភ ត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ (ប្រាំ) ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើប្រចាំត្រីមាស។

## ប្រការ ១៤.- ការយល់ព្រមចំពោះការទាមទារតាវកាលិក

១៤.១ តាវកាលិកថែទាំ និងព្យាបាល ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការថែទាំនិងព្យាបាលនោះធ្វើនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែលបេឡាជាតិរបបសន្តិសុខសង្គមបានកំណត់។

តារាងតម្លៃសម្រាប់ការថែទាំ និងព្យាបាល ត្រូវបានកំណត់តាមកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គម និងបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។

១៤.២ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការទាមទារនោះស្របនឹងលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ វាក្យខ័ណ្ឌ ៧.១, ៧.២ និង ៧.៣ នៃប្រកាសនេះ។

១៤.៣ តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានយល់ព្រម លុះត្រាតែការបាត់បង់សមត្ថភាពនោះត្រូវបានវាយតម្លៃពីគ្រូពេទ្យផ្លូវការ ឬ គណកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម ស្របតាមតារាងនៃកម្រិតបាត់បង់សមត្ថភាពការងារដូចមានចែងក្នុង**ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ក្នុងករណីដែល កម្រិតបាត់បង់សមត្ថភាពការងារពុំមានចែងនៅក្នុងតារាងខាងលើ គណកម្មការ

វេជ្ជសាស្ត្រ ត្រូវវាយតម្លៃកម្រិតបាត់បង់សមត្ថភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ ដោយមានការចូលរួមពីគ្រូពេទ្យឯកទេសតាម ស្ថានភាពជាក់ស្តែងនីមួយៗ ។

**ប្រការ ១៥.- អន្តរប្បញ្ញត្តិ**

ចំពោះសហគ្រាស គ្រឹះស្ថានដែលពុំទាន់ត្រូវបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមការផ្តល់តាវកាលិកសម្រាប់ហានិភ័យការងារ ត្រូវបន្តអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ១៦.- អវសានប្បញ្ញត្តិ**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធ ១ នៃប្រកាសលេខ ១០៩ ករ/ប្រក ស្តីពីភាគទានរបបហានិភ័យការងារ

## តារាងថ្នាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន(រៀល) |
|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ |
| ២ | ២០០.០០១ -២៥០.០០០ | ២២៥.០០០ |
| ៣ | ២៥០.០០១-៣០០.០០០ | ២៧៥.០០០ |
| ៤ | ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ |
| ៥ | ៣៥១.០០១-៤០០.០០០ | ៣៧៥.០០០ |
| ៦ | ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ |
| ៧ | ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ |
| ៨ | ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ |
| ៩ | ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ |
| ១០ | ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ |
| ១១ | ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ |
